# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៩ លេខ ១០ ខែតុលា ព.ស.២៥០០ គ.ស. ១៩៥៧

# កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ


ផ្នែកសាសនា បញ្ជីរឿង ទំព័រ

–អប្បមាទធម៌ . . លោកទ្រឹញ-វ៉ាញ អតីតៈអគ្គលេខាធិការក្រសួងធម្មការ រៀបរៀង ៨៧៩
–តើព្រះពុទ្ធសាសនាវិវត្តមកដល់ត្រឹមណា (តចប់)- លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង . . . ៨៨៤
–សំវេគកថា . . . . . . . . . ស្រី-អ៊ូ ក្រុមជំនុំព្រះត្រៃបិដក រៀបរៀង ៨៩៧

ផ្នែកអក្សរសាស្ត្រ

–សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ. . . . លោក ជាប-ពិន រៀបរៀង . . . ៩០០
–ភាសាខ្មែរ . . . . . . . . . . . លោក វ៉ាយ - ប៊ុក ប្រែរៀបរៀង . . . ៩១០
–រឿងទេវន្តរបស់អម្រិតក្សត្រី ម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ . . . . . ៩១៧
–រឿងសាមកុក (តមក) . . . . . . . . . . . ឧកញ៉ា នូ-កន ប្រែ រៀបរៀង . . . ៩២៨
–រឿងហង្សាឱត (តចប់) . . . . . . . . . លោក វ៉ាយ-ប៊ុក ប្រែ រៀបរៀង . . ៩៣១
–អំពីបងប្អូនពីរនាក់នឹងមាន់ផ្កាក់ (តមក) លោក ទៀង-វៃ-ឈុន ប្រែរៀបរៀង . . ៩៣៧

ផ្នែកកំណត់ទិនប្រវត្តិការណ៍

–ដំណើរទស្សនាការសហរដ្ឋអាមេរិកនៃព្រះតេជព្រះគុណព្រះពោធិវង្ស (តមក) . . .
លោក-ជាទន់ រៀបរៀង ៩៤៣
–ព្រះរាជដំណើរសម្ដេចព្រះឧបយុវរាជ-
ទៅកាន់កោះសិរីលង្កាក្នុងពិធីបុណ្យពុទ្ធជយន្តិ- លោក វ៉ាយ-ប៊ុក រៀបរៀង . . . ៩៤៩
–សន្និសីទនៃ បណ្ឌិត-វិស្សាទ៍ អេក្លាត ធ្វើនៅ-
ពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត (តមក) . . . . . . លោកវ៉ាយប៊ុករៀបរៀង ៩៥៥
–វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក) . . . . ព្រះមហា ចាំងខាត់ រៀបរៀង . . ៩៦០

# KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

## *TABLE DES MATIÈRES*

### *PARTIE RELIGIEUSE:*

-Appamadadharma par *M. TRINH-HOANH* . . . . . . . . . . . 879
-Où en est le Bouddhisme (suite)? traduit par *M. RAY-BUC* . . . 883
-Samvegatha par *M. SREY-OU* . . . . . . . . . . . . . . . . . . . 897

### *PARTIE LITTÉRAIRE:*

-Activité de la Commission des Mœurs et
Coutumes par *M. CHAP-PIN* . . . . . . . . . . . 900
-La langue khmère traduit par *M. RAY-BUC* . . . . . . . . . . 910
-Histoire de Devanda de *M. MOK,* (suite)
revue et corrigée par *M. NHOK-THEM* . . . . . . . 917
-Histoire de Samkok (suite) traduit par *M. NOU-KAN* . . . . . . . 925
-Histoire de Zadig (suite) traduit par *M. RAY-BUC* . . . . . . . 931
-La légende de deux frères et du coq de combat (suite)
traduit par *M. TIANG-TAY-CHHUN* . . . . . . . 937

### *NOTES ET CHRONIQUES :*

-Voyage du Vénérable HUOT-TAT aux
U. S. A. (suite) par *M. CHEA-TONN* . . . . . . . 943
-Voyage de Samdach Préah Uppayuvareach á Ceylan lors de
la fête du Buddha Jayanti par *M. RAY-BUC* . . . . 949
-Conférence du Dr. RICHARD A. GARD au Lycée
Buddhique Préah Suramarit par *M. RAY-BUC* . . . 955
-Dictionnaire Sanskrit-khmer (suite) par Vén. *PANG-KHATH* . . 960

Prix d'abonnement annuel (comprenant 12 numéros): 230$00

**ផ្នែកសាសនា**

# អប្បមាទធម៌

## លោក ទ្រឹញ-រ៉ាញ

អតីតរដ្ឋលេខាធិការក្រសួងធម្មការ

~~រៀបរៀង~~

## ប្រកួតជាប់លេខ បានទទួលរង្វាន់ ក្នុងឱកាសបុណ្យ ព.ស. ២៥០០

---

នមត្ថុ រតនត្តយស្ស

## សូមនមស្ការ ចំពោះព្រះរត្នត្រ័យ

(ដោយសេចក្ដីគោរព)

បន្ទាប់ពីបទនមស្ការនេះទៅ សូមលើកយក អប្បមាទធម៌ " សេចក្ដីមិនប្រមាទ " មកពណ៌នាដើម្បីជាគ្រឿងជួយអប់រំផងជាតិក្នុងពិភពលោក ដែលកំពុងមានសេចក្ដីស្នេហា ចំពោះប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍ប្រទេសជាតិ មាតុភូមិ រៀងរាល់រូបរាល់ជាតិ ។

បពិត្រលោក-អ្នកត្រូវការប្រយោជន៍ទាំងឡាយ !

ហេតុដែលនាំឲ្យលើកយក អប្បមាទធម៌ មកពណ៌នាលាតត្រដាងជូនក្នុងពុទ្ធសា.សនាយុកាលគំរប់ ២.៥០០ឆ្នាំ គឺពាក់កណ្ដាលព្រះពុទ្ធសា. សនានេះ ដោយយល់ឃើញថា: ធម៌នេះជាកំពូលធម៌ទាំងឡាយ ដែល

អាចញុំាងប្រយោជន៍គ្រប់យ៉ាងឲ្យសម្រេចបាន ។

អប្បមាទធម៌នេះ ចាប់តាំងពីពេលដែលព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងឡើង ក្នុងលោកកាលណា ព្រះអង្គតែងទ្រង់សំដែងប្រោសប្រទានសត្វសត្តនិករ ជាច្រើនលើកច្រើនគ្រា ដរាបទល់នឹងពេលទៀបទ្រង់ព្រះបរិនិព្វានទៀត ព្រះអង្គក៏ទ្រង់ឈ្វេងយល់ ដោយក្រែងសត្វក្នុងពិភពលោក ភ្លេចអប្បមាទធម៌នេះ ទ្រង់ត្រៀតសំដែងផ្តាំទុកផ្តាច់ ជាចុងក្រោយបំផុត ដូចមានជាប់នៅសព្វថ្ងៃនេះថា:

ហន្ទទានិ ភិក្ខវេ អាមន្តយាមិ វោ វយធម្មា សង្ខារា អប្បមាទេន សម្បាទេថ ! ម្នាលភិក្ខុទាំងឡាយ តថាគតដាស់តឿនអ្នកទាំងអស់គ្នា សង្ខារទាំងឡាយ មានការសូន្យជាធម្មតា អ្នកទាំងឡាយ ចូរញុំាងប្រយោជន៍ឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ ! ។

ក៏អប្បមាទធម៌នេះ ពិតជាធម៌ដែលព្រះសម្ពុទ្ធ ទ្រង់ពិចារណាជ្រើសរើសឃើញច្បាស់ព្រះអង្គឯងថា រកធម៌ណាអាចញុំាងប្រយោជន៍គ្រប់យ៉ាង ឲ្យសម្រេចក្នុងបច្ចុប្បន្នទាន់ភ្នែក នឹងប្រយោជន៍ក្នុងបរលោក ដូចជាអប្បមាទធម៌នេះគ្មាន ។ ព្រោះហេតុនោះហើយបានជា ព្រះសម្ពុទ្ធទ្រង់មានព្រះពុទ្ធដីកាផ្តាំទៀតថា ចូរសត្វក្នុងពិភពលោក កុំភ្លេចអប្បមាទធម៌នេះសោះឡើយ ។

ពាក្យថា: អប្បមាទធម៌នេះ ជាភាសាបាលី ប្រែចេញជាភាសាខ្មែរថា ការមិនប្រមាទ សេចក្តីមិនប្រហែសធ្វេស ។

សេចក្តីមិនប្រមាទនេះ ចែកជា ២ ផ្នែក:

១- មិនប្រមាទក្នុងការលះ;

២- មិនប្រមាទក្នុងការចំរើន ។

សូមអធិប្បាយកត់ពន្យល់សេចក្តី នៃការមិនប្រមាទទាំង ២ផ្នែក មួយម្តងដូចតទៅ ៖

១- មិនប្រមាទក្នុងការលះ បានសេចក្តីថា: អំពើណា ៗ ដែលជនជាតិប្រព្រឹត្តទៅហើយ នាំឲ្យខូចខាតផលប្រយោជន៍ផ្ទាល់ខ្លួន ទាំងប្រយោជន៍សាធារណៈជន អំពើនោះ ៗ ត្រូវតែលះបង់ចោល ដោយដាច់ខាត សូម្បីតែបន្តិចបន្តួច ក៏មិនត្រូវប្រថុយប្រព្រឹត្ត ឬប្រកបឡើយ ។

បើកាលណាជនជាតិមានសេចក្តីប្រមាទ ដោយទុកស្មានថា អំពើតិចតួចមិនជាការប៉ុន្មានទេ ហើយនៅតែខំប្រព្រឹត្តតទៅទៀត ជនជាតិនោះឯង មុខជានឹងបានទទួលលទ្ធផល ជាទុក្ខពុំខានឡើយ ។

២- មិនប្រមាទក្នុងការចំរើន បានសេចក្តីថា: អំពើណា ៗ ដែលជនជាតិប្រព្រឹត្តទៅហើយ នាំឲ្យដុះកើតផលប្រយោជន៍ទាំងសេចក្តីចំរើនរុងរឿងផ្ទាល់ខ្លួន ទាំងសាធារណៈជន ទោះបីតិច ឬច្រើនក៏ដោយ អំពើនោះ ៗ ជនជាតិត្រូវតែខំព្យាយាមបន្តសកម្មភាពទៅទៀត ពុំត្រូវធុញទ្រាន់នឿយណាយ ដោយមនោគតិ ប្រកបដោយការប្រមាទ ហើយស្មានថា: អំពើតិចតួច ពុំងាយនឹងសម្រេចអ្វីបានឡើយ ។ សូម្បីក្អមទឹក ដែលគេបើកមាត់ចំហទុកចោលកណ្តាលវាល ក៏គង់ពេញពោរទៅដោយដំណក់ទឹកភ្លៀង ដែលធ្លាក់តក់ ៗ ចុះពីអាកាសមកដែរ ។

សេចក្ដីប្រៀបធៀប នៃការមិនប្រមាទទាំងពីរផ្នែក មានកំពស់ស្មើគ្នា ។

បច្ចុប្បន្នសម័យ នៃពុទ្ធសករាជគំរប់ ២.៥០០ ព្រះវស្សានេះ ជនជាតិក្នុងពិភពលោក ស្ទើររាល់ប្រទេស បានបបួលគ្នារៀបចំធ្វើបុណ្យយ៉ាងឧឡារិក រំលឹកអាយុកាលពាក់កណ្ដាលសាសនា ។ កាលបើដូច្នេះ ជនជាតិណាក៏ដោយ ក្នុងពិភពលោក គួរតែនាំគ្នាប្រព្រឹត្តសុចរិតយុត្តិធម៌ ឲ្យបានម៉ឺងម៉ាត់ គឺត្រូវស្រឡាញ់ប្រយោជន៍ផ្ទាល់ខ្លួន និងប្រយោជន៍សាធារណៈជន ប្រយោជន៍ជាតិមាតុភូមិសាសនា មហាក្សត្រខ្លួន ព្រមទាំងជនជាតិដទៃផង មិនត្រូវបៀតបៀនញាំញីរឹបជាន់ សង្កត់សង្កិន យកផលប្រយោជន៍ អំពីគ្នាទៅវិញទៅមកដោយសារតែមានសេចក្ដីប្រមាទឡើយ ។ ប្រព្រឹត្តបែបនេះ ដើម្បីរក្សាការពារឧត្ដមប្រយោជន៍ ឲ្យបានស្ថាពរ ព្រមទាំងជួយពង្រីក ពង្រឹងសន្តិសុខ សន្តិភាព ឲ្យបានទូលំទូលាយពាសពេញសាកលលោកផង ។

អវសានកថា សូមផ្សាយសប្បុរសធម៌ គ្រប់សញ្ញាតិ សូមបានប្រកបដោយសេចក្ដីសុខ-ចំរើន ព្រមទាំងតាំងនៅស៊ប់ ក្នុងព្រះពុទ្ធសាសនា អស់កាលជានិច្ច និរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ ។

# តើព្រះពុទ្ធសាសនាវិវត្តមកដល់ត្រឹមណា?

សន្និសីទលោក វ. រាហុល ថ្លែងនៅវិទ្យាល័យ

ភវៈអាទិទេពនិយម Collège Idéologique

ឯទីក្រុងបារីស កាលពីថ្ងៃទី ១០ ធ្នូ ១៩៥៦

## លោកវ៉ាយ-ប៊ុក ប្រែពីភាសាបារាំង

## មកជាភាសាខ្មែរ

(តចប់)

ចំពោះពុទ្ធមាមកជនម្នាក់ ពួកថេរវាទនឹងពួកមហាយានថា ពួកពុទ្ធសាសនិកជនដូចគ្នាទាំងអស់ ពួកទាំងពីរទទួលជាអហង្ការ ទូទាំងព្រះបរមសមាសម្ពុទ្ធគឺចតុរារិយសច្ច, អដ្ឋង្គិកមគ្គ, បដិច្ចសមុប្បាទ ។ល។ ការដែលពួកទាំងពីរមានសភាពផ្សេងពីគ្នា បិតនៅខាងពាហិរហេតុនឹងជំនឿប្រជាមាទិត ដែលមិនមែនជាសារៈសំខាន់ ៗ បើគេបំបាត់លទ្ធិព្រះពុទ្ធសាសនាចេញ គេអាចយល់បានថា ការព្រមព្រៀងរបៀបពួកទាំងពីរជាការងាយ ៗ នៅមហាវិទ្យាល័យព្រះសង្ឃខាងលទ្ធិថេរវាទនាមថា វិទ្យាលង្ការបរិវេណ ឯទីក្រុងកូលម្ប៊ូ (ប្រទេសស៊ីឡង់) មានលោកសង្ឃខាងមហាយាន បាននិមន្តមកសិក្សារៀនសូត្រដែរ ។ លោកសង្ឃមហាយាននេះ មានបព្វជិត និងគ្រហស្ថគោរពដូចគ្នា និងលោកសង្ឃថេរវាទ ។

ពុទ្ធិកសមាគមពិភពលោក បានប្រមូលប្រជុំប្រទេសថេរវាទនិងប្រទេសមហាយាន ឲ្យបានចូលមកប្រាស្រ័យគ្នា ជាយ៉ាងជិតស្និទ្ធ ។ សមាជលើកទីពីរនៃអង្គការនេះ បានធ្វើនៅទីក្រុងតូក្យូប្រទេសជប៉ុន ពី គ.ស.១៩៥២ សមាជលើកទីបី នៅទីក្រុងរង្គូណប្រទេសភូមា គ.ស. ១៩៥៤ និងសមាជលើកទី៤ បានប្រជុំគ្នាពីខែវិច្ឆិកា១៩៥៦នៅទីក្រុងកាត្-

ម័ណ្ឌ (ប្រទេសនេប៉ាល់) ប្រទេសដែលព្រះដ៏មានព្រះភាគទ្រង់ប្រសូត ។ ខ្ញុំមានបំណងចង់បញ្ជាក់នៅទីនេះថា ប្រធានដ៏ទុកនៃពុទ្ធិកសមាគមពិភពលោកគឺលោកសាស្ត្រាចារ្យ មលៈលៈសេករៈ នៅប្រទេសសីឡង់ ហើយលោកអ្នកមុខជានឹងមានចិត្តសោមនស្ស ជាយ៉ាងក្រៃលែងដោយបានឮថា អនុប្រធាននៃអង្គការពិភពលោកនោះ មកពីក្រុងប៉ារីសៈ គឺនាងកញ្ញា លុនស្បែរ៍ ប្រធានិកានៃសមាគមមិត្តពុទ្ធសាសនាក្រុងប៉ារីស ។

ក្នុងឆ្នាំនេះ, តាំងពីថ្ងៃពេញបូណ៌មីខែវិសាខ (ឧសភា) ១៩៥៦ ទៅដល់ថ្ងៃពេញបូណ៌មី ខែពិសាខ (ឧសភា) ១៩៥៧ គឺជាឆ្នាំសំខាន់ណាស់ ក្នុងព្រះពុទ្ធសាសនាប្រវត្តិ ។ គឺឆ្នាំ ២៥០០ ក្រោយថ្ងៃដែលព្រះសម្មាសម្ពុទ្ធ ចូលបរិនិព្វាន ដែលគេសន្មតនាមថា ពិធីបុណ្យពុទ្ធជយន្តី ។

មានជំនឿមួយ ចំពោះពុទ្ធសាសនិកជនទាំងលាននាក់ តាមប្រពៃណីបុរាណថា ឆ្នាំ ២.៥០០ នៃព.ស. នាំទៅកាន់កាលសម័យមួយដែលធម៌របស់ព្រះសម្មាសម្ពុទ្ធ ផ្សាយទូទៅក្នុងពិភពលោក ព្រមទាំងថាប្រជារាស្ត្រនឹងត្រាច់ទៅកាន់សុចរិតធម៌ហើយថា សុភមង្គល នឹងសម្បូណ៌ភាពនឹងចម្រើនឡើង ក្នុងពិភពលោកនេះ ។

ពាក្យថា"ធម៌"ទ្រង់ព្រះពុទ្ធ មិនមែនជាគណៈមួយ ដែលគេបង្កើតឡើងនោះទេ, គឺជាពាក្យមានតម្លៃដូចជាសច្ចៈ សេចក្ដីស្នេហា, សេចក្ដីមេត្តា, ការមិនបៀតបៀន ការសន្ដោស គតិបណ្ឌិត ការយល់ត្រូវ, សន្តិភាព, សុខចំរើន, ការប្រោះបាត់នៃអត្តទត្តភាព, ការស្អប់ខ្ពើមអវិជ្ជា ការបរិសុទ្ធកាយវាចាចិត្ត, ។ នេះជាតម្លៃសាកលហើយ

គម្ពីរនេះ មិនបានពោលចំពោះគណៈណាសោះឡើយ ។ កាលពុទ្ធសាសនិកជនជឿជាក់ថា ឆ្នាំនេះគឺកាលសម័យ ដែលព្រះធម៌អាចផ្សាយទូទៅគ្រប់ពិភពលោកគឺថា គតិដ៏ល្អ, គុណសម្បត្តិដ៏ប្រសើរ អាចផ្សាយទូទៅគ្រប់ពិភពលោកបាន ។ ភូមិភាគដែលកាន់ព្រះពុទ្ធសាសនា ដោយអចលនៈសទ្ធា ដ៏ខ្ពង់ខ្ពស់, បានប្រុងប្រៀបរៀបចំនូវពិធីបុណ្យ ព.ស. ២៥០០ ។ គ.ស. ១៩៥០ ប្រទេសស៊ីឡង់ ហើយតាមលំដាប់មកប្រទេសភូមា មានការធ្វើពិធីបុណ្យឆដ្ឋសង្គាយនាព្រះត្រៃបិដក គឺការផ្ទៀងផ្ទាត់អត្ថបទបាលីដើម, ដើម្បីនឹងបោះពុម្ពជាសៀវភៅថ្មី ខាងពុទ្ធសាសនាព្រមទាំងសេចក្តីប្រែជាភាសាទំនើប ជាច្រើនភាសា ។ មានសមាគមចំនួនជាងមួយរយ បានរៀបចំអង្គការ ដើម្បីជួយគាំពារសីលធម៌និងវប្បធម៌ប្រជារាស្ត្រទាំងអស់ ។

ក្នុងឆ្នាំនេះ, មានពិធីបុណ្យធំៗ ដែលគេបានធ្វើនៅប្រទេស ដែលកាន់ព្រះពុទ្ធសាសនា ។ មានមនោសញ្ចេតនាខាងសាសនា មានសភាពខ្លាំងពន់ប្រមាណ បានផ្សាយទៅកាន់ប្រជាករទាំងឡាយ ។ មានការបោះពុម្ពសៀវភៅសារពត៌មាន ជាច្រើនសម្រាប់មហាជន ។ មានវិហារនិងវិមានថ្មី ជាច្រើនបានសាងឡើង សម្រាប់សកម្មភាពខាងសាសនា ។ រដ្ឋាភិបាលឥណ្ឌា បានធ្វើពិធីបុណ្យដ៏សំខាន់ក្នុងឆ្នាំនេះ ដោយសាងមហាវិមាននៃអនុស្សាវរីយ៍ នៅទីក្រុងញូវដែលី តាំងនូវស្ថាប័នពុទ្ធសាសនា ព្រមទាំងបោះពុម្ពផ្សាយ អក្សរសាស្ត្រព្រះពុទ្ធសាសនា និងធ្វើភាពយន្តពុទ្ធសាសនា ។

ព្រះបាទដាឡៃ - ឡាម៉ានិងព្រះបាទប៉ាញ់ឆែន ឡាម៉ានៃប្រទេសទីបេត៍ ដោយសេចក្តីអញ្ជើញរបស់រដ្ឋាភិបាល ទៅរួមប្រជុំ ក្នុងពិធីបុណ្យព្រះពុទ្ធជយន្តិ ប្រទេសឥណ្ឌា ក៏បានស្តេចយាងទៅកាន់ទីក្រុងញូវ-ដែល្ហី ។ ដោយសេចក្តីអញ្ជើញ នៃប្រទេសស៊ីឡង់ ពួកគណៈប្រតិភូចិន,ជប៉ុន ក៏បានអញ្ជើញទៅកាន់ប្រទេសស៊ីឡង់ ។ ដោយខ្ញុំបានដំកល់មកហើយថា ការគមនាគមន៍ រវាងប្រទេសថេរវាទ និងប្រទេសមហាយាន មានសភាពកាន់តែជិតស្និទ្ធ ។ មានការប្រឹក្សាគ្នា ដើម្បីនឹងបើកវិជ្ជាស្ថានបាលីនៅប្រទេសជប៉ុន និងប្រទេសចិន ដើម្បីនឹងសម្រួលការសិក្សា ខាងលទ្ធិថេរវាទ ។

ពីខែមុន (វិច្ឆិកា ១៩៥៦) រដ្ឋាភិបាលឥណ្ឌានិងអង្គការសហប្រជាជាតិ នៃការអប់រំវិទ្យាសាស្ត្រនិងវប្បធម៌ បានរួមប្រជុំ ដើម្បីនឹងធ្វើសន្និបាតព្រះពុទ្ធសាសនា នៅទីក្រុងញូវ ដែល្ហី ដែលមានសុមេធបុរស នៃភូមិភាគបូព៌ាប្រទេស និងបស្ចិមប្រទេស បានទទួលសេចក្តីអញ្ជើញ ក្នុងពេលនោះ ។ សន្និសីទនេះ មានវត្ថុបំណងបញ្ជាក់ពិភពលោកថា ព្រះពុទ្ធសាសនាអាចឲ្យសន្តិភាពនិងញ៉ាំងចិត្តមនុស្សឲ្យមានសេចក្តីសន្តោសគ្នា ទៅវិញទៅមកបានយ៉ាងណាខ្លះ ?

ក្នុងសម័យឥឡូវនេះ នៅក្នុងប្រទេសនៃពិភពលោក ជាប្រទេសនិយមព្រះពុទ្ធសាសនា ឬមិននិយម តែងមានចិត្តសាទរឡើងជាថ្មី ចំពោះព្រះពុទ្ធសាសនា និងវប្បធម៌នៃព្រះពុទ្ធសាសនា ។ អ្នកទាំងឡាយ បានសង្កេតឃើញស្រាប់ហើយ ក្នុងពេលថ្មីៗនេះ មានសារពត៌មានជាច្រើនរយច្បាប់នៃប្រទេសទាំងឡាយ បានផ្សាយជា

ភាសាផ្សេង ៗ នូវសេចក្ដីផ្សាយព្រះពុទ្ធសាសនា ។ ផលប្រយោជន៍សាកលនេះ កើតមានឡើង មិនមែនគ្មានវិចារណញ្ញាណនោះទេ ព្រះពុទ្ធសាសនាបាននាំមក ក្នុងសម័យបច្ចុប្បន្ន, ចំពោះពិភពលោក នូវបេសកកម្មដ៏សំខាន់ ។

ឯចំណែកខាងទ្វីបអឺរ៉ុប ក៏ដូចគ្នាពិធីបុណ្យ ព.ស. ២៥០០ ឬ ពិធីបុណ្យពុទ្ធជយន្តី បានធ្វើនៅប្រទេសជាច្រើន ។ នៅទីនេះ ឯទីក្រុងប៉ារីស, ពិធីបុណ្យនេះ ក៏បានធ្វើពីខែឧសភាមុននេះ នៅគេហដ្ឋានមហាវិទ្យាល័យ ក្រោមអធិបតីភាពសមាគម មិត្តពុទ្ធសាសនា ។ មានគណៈប្រតិភូនានាប្រទេស, ប្រជាជាតិទាំងឡាយ សាសនាទាំងឡាយ អគ្គការការទូត ទីតិសភានិងរាជ់ជាតិ បានចូលមកប្រជុំ ជាមួយផង ។ ខ្ញុំមានចិត្តសោមនស្ស ជាយ៉ាងក្រៃលែង ដោយបញ្ជាក់នៅទីនេះថា សមាគមពុទ្ធសាសនា នៅទីក្រុងប៉ារីសបានធ្វើផលប្រយោជន៍ជាច្រើន ដើម្បីផ្សាយនូវបេសកកម្មព្រះបរមសម្មាសម្ពុទ្ធ ចំពោះមហាជន ដោយហេតុនេះហើយបានជាថា សមាគមនេះ បានផ្សាយនូវមេត្រីភាព និងសេចក្ដីយល់ច្បាស់លាស់ ទៅវិញទៅមក រវាងបូព៌ាប្រទេស និងបស្ចិមប្រទេស ។

ព្រះពុទ្ធសាសនាតាំងនៅក្នុងមូលដ្ឋានពីរយ៉ាង: មេត្តានិងគតិបណ្ឌិត មេត្តាចំពោះសត្វលោកទាំងអស់ ដោយមិនរើសមុខនិងគតិបណ្ឌិត; សម្រាប់ពិនិត្យនូវធម៌ពិត-មែន ។ ព្រះពុទ្ធសាសនាជានិមិត្តរូប

នៃសទ្ធា ជាយ៉ាងជ្រាលជ្រៅ ដែលឋិតនៅ ក្នុងមនុស្សជាតិ ហើយ បានប្រគល់ចំពោះមនុស្សជាតិនេះ នូវការទទួលខុសត្រូវ ពេញលក្ខណៈចំពោះខ្លួន និងសេចក្ដីថ្លៃថ្នូររបស់ខ្លួន ។ ព្រះពុទ្ធសាសនា ធ្វើឲ្យមនុស្សជាតិត្រួតត្រាខ្លួនដោយខ្លួនឯង ។

គោលការទទួលការខុសត្រូវ ចំពោះបុគ្គលនេះឯង ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បានប្រគល់សេរីភាព ឲ្យសាវកព្រះអង្គ ។ ព្រះអង្គទ្រង់ប្រទានឱវាទ ចំពោះសាវកថា មិនត្រូវយល់តាមគេដឹកនាំទេ ព្រោះថា សាសនាពោលថា ឬ គ្រូបាអាចារ្យប្រដៅថា ត្រូវតែទទួលប្រព្រឹត្តប្រតិបត្តិតាម ដោយហេតុថា ខ្លួនយល់ជាក់ច្បាស់នូវវត្ថុនោះៗ ហើយបានពិសោធមើលជាក់ច្បាស់ថា វត្ថុនោះ មានសភាពពិតមែន ដោយខ្លួនឯងថែមទៀត ។ ព្រះអង្គទ្រង់យល់ជាក់ច្បាស់ថា បញ្ញាមនុស្ស មិនត្រូវចូលទៅជារណប នៃបញ្ញាជនដទៃ, ត្រូវតែគិតឲ្យយល់ច្បាស់ ដោយខ្លួនឯង ហើយការសម្រេចនូវសច្ចធម៌ មិនត្រូវមានបុគ្គលដទៃ ឬវិធានការ វិន័យជំនឿរទាំងឡាយ ឬ លទ្ធិណាមកបង្ខំឲ្យជឿ ដោយប្រើអំណាចហួសប្រមាណនោះទេ ។

សេរីភាពនៃចិន្ដានឹងការសន្ដោស ដែលព្រះសម្មាសម្ពុទ្ធទ្រង់ទូន្មាន ហើយ មិនដែលមានក្នុងសាសនប្រវត្តិណាឡើយ ។

កាលមួយថ្ងៃ មានបុរសម្នាក់ជាអ្នកមានទ្រព្យសម្បត្តិ ព្រមទាំងជាទីពឹងនៃប្រជារាស្ត្រ នាមថា ឧបលិ ដែលជាសាវកនៃនិគ្គន្ថនាថបុត្ត (ដៃនៈមហាវិហារ) បានបញ្ចេញវាចា បំណងចង់សុំធ្វើឧបាសកនៃព្រះ

សម្តេច ។ តែព្រះសម្តេចទ្រង់មានព្រះបន្ទូលទៅកាន់ឧបលីថា: ចូរអ្នកពិចារណាឲ្យម៉ត់ចត់សិន ក្នុងរឿងនេះ ហើយកុំប្រញាប់ប្រញាល់ពេក ៗ

លុះឧបលីបានបញ្ចេញវាចាជាថ្មីម្តងទៀត, ព្រះដ៏មានព្រះភាគទ្រង់យល់ព្រម ឲ្យឧបលីចូលមកធ្វើឧបាសកបាន, ហើយទ្រង់ទូន្មានថា កុំលះបង់ការគោរព និងកិច្ចជួយឈឺឆ្អាល ចំពោះគ្រូចាស់របស់ខ្លួន ដូចពីកាលមុនមក ៗ

កាលពីសតវត្សរ៍ទី៣មុន គ.ស. ព្រះបាទអធិរាជ, ព្រះអសោកនៃប្រទេសឥណ្ឌា ព្រះអង្គបានកាន់ពុទ្ធសាសនា បានប្រើព្រះរាជនយោបាយ ដើម្បីនឹងផ្សាយព្រះពុទ្ធសាសនា ទៅក្នុងពិភពលោកទាំងមូល ដោយកាន់ព្រះរាជហឫទ័យសន្តោស និងការយោគយល់គ្នាទៅវិញទៅមក គោរពសាសនាដទៃទៀត នៅក្នុងអាណាប្រទេសរបស់ព្រះអង្គ ។ នៅលើព្រះរាជតម្រាស ដែលឆ្លាក់ក្នុងសិលាព្រះអធិរាជ ទ្រង់បានប្រកាសថា: “គេមិនត្រូវគោរពសាសនារបស់ខ្លួន ហើយប្រមាថមើលងាយសាសនាអ្នកដទៃ ដោយយកសទ្ធា ចំពោះសាសនារបស់ខ្លួនទេ ; ធ្វើយ៉ាងនេះឈ្មោះថា ធ្វើឲ្យអាប់ឱនដល់សាសនារបស់ខ្លួន ; ព្រោះហេតុដូច្នេះ ការព្រមព្រៀងគ្នា ត្រូវតែលៃលកឲ្យបានស្រួល ព្រោះថា: អ្នកទាំងអស់ត្រូវស្តាប់ ឬ ត្រូវចង់ស្តាប់លទ្ធិរបស់ជនដទៃ” ។

ខ្ញុំចង់បន្ថែមថា: “ការប្រព្រឹត្តិប្រតិបត្តិតាមព្រះពុទ្ធសាសនា ក្នុងការយោគយល់គ្នាទៅវិញទៅមក ដោយសមានចិត្ត ត្រូវតែយកមកអនុវត្ត ក្នុងសម័យបច្ចុប្បន្ន មិនត្រឹមតែលទ្ធិសាសនាទេ ថែមទាំងលទ្ធិជាតិ

និយមនយោបាយ សង្គមនិងសេដ្ឋកិច្ច" ។

អ្នកជ្រាបស្រាប់ហើយថា តាំងតែពីបឋមសតវត្សទី ១៦ ពួកពទុយហ្គេស បានមកតាំងនៅតាមខែត្រមាត់សមុទ្រ ប្រទេសសីឡុង៍ អស់រយៈពេលមួយសតវត្ស ។ ពួកពទុយហ្គេសជាពួកអធិមុត្តខាងសាសនាកាតូលិក ហើយក៏ធ្វើទារុណកម្ម ដល់ពួកពុទ្ធមាមកជនប្រទេសស៊ីឡុង៍ ដើម្បីបង្ខំពួកនេះ ឲ្យចូលទៅក្នុងសាសនារបស់ខ្លួន; ពួកពទុយហ្គេសនេះ ទៅជាប្រព្រឹត្តបទឧក្រិដ្ឋយ៉ាងកាចសាហាវ ។ លុះជាប់តមក នៅកណ្ដាលសតវត្សទី ១៧ ពួកជនជាតិហុល្លង់ ដែលកាន់សាសនាប្រូតេស្តង់ បានមកធ្វើសង្គ្រាមនឹងពួកពទុយហ្គេសមានជោគជ័យ ក៏មកបតនៅតាមខែត្រមាត់សមុទ្រ ហើយក៏ធ្វើទារុណកម្ម ចំពោះពួកជនជាតិពទុយហ្គេស ដែលកាន់សាសនាកាតូលិក ។

ពួកពទុយហ្គេស ក៏បានទៅក្រាបបង្គំគាល់ព្រះមហាក្សត្រ ប្រទេសសីឡុង៍ សូមឲ្យទ្រង់ជួយទំនុកបម្រុងផង ។ ព្រះមហាក្សត្រទ្រង់ជាអ្នកកាន់ព្រះពុទ្ធសាសនា ទ្រង់បានជ្រាបច្បាស់លាស់ អំពីទារុណកម្ម ដែលពួកពទុយហ្គេស បានធ្វើចំពោះពួកពុទ្ធសាសនិកជន នៅខែត្រមាត់សមុទ្រ តែទ្រង់មានបារមីធម៌ និងមហាសប្បុរសធម៌ ទ្រង់ភ្លេចនូវរឿងរ៉ាវទាំងនោះ ហើយក៏អត់ទោសទាំងអស់ មានព្រះរាជឱង្ការថា: ចូរអ្នកអញ្ជើញមកចុះ សាងព្រះវិហាររបស់អ្នក, ចូរអ្នកប្រព្រឹត្តប្រតិបត្តិ តាមសាសនារបស់អ្នក នៅក្នុងព្រះរាជអាណាចក្ររបស់ខ្ញុំ ដោយសន្តិសុខចុះ ។

ក្នុងពេលឥឡូវនេះ, នៅក្នុងវត្តពុទ្ធសាសនាប្រទេសស៊ីឡង់, មានពួកនិស្សិតក្រៅជាតិ នឹងមហាមាត់បិតនៅសិក្សារៀនសូត្រ នឹងបព្វជិតខាងពុទ្ធសាសនា ។ ខ្ញុំបាននឹកឃើញថា នៅវិទ្យាល័យវិទ្យាលង្កាដែលខ្ញុំបានពោលមកហើយ, យើងមាននិស្សិតមួយ កាន់សាសនាកាតូលិក នៅគង់ក្នុងវត្តនោះ រាល់ថ្ងៃអាទិត្យ ពេលព្រឹក ចៅអធិការវត្តបានស្រែកហៅយុវ៉ននោះ ហើយលោកញញឹម មានពុទ្ធដីកាថាៈ "លេវ (នេះគឺនាមយុវ៉ន) ឥឡូវនេះជាថ្ងៃអាទិត្យ អ្នកត្រូវទៅព្រះវិហារឬ!" ។

បំណែកឯជនជាតិស៊ីឡង់ កាន់សាសនា កាតូលិក ដែលរស់នៅក្នុងបរិវេណពុទ្ធសាសនាច្រើន មានចិត្តសន្ដោស ជាងពួកកាតូលិក នៃប្រទេសឯទៀត ។ ឧទាហរណ៍, ដូចជាកាលពួកកាតូលិក បានអញ្ជើញខ្ញុំម្ដង មកធ្វើសន្និសីទ ។ ខ្ញុំមិនបានពិណនាពីព្រះពុទ្ធសាសនាទេ, ខ្ញុំពោលពីគ្រិស្តសាសនាដោយពន្យល់អំពីការសិក្សាព្រះយេស៊ូគ្រិស្ត តាមគម្ពីរដែលខ្ញុំបានអានជាច្រើនផង ដោយសេចក្ដីគោរព ។ មានពេលខ្លះ, មានលោកសង្ឃ ខាងគ្រិស្តសាសនា ត្រូវគេនិមន្តមកកាន់ពិធីបុណ្យនៃពុទ្ធសាសនា ។

ការសន្ដោសនឹងសមានចិត្ត ប្រកបដោយសេចក្ដីយោគយល់គ្នា ទៅវិញទៅមក ដែលមានមេត្តាសាកលនឹងគតិបណ្ឌិតជាយ៉ាងជ្រាលជ្រៅ ជាមូលដ្ឋាន ជាឧត្តមគតិមួយនៃវប្បធម៌ នឹងអារ្យធម៌ព្រះពុទ្ធសាសនា តាំងពីបឋមសម័យរហូតមកដល់បច្ចុប្បន្នសម័យ ។ ព្រោះហេតុដូច្នេះពិតមែនតែព្រះពុទ្ធសាសនាផ្សាយទូទៅក្នុងទ្វីបអាស៊ីដោយសន្តិវិធី ហើយបាន

ប្រមូលសាវ័ក ក្នុងពេលឥឡូវនេះ បានចំនួនជាង ៥០០ លាននាក់ គេមិន ដែលជួបប្រទះនូវករណីណាមួយ ខាងតារុណកម្មសាសនា ឬឈាមមួយ ដំណក់ធ្លាក់ដល់ដី ក្នុងនាមព្រះពុទ្ធសាសនា ចំពោះពុទ្ធប្រវត្តិ ដែលមាន មកតាំងពី ២៥ សតវត្សរ៍ ។

ព្រះពុទ្ធសាសនា មានសភាពប្រកប ដោយវិចារណញ្ញាណនឹង លក្ខណៈទំនើប បានព្រមព្រៀងទទួលនូវវឌ្ឍនភាពខាងសង្គម, សេដ្ឋកិច្ច, បញ្ញា, វិមុត្តិ ។ ព្រះបរមពុទ្ធោវាទដ៏សំខាន់ គឺជាវត្ថុទាំងអស់មិនទៀង ហើយមានសភាពប្រែប្រួលជាធម្មតា ។ ព្រោះហេតុដូច្នេះ, ការប្រែប្រួល ខាងសង្គម, នយោបាយ, សេដ្ឋកិច្ច ឬវត្ថុឯទៀត, ចំពោះព្រះពុទ្ធសាស-នា ជាឧប្បាទធម៌ធម្មតា ។ សរុបទៅថា វឌ្ឍនភាព គឺការប្រែប្រួល, ការចលនា ហើយមានសភាពមិនឋិតថេរ ។ ចំណែកខាងចំណុចៈសេដ្ឋកិច្ច នយោបាយ ក៏ដូចគ្នា ព្រះពុទ្ធសាសនាជាសាសនា ប្រកបដោយសម័យ បច្ចុប្បន្ន ។

គេបានយល់ព្រមអនុមតិជាសាកលថា ដើម្បីនឹងឲ្យចម្រើនសុក-មង្គល នឹងសីលធម៌នៃប្រជាពលរដ្ឋ, ជីវភាពសេដ្ឋកិច្ចប្រជាពលរដ្ឋនេះ ត្រូវតែលើកតម្កើងជាអធិការ ។ តាំងពី ២៥ សតវត្សរ៍មកហើយ, ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះរាជទានព្រះឱវាទថា អ្នកកាន់កាប់ប្រទេសបាន ពិសោធចង់បំបាត់បទឧក្រិដ្ឋ ដោយធ្វើទណ្ឌកម្ម ចំពោះអ្នកប្រព្រឹត្តបទនេះ ហើយជាកិច្ចមិនបានការ ព្រោះថា ដើម្បីបំបាត់នូវបទឧក្រិដ្ឋ, ព្រមទាំងតម្កើងនូវសីលធម៌បុគ្គលនោះ, ត្រូវធ្វើស្ថានភាពខាងសម្ភារៈនៃបុគ្គល

នោះ ត្រូវបានបម្រើនតាមលំដាប់ ។

ពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ទេសនា ចំពោះគ្រហស្ថ មាន សុភមង្គល ៤ យ៉ាង គឺ ១. សន្តិភាពសេដ្ឋកិច្ច; ២. គ្មានបំណុល; ៣ .សិទ្ធិ ប្រើប្រាស់នូវមធ្យោបាយ ចិញ្ចឹមជីវិត បានដោយសេរី; ៤ .បំពេញ ជីវភាពប្រកបដោយគុណធម៌ វៀរលែងនូវបាបអកុសលទាំងអស់ ។ យើងសូមរំលឹកនៅទីនេះថា បើតាមព្រះពុទ្ធសាសនា លក្ខគោលទាំង ពីរ សម្ភារៈនិងប្រាជ្ញាជាការចាំបាច់ ដើម្បីឲ្យកើតសុភមង្គលដល់មនុស្ស. ជាតិ ។ ចំណែកខាងបព្វជិត ក៏ដូចគ្នា, ដើម្បីនឹងធ្វើសមាធិកម្មដ្ឋាន ឲ្យបានពេញលេញ ប្រកបដោយសប្បាយគ្រប់យ៉ាង ត្រូវតែមានទ្រព្យ សម្បត្តិគ្រប់គ្រាន់ ។ គឺជាការគួរសរសើរថា ព្រះពុទ្ធសាសនាដែលជា សាសនា ប្រកបដោយសីលធម៌ នឹងប្រាជ្ញាមិនបានភ្លេចនូវសារៈសំខាន់ នៃមូលដ្ឋានសេដ្ឋកិច្ច ។ មានមួយថ្ងៃ ព្រះអនាវញ្ញាណ ទ្រង់សំដែង ថា បាបអកុសលធំជាងគេ គឺការស្រេកឃ្លាន ហើយព្រះអង្គក៏ឈប់ បង្អង់មិនបានទេសនា, ទាល់តែមានមនុស្សម្នាក់អត់អាហារ បានអាហារ បរិភោគ, ទើបព្រះអង្គទេសនាតទៅទៀត ។

នៅទីនេះ យើងត្រូវរលឹកថា បើតាមព្រះពុទ្ធសាសនា យសស័ក្តិ ជាមធ្យោបាយ ដើម្បីទៅកាន់វត្ថុបំណងមួយ ។ ទ្រព្យសម្បត្តិមិនមែន សម្រាប់ឲ្យយកមកគរទុកទេ គឺសម្រាប់ឲ្យប្រើប្រាស ។ ការប្រមូលនូវ យសស័ក្តិដោយសេចក្តីលោភ ប្រកបដោយអត្តទត្តភាព ក៏ព្រះអង្គមិនឲ្យធ្វើ ដែរ ការបែងចែកភោគទ្រព្យ ជាប្រយោជន៍ទាំងអស់គ្នា,ព្រះអង្គសរសើរ ៗ

ខ្ញុំបានពោលមកហើយថា ព្រះពុទ្ធសាសនាជាកត្តាវ៉ាន់ជាតិនៃទ្វីបអាស៊ី ហើយមានអានុភាពធំ ចំពោះទ្វីបនេះខាងភូមិភាគអគ្នេយ៍ ។ ព្រះពុទ្ធសាសនាជាជំនួយចំពោះជីវភាពថ្មីនៃសង្គម, នយោបាយសេដ្ឋកិច្ច ដែលកាន់តែបញ្ចេញរូបរាងទ្រង់ទ្រាយជាក់ស្តែងនៅទ្វីបនេះ ។

ក្រោយដែលប្រទេសទាំងឡាយ នៃភូមិភាគអគ្នេយ៍ទ្វីបអាស៊ី បានឯករាជ្យ ប្រទេសនេះច្រើនមាននិន្នាការទៅកាន់លទ្ធិសង្គមនិយម ដែលចម្រើនផុះដាលនៅភូមិភាគនេះ ។ លទ្ធិសង្គមនិយមនេះ មានសភាពដូចគ្នានឹងលទ្ធិសង្គមនិយម នៃប្រទេសស្កង់ឌីណាវ (ប្រទេសស៊ុយអែត នរវែស, ដាណឺម៉ាកជាដើម) ។ លទ្ធិសង្គមនេះ ដែលនឹងចម្រើនរុងរឿងបាន នៅទីនេះ ដោយសារព្រះពុទ្ធសាសនា ។

ខ្ញុំអាចជូនដោយជាក់ស្តែង នូវឧទាហរណ៍មួយៈ– លោកអ្នកប្រហែលជាបានជ្រាបស្រាប់ហើយ, នូវរដ្ឋាភិបាលសង្គម តាំងពីខែមេសា ១៩៥៦ ។ ដែលមាននៅប្រទេសសិរីលង្កា រដ្ឋាភិបាលអតីតៈជារដ្ឋាភិបាលអភិរក្ស និងមូលធននិយម ។ គង់ពេលបោះឆ្នោតជ្រើសរើសដំណាងរាស្ត្រ មានពួកភិក្ខុសង្ឃជាច្រើនពាន់អង្គ បាននិមន្តចេញពីវត្តអារាមស្ងាត់ ដើម្បីមកប្រជុំ ជាសាធារណៈ ។ លោកមានពុទ្ធដីការថា រដ្ឋាភិបាលអតីតៈ ជារដ្ឋាភិបាលប្រកបដោយបដិកម្ម ព្រមទាំងមូលធននិយម ហើយមិនអាចធ្វើប្រទេសឲ្យឡើងទៅកាន់វឌ្ឍនភាពបានទេ ។ ព្រោះហេតុដូច្នេះ យើងត្រូវតែបោះបង់ចោលនូវរដ្ឋាភិបាលនេះ ហើយត្រូវជ្រើសរើសរករដ្ឋាភិបាលផ្សេងទៀត ទៅជារដ្ឋាភិបាលសង្គមនិយម ឬ ចម្រើនជាតិ

ដែលនាំឲ្យបានផលដ៏ប្រសើរ ដល់ពួកប្រជាករទាំងឡាយ ។

រដ្ឋាភិបាលនោះ ក៏ធ្លាក់ទៅក្នុងបរាជ័យ ហើយគេបានជ្រើសតាំងនូវរដ្ឋាភិបាលសង្គមនិយមនិងចម្រើនជាតិមួយ ដោយមតិភាគច្រើន ។ ប្រហែលជាមានវិចារណញ្ញាណក៏ផ្សេងទៀត ចំពោះការប្រែប្រួលរដ្ឋាភិបាលនេះ, តែវិចារណញ្ញាណនោះ ជាការក្រៅអត្ថបទសន្និសីទរបស់យើង ។

រដ្ឋាភិបាលអតីតៈ ជារដ្ឋាភិបាល មានឥទ្ធានុភាព ។ គ្មានអ្នកណាអាចដឹងបានថា រដ្ឋាភិបាលនេះទទួលបរាជ័យទេ ។ លោករដ្ឋមន្ត្រីទីមួយគិតថា គណៈបក្សខ្លួនប្រហែលជាបាន,យ៉ាងតិចត្រឹម ៧០ % ក្នុងចំណោមតំណាងរាស្ត្រទាំងអស់, ត្រឡប់ទៅជាបានតែ ៨ % ។ ក្នុងពេលសម័យជ្រើសតាំងនោះ គ្មានចលាចលវឹកវរអ្វីសោះឡើយ ។ គេបោះឆ្នោតដោយចិត្តស្ងប់ស្ងៀមជាយ៉ាងស្រួល ។ រដ្ឋាភិបាលមូលធននិយម មានឥទ្ធានុភាពជាង ដែលកាន់កាប់ពង្ការយូរមកហើយ ទៅជាលំ ៗ ប្រទេសស៊ីឡង់បានបង្ហាញចំពោះនានាប្រទេស គ្រប់ឧទាហរណ៍មួយជាយ៉ាងជាក់ស្តែង ។ យើងមិនត្រូវភ្លេចថា ប្រជារាស្ត្រនៃប្រទេសស៊ីឡង់, បុរស ឬស្ត្រី បាននិយមប្រើវិធីបោះឆ្នោតសាកល ក្នុងរយៈវេលាម្ភៃប្រាំឆ្នាំមកហើយ ។

ខ្ញុំយល់ថា ការប្រែប្រួលនេះដែលធ្វើដោយសន្តិវិធី នៅប្រទេសស៊ីឡង់បានផលដ៏សំខាន់ ព្រោះថា វប្បធម៌ពុទ្ធសាសនា មានអានុភាពទៅក្នុងជីវភាព នៃប្រជារាស្ត្រនៅលើកោះនេះ អស់រយៈវេលា ជាងម្ភៃប្រាំសតវត្សរ៍មកហើយ ។

ព្រះសង្ឃខាងពុទ្ធសាសនា, នៅពេលបើកសម័យបោះឆ្នោត, មានព្រះពុទ្ធដីកាថា ប្រទេសស៊ីឡង់ ត្រូវត្រឡប់ទៅកាន់សាធារណរដ្ឋសង្គមឯកភាព ហើយត្រូវតែបំណងសង្គមទាំងអស់ ត្រូវតែសម្រេចដោយប្រើមធ្យោបាយប្រកបដោយសន្តិវិធី ។

ខ្ញុំបានពោលមកហើយ អំពីប្រវត្តិសាស្ត្រនៃកោះតូចនេះ ដើម្បីបង្ហាញលោកអ្នក នូវអាកប្បកិរិយា នៃព្រះពុទ្ធសាសនា ចំពោះបញ្ហាសង្គម, សេដ្ឋកិច្ច, នយោបាយ ។

សេចក្តីសង្ខេបនេះ នឹងអាចបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាបានបើកដោយសេរី ចំពោះទម្រង់ទាំងអស់នៃវឌ្ឍនភាពខាងចិត្ត, សីលធម៌ប្រាជ្ញា សង្គមនិងសេដ្ឋកិច្ច ហើយមានករណីយកិច្ច ដ៏សំខាន់បំផុតដែលត្រូវបំពេញក្នុងការសាងពិភពលោក ទៅអនាគត ។ តែព្រះពុទ្ធសាសនា នឹងធ្វើយ៉ាងណាទៅ ?

គេត្រូវដាក់ចំពោះប្រជារាស្ត្រនូវនាមថា "ពុទ្ធសាសនិកជនថ្មី" ។ មិនមែនដូច្នោះទេ ។ នាមថា ពុទ្ធសាសនិកជន, គ្រិស្តសាសនិកជន, មហាមត្តសាសនិកជនឬហិណ្ឌូមិនមានតម្លៃទេ ។ កិច្ចការដ៏ប្រសើរនេះ នឹងអាចធ្វើបាន ត្រូវបញ្ចូលទៅក្នុងអធ្យាស្រ័យមនុស្ស នូវសភាពពិតប្រាកដ ព្រមទាំងសេចក្តីបរិសុទ្ធនៃការមេត្តាជាសាកល ប្រកបដោយសន្តិភាព, ចិត្តសន្តោសនិងគតិបណ្ឌិតជាបរិយោសាន ។

សំវេគគាថា

ពុទ្ធភាសិតជាសារវន្ត

ក្នុងគម្ពីរធម្មបទដ្ឋកថា

ស្រី-អ៊ូ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

## រឿងដើមនៃពុទ្ធភាសិត

ដំណាលអំពីស្ត្រីម្នាក់ឈ្មោះនាងបដាចារា នៅជិតក្រុងសាវត្ថី ដែលត្រូវសេចក្ដីទុក្ខជាទម្ងន់គ្របសង្កត់ គឺទុក្ខអំពីកូន ១ ត្រូវសត្វខ្លែងឆាបយកទៅ, កូន ១ ត្រូវទឹកជំនន់ក្បួចលិចស្លាប់ ក្នុងស្ទឹងអចិរវតី, មាតាបិតា ទាំងបងប្រុសរបស់នាង ត្រូវផ្ទះរលំសង្កត់ស្លាប់អស់ ៗ នាងបដាចារាត្រូវសេចក្ដីទុក្ខបែបនេះគ្របសង្កត់ ក៏វង្វេងភាន់ស្មារតី ពេលមួយបានជួបព្រះបរមគ្រូ, ព្រះអង្គសំដែងពុទ្ធភាសិត ពន្យល់ឲ្យស្ដាប់, លុះចប់ពុទ្ធ-ភាសិតហើយ, នាងបដាចារា ក៏ស្បើយសេចក្ដីទុក្ខសោក បានសម្រេចសោតាបត្តិផល មិនតែនាងបដាចារាមួយប៉ុណ្ណោះទេ សូម្បីពួកជនដទៃជាច្រើន ដែលអង្គុយស្ដាប់ជាមួយផងនោះ ក៏បានសម្រេចសោតា-បត្តិផលដូចគ្នាដែរ ហេតុនេះហើយបានជា ខ្ញុំដកស្រង់ពុទ្ធភាសិតនោះមកអធិប្បាយដូចតទៅ ៖

ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ

និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។

ប្រែថា: បណ្ឌិតដឹងច្បាស់នូវអំណាចនៃហេតុនេះថា "កូនទាំងឡាយមិនមាន ដើម្បីទីពឹង បិតាក៏មិនមាន ដើម្បីទីពឹង ជនជាផៅពង្សទាំងឡាយក៏មិនមាន ដើម្បីទីពឹងបានដែរ បុគ្គលកាលបើត្រូវសេចក្ដីស្លាប់គ្របសង្កត់ហើយ ក៏មិនមានទីពឹងចំពោះញាតិទាំងឡាយឡើយ" គប្បីសង្រួមសីល ជម្រះផ្លូវសម្រាប់ទៅកាន់ព្រះនិព្វាន យ៉ាងឆាប់រួសរាន់ ។

## សេចក្ដីអធិប្បាយ :

បុគ្គលគួរពិចារណានូវសេចក្ដីសង្វេគឲ្យឃើញច្បាស់ថា ជនទាំងឡាយដែលកើតមកក្នុងលោកនេះ រកទីពឹងពំនាក់ឲ្យមាំមួននោះពុំមាន សុទ្ធតែជាអ្នកកំព្រាម្នាក់ឯង ទោះបីមានមាតា បិតា ស្វាមី ភរិយា បុត្រ ធីតា ញាតិសន្តាន ផៅពង្ស មិត្រសំឡាញ់ ទ្រព្យសម្បត្តិ ច្រើនគរគោក ក៏ដូចជាគ្មាន ព្រោះថា ជនទាំងឡាយមានមាតាបិតាជាដើមនោះ មិនអាចនឹងជួយការពារតទល់នូវមរណសង្គ្រាម ដែលដំរង់ចំពោះរូបនីមួយៗនោះបានឡើយ។ បើមរណសង្គ្រាមដៅដំរង់មករូបបុគ្គលណាហើយ បុគ្គលនោះជាអ្នកកំព្រាឥតគ្នីគ្នាឡើយ បើបានជួបប្រទះនូវសេចក្ដីទុក្ខ ដែលកើតអំពីអកុសលកម្ម ដែលខ្លួនធ្វើហើយ ក្នុងពេលមុននោះ ក៏ត្រូវតែទទួលយកនូវសេចក្ដីទុក្ខនោះភ្លាម ឬ បើជួបប្រទះនូវសេចក្ដីសុខ ដែលជាលទ្ធផល នៃកុសលកម្ម ដែលខ្លួនបានកសាងល្អមកហើយ ក្នុងពេលមុននោះ ក៏ត្រូវទទួលយកនូវសេចក្ដីសុខនោះ ចំពោះខ្លួនមួយប៉ុណ្ណោះ មិនអាចចែកគ្នីគ្នាបានឡើយ ។

កាលបើបានពិចារណាឃើញច្បាស់ដូច្នេះហើយ គឺនឹងយល់ច្បាស់ថា មនុស្សសត្វ ប្រុសស្រីទាំងអស់ នឹងរកគ្រឿងទីពឹងពុំនាក់ឲ្យមាំមួននោះ ពុំមានឡើយ ឃើញតែគុណទាំងឡាយ មានគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ និងទានសីលភាវនា ជាដើមនេះឯង ទើបជាទីពឹងដ៏វិសេស អាចជួយឧបត្ថម្ភគាំពារទំនុកបំរុង ក្នុងកាលដែលមរណសង្គ្រាម មកផ្ដាច់ផ្ដិលនូវជីវិតិន្ទ្រិយ របស់សត្វទាំងពួងនោះ ឲ្យបានសុខស្រួលរៀងរាបដរាបទៅដល់លោកខាងមុខទៀតបាន ។

ដូច្នេះ គួរសង្រួមសីល ដំរះសំអាតផ្លូវទៅកាន់ព្រះនិព្វាន ។

ឯផ្លូវសម្រាប់ទៅកាន់ព្រះនិព្វាននោះ មាន ៨ យ៉ាងគឺ

១– សេចក្ដីយល់ត្រូវ,

២– សេចក្ដីត្រិះរិះត្រូវ,

៣– ការពោលពាក្យត្រូវ,

៤– ធ្វើការងារត្រូវ,

៥– ការចិញ្ចឹមជីវិតត្រូវ,

៦– ការព្យាយាមត្រូវ,

៧– សេចក្ដីរឭកត្រូវ,

៨– ការតាំងចិត្តឲ្យនឹងធឹងត្រូវ ។

ចប់សេចក្ដីអធិប្បាយពុទ្ធភាសិតផាសាវវត្តត្រឹមប៉ុណ្ណេះ ។

## ផ្នែកអក្សរសាស្ត្រ

សកម្មភាពនៃក្រុមជំនុំទំនៀមទម្លាប់ខ្មែរ

# នៅពុទ្ធសាសនបណ្ឌិត្យ

### បរិយាយរំពី "ស្ត្រីភាព"

### លោក ប៉ាប.ពិន រៀបរៀង

---

ពាក្យថា "ស្ត្រី" ដែលខ្មែរយើងធ្លាប់ប្រើជាឈ្មោះមនុស្សស្រីនោះ ជាពាក្យសាមញ្ញប្រើក្លាយមកពី ស្ត្រី ជានាមសព្ទ ភាសាសំស្រ្កឹត គឺជាឈ្មោះភេទនៃមនុស្ស ១ ពួក ដែលទីទៃពីបុរស ពីខ្ទើយ ។ ភាសាបាលីថា "ឥត្ថី" ប្រែតាមវចនានុក្រមខ្មែរថា "មនុស្សដែលបុរសគួរចង់បាន, ដែលជាគូនឹងបុរស" ។ មនុស្សភេទនេះ បើហៅឲ្យចំតាមដើមកំណើតភាសា គឺត្រូវហៅថា "ស្ត្រី" ។

ពាក្យថា "ស្រី" មួយម៉ាត់ទៀត ដែលខ្មែរយើងធ្លាប់ប្រើរួមពីខាងដើមសព្ទដទៃ ដូចជាស្រីសួស្តី, ព្រះស្រីសពេជ្ញ, រាជសព្ទថា ព្រះស្រីដីប (ស្វាចៀក) ព្រះស្រីចុណ្ណ (ស្វាបុក) ជាដើម នោះជានាមសព្ទ ភាសាសំស្រ្កឹត ។ ភាសាបាលីថា សិរី ប្រែថា សួស្តី មង្គល ជោគ សេចក្តីសុខ សេចក្តីចំរើន បុណ្យ ភ័ព្វ ព្រេងសំណាង អំណាច តេជៈ ។

ពីនេះ ខ្ញុំសូមលើកយកតែភេទ និងករណីរបស់ស្ត្រីមកអធិប្បាយ ដូចតទៅ :

ភេទរបស់ស្ត្រី : តាមធម្មជាតិ ជាភេទខ្សោយ សាច់ទន់ជ្រាយ កាយទន់ភ្លន់ ចិត្តទន់ឆាប់ខឹង ឆាប់ជា, ផ្ទុយពីភេទបុរសដែលជាភេទខ្លាំង សាច់រឹង កាយរឹងប៉ឹង ចិត្តរឹង ក្រខឹង ក្រជា ។

រឿងខ្សោយនិងខ្លាំងនេះ មិនតែជាភេទមនុស្សជាស្ត្រីជាបុរសទេ សូម្បីតែភេទសត្វជាញីជាឈ្មោលក៏ដូចគ្នា ។

ករណីរបស់ស្ត្រី : ធម្មជាតិតាក់តែងស្ត្រីមក សម្រាប់ធ្វើជាមាតារបស់លោក សម្រាប់ចិញ្ចឹមបុត្រធីតា ថែរក្សាគ្រឹះស្ថាន និងទ្រព្យសម្បត្តិ ។

តាំងពីដើមបឋមកប្បមក មនុស្សក្នុងលោកគ្រប់តែប្រទេសគេនិយមទុកស្ត្រីឲ្យនៅតាមធម្មជាតិដើម គឺគេមិនឲ្យពួកស្ត្រីធ្វើការធ្ងន់ ជាការប្រើកម្លាំងខ្លាំងៗ ដូចលើកដាក់ លីសែង កាប់គាស់ កាប់ដំ ច្បាំងកាំងជល់ ជាដើមទេ, ភារៈទាំងនេះ គេទុកជាភារៈខាងពួកបុរស, ឯពួកស្ត្រីគេប្រើតែការស្រាលៗ ដូចស្ទូងដណ្ដាំ ដេរដុលប៉ាក់ ថែទាំកូនចៅជាដើម ដែលរួមយ៉ាងខ្លីគឺបុរសៗជាអ្នកធ្វើការព្រៃ ស្ត្រីធ្វើការផ្ទះ ។

សម័យបុរាណ ប្រទេសខ្លះគេជួមពួកស្ត្រីដល់ទៅយកសំពត់រុំជើងតាំងពីតូចៗ ដើម្បីមិនឲ្យដើរឆ្ងាយពីផ្ទះ ជាការទប់ភេទស្ត្រីឲ្យនៅតាមធម្មជាតិ, ប៉ុន្តែឥឡូវ ប្រពៃណីនេះរលុបបាត់អស់ទៅហើយ ។

ប្រទេសខ្មែរយើង ក៏បណ្ដោយពួកស្ត្រីឲ្យប្រព្រឹត្តទៅតាមធម្មជាតិ

ដើមដែរ, សម័យបុរាណអ្នកស្រុកមិនឲ្យពួកស្ត្រីរៀនអក្សរទេ, គេនិយាយបន្តបន្ទាប់គ្នាថា "មិនត្រូវឲ្យស្ត្រីរៀនអក្សរ ព្រោះរៀនចេះទៅនឹងសរសេរសំបុត្រទៅប្រុស តាមអំពើចិត្ត" ។ ពាក្យបន្ទាប់នេះបានញុំាងស្ត្រីខ្មែរច្រើនភាគរយមិនឲ្យចេះអក្សរ, ប៉ុន្តែសម័យបច្ចុប្បន្ន ពាក្យបន្ទាប់នេះរលុបរលាយបាត់ជិតអស់ទៅហើយ, គេត្រឡប់ជាប្រាប់គ្នាថា ត្រូវតែឲ្យស្ត្រីរៀនអក្សរគ្រប់គ្នាទៅវិញ ទើបប្រទេសជាតិបានសេចក្តីរុងរឿងចំរើន ។

ពិតមែនតែធម្មជាតិគាត់តែងឲ្យស្ត្រីមានភេទខ្សោយ សាច់ទន់ជ្រាយ កាយមិនរឹងប៉ឹង ចិត្តទន់ ប៉ុន្តែស្ត្រីអាចបង្ហាត់កាយរបស់ខ្លួនតាមក្បួនអនាម័យអត្តពលកម្មឲ្យរឹងប៉ឹង ឲ្យរហ័សរហួន, អប់រំចិត្តតាមក្បួនសិក្សាឲ្យមានប្រាជ្ញាវាងវៃប៉ិនប្រសប់លើសធម្មតាបាន មិនអន់ជាងបុរសប៉ុន្មានទេ ចួនកាលមានគ្រាន់បើជាងបុរសខ្លះដោយអទៀតផង បើប្រសិនជាគេព្យាយាមហ្វឹកហាត់នឹងអប់រំម៉ឺងម៉ាត់មែនទែន ។

ការហ្វឹកហាត់អប់រំកាយចិត្តរបស់ស្ត្រីអាចឃើញលទ្ធផលជាក់ស្តែង ដូចនិទានទាំងអតីតកាលនឹងបច្ចុប្បន្នកាលដែលនាំមកបញ្ជាក់តទៅនេះ :

សម័យមុនពុទ្ធកាលៈ មានស្ត្រីម្នាក់ឈ្មោះនាង "អមរា" ជាមហេសីនៃព្រះមហោសថពោធិសត្វជារាជបណ្ឌិត នៃព្រះបាទវិទេហរាជ ។ ថ្ងៃមួយអាចារ្យទាំង៤នាក់ ដែលជាគូសត្រូវនឹងព្រះមហោសថបានលួចកែវមណីព្រះរាជទ្រព្យទៅលក់ឲ្យនាងអមរា, នាងបានទទួលទិញដោយកត់ទាំងឈ្មោះអ្នកលក់ ទាំងពេលទិញ, ហើយពួកអាចារ្យទូលព្រះមហាក្សត្រមួលបង្កាច់ថា ព្រះមហោសថលួច ។ ព្រះរាជាទ្រង់ព្រះរាជបញ្ជា

ឲ្យហៅព្រះមហោសថៗ ឃើញថាកែវខ្លួនពុំបាន ក៏ប្រាប់នាងអមរាហើយ
ទៀសខ្លួនសិនទៅ ។ ពេលនោះពួកអាចារ្យចង់បាននាងអមរាជាភរិយា
ក៏ឲ្យដំណឹងថា នឹងទៅជួបនាងក្នុងវេលាយប់ នៅផ្ទះនាងៗឲ្យកម្មករជីក
រណ្តៅក្រោមផ្ទះដាក់លាមក ក្នុងរណ្តៅនោះក្រាលក្តារពីលើ ធ្វើគន្លឹះឲ្យ
ជាន់របូតហើយក្រាលកន្ទេលផ្ទុបអាសនៈធម្មតា ។ វេលាពួកអាចារ្យមក
ដល់ ដើរជាន់កន្ទេលក៏ក្តារធ្លាក់ទៅក្នុងរណ្តៅនោះរណ្តំក្បាលគ្នា ។ នាង
អមរាក៏ឲ្យចាប់អាចារ្យទាំង៤នាក់ បង្ក្តាប់គ្នានាំទៅថ្វាយព្រះរាជាៗទ្រង់
ព្រះវិនិច្ឆ័យថា កំហុសនេះធ្លាក់ទៅលើអាចារ្យទាំង៤ ។ ព្រះមហោសថរួច
ខ្លួនដោយសារនាងអមរាជាមហេសី ដែលជាស្រីបានសិក្សា មានប្រាជ្ញា
ច្រើនជួយដោះកុន ។

សម័យពុទ្ធកាលៈ មានស្រីគម្នាក់ឈ្មោះនាងខុជ្ជុត្តរា ជាស្រី
បម្រើពួកព្រះស្នំរបស់ព្រះបាទឧទេនព្រះចៅក្រុងកោសម្ពី មានព្រះនាង
សាមាវតីជាដើម ដែលព្រះរាជាទ្រង់ហាមពួកព្រះស្នំមិនឲ្យចេញទៅស្តាប់
ព្រះធម៌ទេសនានៃព្រះសម្មាសម្ពុទ្ធឯក្រៅព្រះរាជវាំង ។ ព្រះស្នំទាំងនោះ
បានចាត់នាងខុជ្ជុត្តរាឲ្យទៅស្តាប់ ។ ហើយឲ្យនាំយកមកសំដែងប្រាប់ព្រះ
ស្នំ ។ នាងខុជ្ជុត្តរាបានស្តាប់បានសំដែងធម៌រាប់ថ្ងៃក៏បានទៅជាអ្នកប្រាជ្ញ
មួយរូបពូកែខាងសំដែងធម៌ បានលាភសក្ការៈច្រើន ។

មាននិទាន១ទៀត ក្នុងសម័យពុទ្ធកាលដែរថាៈ មានស្រីម្នាក់ឈ្មោះ
នាងកុណ្ឌលកេសី ជាកូននៃរាជគហសេដ្ឋី នាងឲ្យសេដ្ឋីជាបិតាលោះចោរ
ម្នាក់ដែលពេជ្ឈឃាតបណ្តើរទៅសម្លាប់ យកមកធ្វើប្តី ។ ចោរមកនៅផ្ទះ

ស្ដីហើយក៏នឹកចង់ទៅនៅព្រៃវិញ ក៏ល្បួងនាងឲ្យជូនក៏ទៅព្រៃ ដើម្បីលាបំណន់ក្បែរមាត់ជ្រោះនៅដើមភ្នំមួយ ក៏ឲ្យនាងស្លៀកពាក់ល្អ មានគ្រឿងមាសពេជ្រច្រើន ដើម្បីកសម្លាប់យកគ្រឿងប្រដាប់លក់ស៊ីតាម ។ លុះទៅដល់មាត់ជ្រោះ ចោរប្រុងសម្លាប់នាងៗគិតថា “ប្រាជ្ញាដែលគេខំរៀនសូត្រមក គេមិនដែលប្រើជាអាហារទេ គេត្រូវតែប្រើដោះខ្លួនឲ្យផុតពីភ័យអាសន្ន” ។ លុះគិតហើយ នាងលួងចោរថា “អ្នកបង! ខ្ញុំដឹងគុណណាស់ ដែលអ្នកបានមកធ្វើជាប្ដីខ្ញុំនេះ មុននឹងខ្ញុំព្រាត់ចាកអ្នក ខ្ញុំសូមបូជាគុណអ្នកសិន ហើយសឹមស្លាប់” ។ ថាហើយក៏សំពះទៅទិសទាំង ៤ ដើរប្រទក្សិណចោរ៣ជុំ ហើយច្រានទម្លាក់ជ្រោះស្លាប់ទៅ ។

កាលដែលចោរធ្លាក់ជ្រោះ ពួករុក្ខទេវតាដែលអាស្រ័យនៅព្រៃនោះ ក៏ស្រែកបន្លឺសាធុការឮពេញទាំងព្រៃថា :

ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិចក្ខណា ។

ប្រែថា: បុរសមិនមែនជាបណ្ឌិតគ្រប់ហេតុទាំងពួងទេ, ស្ត្រីក៏ជាបណ្ឌិតអាចពិចារណាក្នុងហេតុនោះៗដែរ ។

គឺថា: អ្នកប្រាជ្ញមិនមែនមានតែបុរសទេ, ស្ត្រីបើខំរៀនសូត្របំណេះវិជ្ជាខាងផ្លូវលោកក្ដី ខាងផ្លូវធម៌ក្ដី ក៏បានជាអ្នកប្រាជ្ញដូចគ្នា ។

## ប្រទេសកម្ពុជាសម័យនគរភ្នំ(ហ្វូណន) គ្រិស្តសតវត្សទី១:

ព្រះរាជា១ព្រះអង្គទ្រង់ចេញចាកប្រទេសឥណ្ឌាភាគខាងត្បូង ចូល

មកកាន់ប្រទេសខ្មែរដំបូងបំផុត ។

ព្រះរាជាអង្គនេះខ្មែរហៅថា "ព្រះបាទកុម្រែ" តាមនាមដ្ឋ ។ ព្រោះពាក្យថា កុម្រែ នេះហើយ បានជាក្លាយមកជាខ្មែរសព្វថ្ងៃនេះ ។

សៀមហៅថា"ព្រះបោង"ប្រែជាខ្មែរថា"ព្រះអង្គមាស" ព្រោះព្រះអង្គមកប្រថាប់នៅជ្រោយកោះមាស (សុវណ្ណភូមិ);

ចិនហៅថា "ព្រះបាទកៅណ្ឌិន្យ" តាមព្រះនាមដើមជាភាសាសំស្រ្កឹត ឬហៅម្យ៉ាងទៀតថា "ព្រះបាទហ៊ុនទៀន" ។

ព្រះរាជាអង្គនេះ បានធ្វើសង្គ្រាមនឹងព្រះរាជិនី (ស្តេចស្រី) ទ្រង់ព្រះនាម"លៀវយី"ដែលខ្មែរហៅថា"ព្រះនាងសក់ក្រអូប"ខ្លះហៅថា"ព្រះនាងនាគី" ព្រោះទ្រង់ព្រះសម្ភពពីពស់នាគ, តែតាមពិតព្រះនាងនេះមិនមែនជាសត្វនាគទេ គឺព្រះរាជធីតានៃព្រះបាទអស្សវៃពជ (ស្តេចពាមទី ៥) ដែលទ្រង់ព្រះទីវង្គតទៅ មានតែព្រះរាជធីតានេះឡើងសោយរាជ្យគ្រងព្រះរាជ្យ, ព្រះនាងនេះនៅលើបានជាខ្មែរជាន់នោះហៅថា "ព្រះនាងនាគ"ព្រោះនាគប្រែថា ប្រសើរ ថាបរិសុទ្ធ គឺពុំមានបុរសប៉ះពាល់ ដូចកូនការបំបួស គេតែងហៅកុលបុត្រដែលគោរសក់រៀបនឹងចូលបួសថា "នាគ"នោះឯង ។

កាលព្រះរាជិនីលៀវយីចាញ់សង្គ្រាមហើយ ក៏សព្វព្រះរាជហឫទ័យទទួលយកព្រះបាទកុម្រែជាព្រះស្វាមី អភិសេកសោយរាជ្យនៅនគរវ៉្នំ

"ក្ន" ព្រះមហាក្សត្រអង្គនេះហើយជាដើមព្រះរាជវង្ស គឺព្រះរាជបល្ល័ង្ក ទី ១ នៃប្រទេសកម្ពុជា ។ រឿងនេះសឲ្យឃើញថាប្រទេសខ្មែរដំបូងបំផុត មានស្ត្រីជាស្តេចគ្រប់គ្រង ។

* * *

## សម័យអង្គរ (គ្រិស្តសតវត្សទី ១៣):

សិលាចារឹកនៅប្រាសាទអង្គរពោលថា "ព្រះនាងអគ្គមហេសីនៃព្រះបាទជ័យវរ្ម័នទី ៧ ពូកែលើសលុប ឥតនរណាស្មើខាងវិទ្យាសាស្ត្រ ទីងបរមត្ថសាស្ត្រ ព្រះរាជាទ្រង់តាំងជាព្រះបរិនាយិកាចារ្យក្នុងព្រះអារាមព្រះពុទ្ធសាសនាដ៏ល្បីល្បាញ ១ ព្រះនាងបានបង្រៀនពួកស្ត្រី" គឺព្រះនាងនេះហើយ ដែលធ្វើឲ្យយើងដឹងដោយសិលាចារឹកយ៉ាងធំ ១ នៅប្រាសាទពិមានអាកាស ដែលព្រះនាងតែងដោយព្រះអង្គឯងថា "ព្រះនាងគង់នៅក្នុងទី ១ ឈ្មោះនរេន្ទ្រាស្រមជាទីសិក្សា ដែលពួកស្ត្រីរាជបរិពាររមករៀនសូត្រ ព្រះនាងក៏ល្បីល្បាញក្នុងទីនោះ ដោយការគោរពរបស់បណ្ឌិតសិស្សទាំងឡាយ ព្រះនាងជាអ្នកធ្វើឲ្យពួកស្ត្រីទាំងនោះបានសេចក្តីសុខ ឧបមាដូចជាទេវធីតាឈ្មោះសរស្វតីបែងភាគមក ... ព្រះនាងបានផ្សាយសេចក្តីមេត្តាព្រះមហាក្សត្រ ចំពោះស្ត្រីណាដែលចូលចិត្តសិក្សាវិទ្យាសាស្ត្រ ឧបមាដូចជាទឹកទិព្វយ៉ាងប្រសើរដែលហូរចេញមកជាសេចក្តីចេះដឹង" ។

* * *

## សម័យព្រះបរមរាជវាំងកោះស្លាកែត (គ្រិស្តសករាជ ១៨៣៤ដល់១៨៤១):

ប្រទេសកម្ពុជាមានស្ត្រីភាពជាព្រះរាជិនី គឺព្រះអង្គ ម៉ី ក្សត្រី ព្រះរាជបុត្រីព្រះបាទឧទ័យរាជា (អង្គចន្ទ) ស្តេចឡើងសោយរាជ្យតំណពីព្រះវរបិតាគង់នៅក្នុងព្រះបរមរាជវាំងកោះស្លាកែត (ត្រើយពោធិ៍ព្រះបាទ) ក្នុងខេត្តកណ្តាលសព្វថ្ងៃនេះ ។ រជ្ជកាលនេះ ជារជ្ជកាលទី ៧៨ នៃព្រះរាជបល្ល័ង្កប្រទេសកម្ពុជា, មុនរជ្ជកាលព្រះករុណាបរមកោដ្ឋ (ព្រះអង្គឌួង) ដែលគង់នៅព្រះបរមរាជវាំងឧត្តុង្គមានជ័យ ។

* * *

## សម័យភ្នំពេញ (គ្រិស្តសករាជ ១៩៥៥):

ប្រទេសកម្ពុជាមានព្រះមហាក្សត្រ ២ ព្រះអង្គ គឺព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម-សុរាម្រិត ជាព្រះរាជស្វាមី និងសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ-មុនីវង្ស-កុសុមៈនារីរ័តន៍សិរីវឌ្ឍនា ជាព្រះអគ្គមហេសី ទ្រង់ឡើងសោយរាជសម្បត្តិពីថ្ងៃទី ៣ ខែមីនា គ្រិស្តសករាជ ១៩៥៥ ជារជ្ជកាលទី ៨៤ នៃព្រះរាជបល្ល័ង្កប្រទេសកម្ពុជា តំណពីរជ្ជកាលទី ៨៣ នៃព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម-សីហនុ ជាព្រះរាជបុត្រដ៏ធ្លេមនៃព្រះអង្គ ។

ស្រាវជ្រាវរឿងទាំងអតីតទាំងបច្ចុប្បន្ននេះមក ដើម្បីបញ្ជាក់ឲ្យឃើញថា: ភេទស្ត្រីដែលធម្មជាតិតាក់តែងមកជាភេទខ្សោយ សាប់ជ្រោយ

កាយទន់ភ្លន់ ចិត្តមិនសូវរឹងប៉ឹងនោះ បើបណ្ដោយទុកតាមធម្មជាតិក៏ខ្សោយតាមដើម ប៉ុន្តែបើគេបានអប់រំបណ្ដុះនិស្ស័យដោយ ក្បួនអនាម័យក្បួនវិទ្យាសាស្ត្រ និងក្បួនសិក្សាយ៉ាងម៉ឺងម៉ាត់ ក៏នៅជាមនុស្សខ្លាំង សាចរឹង កាយរឹងប៉ឹង ចិត្តពូកែក្លាហាន មានប្រាជ្ញាប៉ិនប្រសប់ស្មើនឹងបុរសដែរ ឬពូកែជាងបុរសខ្លះដោយអទ្វើ ៗ ក៏សឹងមាន ដូចនិទានដែលស្រង់មកតំណាលជាភស្តុតាងស្រាប់ ៗ

ព្រោះហេតុនេះ បានជាមនុស្សលោកសម័យបច្ចុប្បន្ន គេនិយមឲ្យស្ត្រីធ្វើពិធីហាត់ប្រាណ ដើម្បីឲ្យស្ត្រីមានសុខភាព ឲ្យរឹងប៉ឹង រហូតដល់អាចធ្វើជាទាហាន ឬជាពេទ្យទាហានទៅប្រតិបត្តិការក្នុងកងទ័ពបាន, ឲ្យស្ត្រីរៀនអក្សរដើម្បីឲ្យមានប្រាជ្ញាជ្រៅជ្រះ រហូតដល់ធ្វើជាសាស្ត្រាចារ្យ ជាអ្នកកាន់ការកាន់មុខតំណែងធំ ៗ បាន, ឲ្យរៀនសិល្បៈវិជ្ជាគ្រប់បែបឲ្យបានជាសិល្បករ ហត្ថករ ទស្សហាករ វណិជ្ជករ កសិករ កម្មករជំនាញ ៗ សម្រាប់ញុំាងសេដ្ឋកិច្ចរបស់ប្រទេស ឲ្យមានវឌ្ឍនភាព ។ ល ។

ប្រទេសកម្ពុជាយើងសម័យបច្ចុប្បន្ននេះ រាជរដ្ឋាភិបាលសង្គមរាស្ត្រនិយម មានសម្ដេចព្រះឧបយុវរាជ នរោត្តម សីហនុ ព្រះបិតាឯករាជ្យជាតិ ជាប្រធានទ្រង់បានស្ថាបនាស្ត្រីខ្មែរជាតិ ជាអាទិ៍ គឺឲ្យស្ត្រីមានសិទ្ធិស្មើនឹងបុរស, អាចបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួន, អាចឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោតជ្រើសតាំងខ្លួនជាតំណាងរាស្ត្រទៅកាន់រដ្ឋសភា, អាចធ្វើជារដ្ឋសភាបាន, ឲ្យស្ត្រីហាត់ប្រាណតាមអត្តពល-

កម្មវិធី ឲ្យមានកងកាយរឹងប៉ឹង មានសុខភាព ឲ្យហាត់កាន់កាំភ្លើង, ដូចក្នុងផែនការព្រះសីហនុ ដែលតាំងស្ត្រីខ្មែរ ឲ្យជានារីក្លាហានជំណាលគ្នានឹងបុរស ដែលតាំងជាកងជីវពល កាន់កាំភ្លើងប្រតិបត្តិការសាមគ្គី មានជោគជ័យដរាបដល់ដណ្ដើមយកឯករាជ្យពេញទី ជូនមាតុប្រទេសបាន ពីថ្ងៃទី៩ វិច្ឆិកា គ. ស. ១៩៥៣ ។

ខ្ញុំមានសេចក្តីសង្ឃឹមថា អនាគតដ៏ខ្ទីនៃប្រទេសកម្ពុជាយើង មុខតែបានភ្លឺត្រចះដោយសារស្ត្រីខ្មែរ ដែលនាំគ្នាសិក្សាអក្សរសាស្ត្រ សិល្បៈសាស្ត្រនិងវិទ្យាសាស្ត្រគ្រប់បែបយ៉ាងតាមផែនការដែលសង្គមរាស្ត្រនិយមបានឧបត្ថម្ភ ហើយដើម្បីធ្វើប្រទេសជាតិមាតុភូមិឲ្យបានសុខចម្រើនថ្កើនរុងរឿងទាន់សម័យ ដូចអារ្យប្រទេសនានាក្នុងសកលលោកជាប្រាកដពុំខាន ។

ចប់

ស្ត្រីជាពលភាពប្រទេសជាតិ
អាចជួយប្រុសភាគសកម្មភាព
ជួយជាតិសាសនាប្រាជ្ញខ្លួរប្រាប
យោគជ័យសំណាបស្រីយោធប្រុស ។

ភ៉យ-ប៊ុក

# ភាសាខ្មែរ

លោកហ្វ្រង់ស្វាស៍ ម៉ារទីនី - រៀបរៀង

## លោកប៉ាយ-ប៊ុក ប្រែមកជាភាសាខ្មែរ

ខ្ញុំមិនបានដឹងថា អ្នកណាជាបឋមដែលសរសេរថា ភាសាខ្មែរមកពីភាសាសំស្ក្រឹត ។ តែការកាន់ប្រឡំនេះ កើតឡើងដោយអ្នកនិពន្ធដែលមិនសូវមានវិជ្ជាខាងភាសាសាស្ត្រ បេះតែចំឡងតាមគ្នាទៅវិញទៅមក ។ អត្ថបទនេះ សម្រាប់ពន្យល់បំភ្លឺអ្នកអាននៅចំណុចនេះ, ហើយមិនបានអះអាងថា នឹងពណ៌នានូវភាសាខ្មែរ ដោយសំដែងនូវលក្ខណៈគោលឲ្យពេញលក្ខណៈទេ ។

អ្នកដែលមិនបានទទួលពត៌មានច្បាស់លាស់, ច្រើនកាន់ប្រឡំភាសានឹងអក្សរ ។ គឺ ចំពោះតែអក្សរខ្មែរ ដែលត្រូវពោលបានថា អក្សរនេះមកពីអក្សរឥណ្ឌៀ ។

តួអក្សរខ្មែរ គឺ គេខ្ចីតួអក្សររបស់ប្រទេសឥណ្ឌៀខាងត្បូង យកមកប្រើក្នុងសតវត្សរ៍ទី៦ ។ តួអក្សរខ្មែរដែលសម្រាប់ប្រើសព្វថ្ងៃមានពីរបែប គឺតួជ្រៀងមានសភាពទ្រេត ដែលសម្រាប់ប្រើជាសាមញ្ញគឺលិខិតសរសេរដៃឬបោះពុម្ព អត្ថបទរដ្ឋបាល សៀវភៅ ឬ សារពត៌មាន ។ តួ"មូល" គឺមានទម្រង់មូល ជាអក្សរសរសេរយឺត ហើយផ្ចិតផ្ចង់ថែមទៀត សម្រាប់ចំឡងអត្ថបទ ខាងសាសនាជាភាសាបាលី ។ តែគេច្រើនប្រើតួអក្សរធំដើម្បីយកទៅសរសេរចំណងជើងសៀវភៅ ពាក្យដែលគេគូសចំណាំក្នុងអត្ថបទជាអក្សរជ្រៀង យីហោពាណិជ្ជដ្ឋាន អក្សរចារឹកនៅក្លោងទ្វារគ្រឹះស្ថានជាសាធារណៈ ។

អក្សរបោះពុម្ព មិនមែនមានសភាពៈផ្សេង ពីអក្សរសរសេរដៃទេ ។

ឥឡូវនេះ គ្មានបុគ្គលណាមិនដឹងថា ភាសាសំស្រ្កឹតដែលជាភាសាអក្សរសាស្ត្រ សម្រាប់សិក្សារៀនសូត្រនៅប្រទេសឥណ្ឌាទេ កើតឡើងដោយអំបូរភាសាឥណ្ឌូ-អឺរ៉ូប៉េអែន, គឺថា ភាសាសំស្រ្កឹត មានប្រភពដូចគ្នានឹងភាសា សម្រាប់សិក្សា គឺភាសាក្រិកនឹងឡាតាំង ។ គឺជាត្រយមួយពន្លកចេញពីដើមជាមួយគ្នា ដែលជាទីកើតនៃភាសាស្លាវ, សែរម៉ានិក នឹងបាល់ទិក ។

អ្នកណាដែលបានសិក្សារៀនសូត្រនូវភាសាទាំងនេះ, បើទុកណាជាអ្នកនោះមិនមែនជាអ្នកស្ទាត់ជំនាញ ខាងវិជ្ជាភាសាសាស្ត្រ, គង់តែយល់បានថា សទ្ទានុសាស្ត្រ សូរសាស្ត្រ នឹងវេយ្យាករណសាស្ត្រនៃភាសានោះ មានសភាពប្រហែល ៗ គ្នា ដែលគេអាចសំគាល់បាន ។ មិនចាំបាច់ចេះភាសាខ្មែរច្រើនទេ ដើម្បីនឹងឲ្យយល់ថា ភាសាខ្មែរមានសភាពផ្សេងពីភាសាអឺរ៉ូប៉េអែន ។

ភាសាខ្មែរដែលខុសគ្នាស្រឡះ ពីភាសាសំស្រ្កឹត, គឺ ភាសាឥណ្ឌូ-អឺរ៉ូប៉េអែន, ជាភាសាដែលកើតឡើង ពីអំបូរភាសា ឥណ្ឌូស៊ុណ្ឌាដែលហៅថា ភាសាមនខ្មែរ ព្រោះថា ភាសាខ្មែរ នឹងភាសាមន ដែលគេនិយាយនៅប្រទេសភូមាខាងក្រោម ជាសាខាយ៉ាងសំខាន់នៃអំបូរភាសាឥណ្ឌូស៊ុណ្ឌា ។

ក្រៅពីភាសាវៀតណាមដែលវប្បធម៌ចិន បានវេចនាឲ្យទៅជាភាសាចិនដោយភាគច្រើន, នៅឥណ្ឌូចិនមានភាសាសំខាន់ ៣ ក្រុម ឬពួក គឺ

-ភាសាថៃ(សៀម លាវ, គ្រាមភាសាថៃនៅប្រទេសតុងកឹងខាងលើ

-ឥណ្ឌូនេស៊ីយាង (ចាម, ជរ៉ៃ, រ៉ាដែ . . .) ។

-ភាសាមនខ្មែរ (ព័រ, ចុង, សាំរែ, គួង,,ស្ទៀង, ភាគ . . .) ។

បើតាមពិនិត្យពួកភាសាទាំងអស់នេះ អាចមានសភាពជួបគ្នាជាច្រើនកន្លែង ទាល់តែគេរួមពួកភាសាទាំងបី បញ្ចូលគ្នាអំបូរភាសាតែមួយ ហៅថា ភាសាអូស្ត្រូ-អាស៊ីអាទិក ។

បឋម, ភាសាខ្មែរដែលជាភាសាប្រជារាស្ត្រ មានវិវឌ្ឍន៍ស្តួចស្តើងក្រជាទីបំផុត ត្រង់ស័ព្ទអរូបី (termes abstraits) ។ លុះដល់ជនជាតិខ្មែរបានទទួលសិរីវិល័យពីប្រទេសឥណ្ឌា ព្រមទាំងធ្វើស្ថាប័នសង្គម នឹងសាសនាថ្មី,ជននេះត្រូវខ្ចីពាក្យសំស្ក្រឹត យកទៅប្រើប្រាស់ចំពោះពាក្យស័ព្ទរដ្ឋបាល, គុណការ, នឹងអក្សរសាស្ត្រ ដើម្បីនឹងយកពាក្យដែលបានមកពីបរទេស ទៅប្រាស្រ័យដោយប្រាជ្ញាខ្លួន នឹងជីវភាពសម័យបច្ចុប្បន្ន ។ ហេតុនេះហើយបានជាកើតមានរឿងគេពោលថា ភាសាខ្មែរកើតមកពីភាសាសំស្ក្រឹត ; បើតាមពិត, ភាសាខ្មែរគ្រាន់តែខ្ចីស័ព្ទសំស្ក្រឹតយកមកប្រើប៉ុណ្ណោះ។ ពិតមែនតែជនជាតិខ្មែរបានតម្កល់ទុកភាសាសំស្ក្រឹតជាភាសាវិញ្ញូជន, តែប៉ុន្តែ ភាសាសំស្ក្រឹតមិនដែលមានអានុភាពជាងភាសាអ្នកស្រុក ព្រោះថា តាមសិលាចារឹកបញ្ជាក់ថា តាំងពីបឋមសម័យ ភាសាខ្មែរ បានយកមកប្រើជាមួយនឹងភាសាសំស្ក្រឹត ។ ការដែលបញ្ជាក់ ឲ្យឃើញនូវការប្រើប្រាស់ ដោយសេចក្តីសន្មត ឬ ដោយនិយមប្រជារាស្ត្រ នូវភាសាសំស្ក្រឹតនេះ គឺថា អត្ថបទសំស្ក្រឹតទាំង

អស់ សុទ្ធតែសរសេរជាពាក្យកាព្យ ។

ដល់ក្រោយមកទៀត, ក្នុងដើមសតវត្សរ៍ ១៤ ដោយព្រះពុទ្ធសាសនាហីនយាន ដែលមានអត្ថបទពិសិដ្ឋសរសេរជាភាសាបាលី បានចូលមកជំនួសនូវព្រាហ្មណសាសនា និងពុទ្ធសាសនាមហាយាន, ភាសាខ្មែរ ក៏បានយកពាក្យបាលីមកប្រើជាច្រើន ។ ការចម្រើនពាក្យនៃសព្ទានុក្រមខ្មែរ ដោយខ្ចីពាក្យបាលីយកមកប្រើ ចេះតែចម្រើនរាល់ ៗ ថ្ងៃ, ជាលំដាប់តមក ។ តាំងពីប្រទេសកម្ពុជាបានស្វ័យភាព គេបានឃើញការចលនានៃពាក្យថ្មី ឬការចម្រើននៃភាសាខ្មែរ ដោយហេតុថា អ្នកប្រែភាសាឬអ្នកនិពន្ធជាភាសាខ្មែរ នូវអត្ថបទរដ្ឋបាល, រដ្ឋធម្មនុញ្ញ ឬអ្នកត្រូវការផ្សាយពត៌មាន តាមកាសែតនិងវិទ្យុ ត្រូវប្រើពាក្យនោះជាការចាំបាច់ ។

ពត៌មានមួយ ត្រូវកត់សំគាល់ គឺនវសព្ទ ( ពាក្យថ្មី ) ដែលបង្កើតឡើង ដោយពេញចិត្ត តែយកភាសាបាលី ជាមូលដ្ឋានច្រើនជាងភាសាសំស្ក្រឹត រឿងនេះ គឺ មកពីជនជាតិខ្មែរសម័យបច្ចុប្បន្ន ស្គាល់ជាក់ច្បាស់នូវភាសាបាលី ជាងភាសាសំស្ក្រឹត ។ អ្នកអគ្គមាស់យុត្តិវិន្យទ្រង់បានស្ថាបនានូវគណៈកម្មការមួយ សម្រាប់ប្រែច្បាប់រដ្ឋធម្មនុញ្ញថ្មី ដែលមានអត្ថបទដើមសរសេរជាភាសាបារាំង ។ គណៈកម្មការនោះច្រើនមានសមាជិក ជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ (ឥឡូវហៅថាសាលាពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ) ឬ ជាពួកសុមេធពុទ្ធសាសនបណ្ឌិត្យជាសមាសភាព ។ មានរឿងមួយទៀត ដែលគេត្រូវកត់សំគាល់, គឺថា ពាក្យបាលីដែលបានព្រមព្រៀងយកមកប្រើ ដើម្បីបញ្ចូលទៅក្នុងពាក្យសព្ទ

បច្ចេកទេស ភាសាខ្មែរច្រើនមានសភាពដូចគ្នា និងពាក្យដែលពួកសៀមបានយកមកប្រើហើយ ៗ វិចារណញ្ញាណគឺជាមានភិក្ខុអង្គខ្លះដែលមានវិជ្ជានិងពួកសុមេធពុទ្ធសាសនបណ្ឌិត្យទាំងពីរផ្នែក ដែលចេះដឹងជ្រៅជ្រះនូវភាសាសៀម ហើយដោយមានបំណងយ៉ាងខ្លាំង, ចង់ពង្រីកវប្បធម៌របស់ខ្លួន ឲ្យកាន់តែចំរើនក្នុងកិច្ចស្វែងរកពតិមាន អំពីវឌ្ឍនធម៌ និងវត្ថុទាំងឡាយនៃជីវភាពទំនើប ពួកនេះមានតែទស្សនាវដ្ដីនិងកាសែតសៀមប៉ុណ្ណោះ ដែលគេទុកជាប្រភពនៃការស្វែងរកពតិមាននោះ ៗ ។ ភិក្ខុសង្ឃដែលចេះភាសាបារាំងបន្តិចបន្តួច ក៏រកបានដោយកម្រណាស់, ហើយភិក្ខុសង្ឃដែលមានសមត្ថភាពអានសៀវភៅ ជាភាសាបារាំងបាន, ជាការកម្រណាស់ទៅទៀត ៗ នៅប្រទេសកម្ពុជា, មិនមានទស្សនាវដ្ដីនិងសារពត៌មានខ្មែរទេ (១), ចំណែកឯទីក្រុងបាងកក មានសារពត៌មានទិនានុប្បវត្តិ, និងទស្សនាវដ្ដីសប្ដាហៈនិងអនុមាស ជាពិសេសស្ដីអំពីវិទ្យាសាស្ត្រ, វេជ្ជសាស្ត្រ, កសិកម្ម, អក្សរសាស្ត្រ, សាសនា, សេដ្ឋកិច្ច និងនយោបាយ ៗ ពាក្យស័ព្ទបច្ចេកទេស, ប្រកបដោយប្រាជ្ញាដ៏ជ្រាលជ្រៅ នៃទស្សនាវដ្ដីទាំងនោះ ច្រើនដកយកមកពីភាសាបាលី និងភាសាសំស្ក្រឹត ៗ

ដោយមានការខ្ចីពាក្យយកមកប្រើ ចំពោះតែភាសាមួយដូចគ្នា ពិតមែនតែភាសាខ្មែរ និងភាសាសៀម មានអំបូរភាសាខុសគ្នាស្រឡះ ក៏គង់មានបំណងទៅកាន់ឧត្តមដ្ឋាន គឺស្ថាននៃភាសាដែលសម្រាប់ប្រើខាង

---

១– កំណត់នៃអ្នកប្រែៈ លោកម៉ារ៉ឺទី ប្រហែលជាសរសេរអត្ថបទនេះក្នុងឆ្នាំ ១៩៤៥ ក្នុងពេលដែលប្រទេសកម្ពុជា មានទស្សនាវដ្ដី ២ គឺ ទស្សនាវដ្ដីស្រុកខ្មែរ ១ ទស្សនាវដ្ដីកម្ពុជសុរិយា ១ និងសារពត៌មាននគរវត្ត ១ ផងដែរ ៗ

អក្សរសាស្ត្រ និងវិទ្យាសាស្ត្រ ។

គោលការនេះ អាចធ្វើប្រជារាស្ត្រទាំងពីរនៅឥណ្ឌូចិន ដែលទទួលអារ្យធម៌ ពីប្រទេសឥណ្ឌា ឲ្យមានមនោធម៌ នៃសមាគមន៍វប្បធម៌ ប្រកបដោយពលភាពទ្វេឡើងទៀត ។ ហើយបើគេយល់ថា ជនជាតិលាវ ដើម្បីនិងធ្វើភាសារបស់ខ្លួន ដែលមានសភាពប្រហែលគ្នា នឹងភាសាសៀម ឲ្យកាន់តែសម្បូរខាងពាក្យប្រើប្រាស់ សម័យបច្ចុប្បន្នបាន គំយកពាក្យនេះពីភាសាបាលីដែរ ។ ភាសាទាំងពីរ ដែលមានដើមតែមួយដូចគ្នា គឺភាសាថៃ បានចូលទៅជិតស្និទ្ធនឹងភាសាខ្មែរ ទាំងអក្សរសាស្ត្រនិងបច្ចេកទេស ហើយគេអាចឃើញថាជាការមានផលប្រយោជន៍ ការស៊ិញស្រួល យ៉ាងណាទៅចំពោះពាក្យសព្ទ ដ៏ជ្រាលជ្រៅ ជាសមូហភាព ដែលអាចនឹងប្រើបាន ក្នុងកាលជាអនាគត ចំពោះការផ្លាស់ប្តូរវប្បធម៌និងនយោបាយ របស់ប្រជាជាតិទាំងបី ដែលមានព្រំប្រទល់ជាប់គ្នា តាមភូមិសាស្ត្រ ។

ដោយហេតុថា ភាសាខ្មែរមានពាក្យសព្ទអរូបីតិចណាស់ និងពាក្យសម្ពន្ធ មានសភាពវែងពន់ពេក, ភាសាខ្មែរនេះ ក្នុងសម័យបច្ចុប្បន្ន មិនអាចនឹងរៀបចំឲ្យសម ទៅតាមគំនិតទំនើបបានឡើយ ។ តែយើងមិនអាចថា មិនបានចាល់តែសោះនោះទេ ក្នុងពេលអនាគត ភាសានេះ អាចនឹងសម្រេច ទៅរកផលដ៏ប្រសើរ ក៏មិនដឹងដែរ ។ ពាក្យសព្ទអរូបីនិងបច្ចេកទេស កាន់តែចម្រើនកាល់ៗថ្ងៃ ដោយខ្ចីពាក្យសម្រាប់ប្រើប្រាស់ ពីភាសាសិក្សាប្រទេសឥណ្ឌា, ហើយពាក្យសម្ពន្ធ អាចសម្រួលទៅបាន ដោយមានអ្នកនិពន្ធ មានប្រាជ្ញាចេះភាសាខ្មែរនិងបាលីផង ។ ហេ

ត

ដូច្នេះឯង បានជាការប្រតិបត្តិ នៃកិច្ចប្រែភាសាអឺរ៉ូប៉ែន អាចនឹងធ្វើទៅបានដោយងាយ ក្នុងកាលជាអនាគត ។ ក្នុងឧទាហរណ៍ដូចជាជនជាតិហ្វីណា, ភាសាហ្វីណូអុងគ្រីយែន (finno - ougrienne) ពីដើមជាស្មើនៃស៊ីវិល្ស មានរភាពខុសគ្នា នឹងស៊ីវិល្ស ដែលជនជាតិហ្វីណាបានទទួលជាលំដាប់តមក ក្នុងពេលដែលជនជាតិហ្វីណា មកតាំងទីលំនៅ ។ ភូមិភាគអឺរ៉ូប៉ែន ។ បប៉ម, ជនជាតិហ្វីណា, ដើម្បីនឹងគោលប្រាស្រ័យចំពោះស៊ីវិល្សថ្មី ដែលខ្លួនបានទទួលមកកាន់យក, ត្រូវប្រើភាសាស៊ុយអែដ, ហេតុនេះបានព្យាយាមបង្កាភាសារបស់ខ្លួន ឲ្យចម្រើនជាលំដាប់ តមកសម្រួលភាសានោះឆ្លងយកពីភាសាស៊ុយអែដ, ៗ ព្រោះហេតុនេះហើយបានជាភាសាហ្វីណា ដែលជាភាសាអាស៊ីអាទិក អាចនឹងយកទៅប្រើប្រាស់បាន ចំពោះស៊ីវិល្សអឺរ៉ូប៉ែនទាំងគំនិតថ្មីទើបជា យ៉ាងហ្មត់ចត់ ។ ចប់ ។

| |
|---|
| ភាសារលត់ជាតិរលាយ<br>ប្រុសស្រីស្វាធ្យាយភាសាជាតិ<br>ព្យាយាមរក្សា ឲ្យសុខសាន្ត<br>កុំធ្វេសប្រមាទសង្វាតជាប់ ៗ<br>រ.ប. |

រឿងទេវធូ

ពាក្យកាព្យ

# លោកអនុមន្ត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

## លោកញ៉ុក ថែមពិនិត្យ

តមក

កុម្ភណ៍ស្អាប់ ពោធិបង្អាប់ ទំមិតអាសនា សិង្ហមណីរត្នពាស
ផ្ទះផ្ទាសថ្ងៃថ្លា កែវកង់សុវណ្ណ ក្តីផ្ទុកព្រោងព្រាយ ។ មានស្វេតច្ឆត្រ
ប្រាំពីរត្រួតរត្ន សឹងផ្កាចាំងឆ្លាយ ក៏បាក់ពាក់ទង ក្រាសក្រង់ផ្កាត់ផ្ទាយ
ពីជោរខ្ចរខ្ចាយ ទូវល្អងកេសរ ។ ខ្ទះជងទឹកស្រះ មកស្រង់ថ្វាយព្រះ
ពោធិបវរ ឲ្យស្រង់គ្រប់គ្រឿង រុងរឿងសឹងស អញ្ជើញស្តេចមក
គង់លើធម្មាសន៍ ។ យង់យល់គ្រប់ គ្របង់ល្អល្អ ក្តីផ្ទុកទិកាស
អុជទៀនធូបផង ព្រាតព្រោងពេញពាស ប្រក់ផ្ទះផ្ទាស់រុងរឿងរស្មី ។

ព្រះពង្សពុទ្ធទៅ អ្នកគង់ស្ងៀមនៅ លើអាសន៍សួស្តី ពុំបើក-
ព្រះសូរ មធុរថាអ្វី យក្សយល់ទរបតី ស្តេចគង់ស្ងៀមនៅ ។
យក្សគឿនទៀតថា ឥឡូវអាសនា គួរហើយម្តេចទៅ អង្គុយក្រាងើយ
កន្តើយស្ងៀមនៅ មិនសំដែងទៅ រំពឹងដល់ណា ។

ពោធិសត្វឆ្លើយ ថាហៃយក្ខអើយ បើនឹងទេសនា គួរមានបរិស័ទ
សុំអារាធនា នោះទើបគួរថ្លា- ថ្លែងព្រះធម៌ថ្លៃ ។ មួយសោតឲ្យមាន

បុគ្គលកល្យាណ ស្តាប់ធម៌ប្រពៃ ប្រសើរហៅជួរ ពុំគួរឡើយនៃ
អង្គឧត្តមត្រៃ ប្រើអញស៊ើខ្ញុំ ។ អញបេះសំដែង គួរតែប្រសើរ ឧទ-
សិរបត្តិ ក្រួញក្រាបឲ្យរាប សុភាពដៃផ្គុំ អារាធនាសុំ នូវសីលតាំងប្រាំ ។
អង្គអញសំដែង ធម៌ដល់ប្រសើរ ចូរទៅចងចាំ កួចកត់សំគាល់ រៀង-
ពលចំណាំ ឲ្យបានចងចាំ ដោយអាថ៌គាថា ។ កុម្ភណ្ឌបួននាក់ ហេតុ-
ចង់ដឹងជាក់ ព្រះ ថ្លៃថ្លា ក្រួញក្រាបបង្គំ បរមក្សត្រា ទទួលសីលមហា
បុរសវិញ្ញាណ ។

ទើបពោធិសត្វ ពន្ធកពុទ្ធត្ត បន្ទូលទៅស្ថាន ហៃអស់មហាយក្ស សីល
ប្រាំស្មានាន ចូរអ្នកឲ្យនបា ចាំជាក់ប្រក្រតី ៗ បាណាតិបា-តាអទិន្នាកាមេសុ-
មិច្ឆាចារិយា មុសាវាទ មជ្ជបរិ វេរមណា ។ បាណាតិបាត ឲ្យវៀរប្រមាថ
ជីវិតសត្វា អទិន្នាទាន វៀរមានលោភា លោភលួចទ្រព្យ នៃអស់-
មហាជន ។ កាមេសុមិច្ឆា កុំបរទារា វៀរលួចប្រពន្ធ នៃអ្នកនានា
ឲ្យជាមានម- ន្ទិលទាស់ទូទ់ ដូចដល់អាត្មា ។ មុសាវាទ វេរមណី
វៀរពាក្យមុសា មជ្ជបរិ វៀរពិសុរា គឺលាមកជា ថ្នាំបំពុលអង្គ ។
ពន្ធកសារពេជ្រ ឲ្យសីលប្រាំស្រេច ទៀងទើបត្រាស់ទ្រង់ បន្ទូលទៅថា
ហៃមហាយក្សយង់ ចូរប្រសើរប្រុង ស្មារតីពល់គ្នា ។ ចូរចិត្តចងចាំ
នូវសីលតាំងប្រាំ នោះឯងឲ្យប្រា- កដកុំប្រមាទ ឲ្យឃ្មាតឃ្មៀងឃ្មា
សីលប្រាំនេះជា ឬសកែវឧត្តមោ ។ សីលនោះជាខ្ទឹម ឥតស្មើប្រៀបផ្ទឹម
ជាយានសេដ្ឋា ប្រសើរភាំងបួន ហៅខ្ពូនមុំឡ្ហា ខ្ពៅហេតុពាលោ-
កាត់ឬសកែវបង់ ។ ទីងនាំខ្លួនទៅ ទល់ទុក្ខនិត្យនៅ នរកលុះលង់

ព្រោះកាលជាមនុស្ស កាត់ឫសកែវបន៍ សៀតសោះឲ្យអន្ត តែងតែងវេទនា ។ ចូរប្រស្តូងឯង ស្តាប់អញបំដែង អធម្មធម្មា មិនមែនព្រះធម៌ ទឹង ធម៌ថ្លៃថ្លា អាចឲ្យ ិសារ ឲ្យប្រស្តែងស្តាប់ ។ មិនមែនធម៌ពិត នេះគឺទុច្ចរិត ទាំងបីពុំគាប់ ពុំគឺធម្មា ឥតសព្វមានសព្វ រក់ទឹងក្រឡាប់ ឲ្យវេវេទនា ។ ប្រស្តែងទាំងអស់ កាលដើមជាមនុស្ស ព្រោះតែរក្សា ទុច្ចរិត. ទាំងបី នេះឥឡូវជា យក្ខយង់មោហា ដូរជាតិកម្មៅ ។ កំឡាំងទុច្ចរិត ទាំងបីបៀនបិទ អកុសលខ្ទួនទៅ គួរលោកគួរលះ ឲ្យជ្រះចេញទៅ ទុច្ចរិតនោះហៅ មិនមែនធម្មា ។ រីធម៌ពេញពិត នោះគឺសុចរិត ទាំងបីប្រការ ប្រកបប្រាកដ សន្មតហៅថា ព្រះធម៌ថ្លៃថ្លា ប្រសើរសេដ្ឋា ។

កុម្ភណ្ឌប្អូនអាក់ ស្តាប់ធម៌ជឿងជាក់ ទន់ទាំងមនោ សោមនស្សក្សាល អញ្ញាល័យោ ក្រាបក្រោមបាទា ពន្ធកសារស្តា ។ ទូលថាបពិត្រ អគ្គមានរិទ្ធិ ជាតិជាអាចារ្យ ចូរអ្នកទិទាន ឲ្យបានពិស្តារ ទុច្ចរិតបីប្រា- ការតើម្តេចទៅ ។

ពោធិសត្វឆ្លើយ ថាហៃយក្ខអើយ រីឯលោកហៅ ថាទុច្ចរិត បីពិតអញនៅ សំដែងចែងទៅ ឲ្យជ្រងពីគ្នា ។ មួយគឺកាយទុច្ចរិត មួយគឺវាចា ទុច្ចរិត មួយគឺមនា ទុច្ចរិតា នេះហៅទុច្ចរិត[1] ។ ទុច្ចរិតបីប្រ- ការនេះបែកជា ដប់ប្រការពិត យក្ខសួរវិធី រីបទុច្ចរិត ជាដប់បទពិត ម្តេចខ្លះអាចារ្យ ។ ពោធិសត្វឆ្លើយ ថាហៃយក្ខអើយ កាយទុច្ចរិតា បែបបទបាល័ ជាបីប្រការ រីឯវាចាទុច្ចរិតនោះ ។

(១) នេះជាសេចក្តីសំដែងអំពីទុច្ចរិត ៣ប្រការ គឺកាយទុច្ចរិត ១ វចីទុច្ចរិត១ មនោទុច្ចរិត១ ។

ជាបួនប្រការ រីមនសា ទុច្ចរិតស្មោះ ថែកបទថែរជា បីប្រការនោះ
បូករួមទាំងអស់ ជាដប់ប្រការ ។

យក្សស្តាប់ចូលចិត្ត សួរថាបពិត្រ ទុច្ចរិតដប់ប្រា- ការតើម្តេចខ្លះ
សូមព្រះករុណា សំដែងពិស្តារ ឲ្យយើងចូលចិត្ត ។ កាលណោះពង្ស-
ពោធិ៍ ប្រសើរជាតិដោត ប្រុះប្រាជ្ញាញុក ហៃយក្សទាំងឡាយ ឯកាយទុច្ច-
រិត ថែកជាបីបិត មានឧបទេបទ្ធែ ។ មួយគឺបាណា មួយគឺអទិន្នា មួយគឺកាមេ
ទាំង ៣ ឯងគាប ក្នុកប្រាជ្ញប្រាប់ប្រែ ប្រមូលឲ្យផ្សែ ហៅកាយទុច្ចរិត ។
រីឯវចី ទុច្ចរិតបាលី បែងជាបួនពិត សោតសឹងអប្រិយ មួយនឹតចិត្ត
ស្តីពុំដែលពិត មានតែមុសា ។ មួយគឺញុះញង់ ឲ្យគេបែកបង់
សាច់សំឡាញ់គ្នា វិនាសប្រាសព្រាត់ បែកបុគ្គលយោ ប្រាសព្រោះវាចា
ឯងគាប់ស្រដី ។ មួយពាក្យទ្រគោះ ពាក្យអសុរស ឥតរស់មេត្រី
ពាក្យពោលរឹងរូស ប្រទូស្តចង្កូ ពាលាស្រដី ច្រើនប្រឡាសលន់ ។
មួយពាក្យឈ្នានីស ដូចង់ចាបេស ស្រដីផ្ដាញ់ផ្លូន ផ្ដាញ់ផ្ដាលពុំគាប់
បង្អាប់បង្អន់ បំភរបំភាន់ បំផុតលាភគេ ។ ពាក្យបួនអប្រិយ នេះហៅវចី
ទុច្ចរិត ជាពាក្យអបលក្ខណ៍ ហៃយក្សរឯ មនោមនេ ទុច្ចរិតា ។
មួយចិត្តសង្ខាត ចិត្តតាមព្យាបាទ ទោសគបទោសា មួយចិត្តលោភពិត
មួយចិត្តមិច្ឆា ទិដ្ឋិហៅថា មនោទុច្ចរិត ។

កុម្ភណ្ឌបួននាក់ បានស្ដាប់វៀងជាក់ ទូលថាបពិត្រ តោះអ្នកដែលធ្វើ
អំពើទុច្ចរិត ដោយកាយពុំទិត្យ ពុំណាយលាភលា ។ កម្មអ្នកដែលធ្វើ
ដោយកាយនោះតើ ដូចម្តេចអាចារ្យ ចូរអ្នកនិមន ឲ្យបានពិស្តារ

ឲ្យយើងដឹងប្រា- កដកម្មដៀងជាក់ ។

ពន្យុត្តផល ស្ដេចបើកបន្ទូល ថាហៃអស់យក្ស បយោនពេ នូវអ្នក ណាឯងអបល័ក្ខណ៍ ធ្វើកម្មបាណា ៗ ស្លាប់ទៅនរក លំបាកវេទុក្ខ លុះមកកើតជា មនុស្សក្នុងលោកិយ អប្រិយមហិមា រូបកាឥអង្គអា ក្រក់ក្រៃក្រពុំស្អាត ៗ កំព្រាកកំព្រយ ក្រងក្រេងយ ជាលំនៅព្យាធិ តែង ធ្វើឲ្យអ- ន្តរាយជន្មជាតិ ចួនគេពិឃាដ ដោយគ្រឿងសស្ត្រា ៗ ចួន ស្លាប់ក្នុងពោះ ចួនប្រទះគ្រោះ សត្វខាំមរណា យក្ខអើយអ្នកធ្វើ អំពើ បាណា ពុំដែលមានអា- យុយឺនយូរនៅ ៗ មានអ្វីពេញចិត្ត កំពុង ស្នេហ៍ស្និទ្ធ ប្រែប្រាសចោលទៅ ឥតកោះឥតការ អសារអសៅ ពុំដែលទីងនៅ ស្លាប់ដល់ដក ៗ យក្ខអើយថាបើ អ្នកណាតាចធ្វើ កម្មអទិន្នា ស្លាប់ទៅវេទុក្ខ នរកសោះ[illegible] លុះមកកើតជា មនុស្ស ក្នុងលោកិយ៍ ៗ មកជាអ្នកខ្សត់ ហិនហោចទុគ៌ត កំព្រាអប្រិយ៍ ឥតញាតិជុំជិត ឥតមិត្រមេត្រី មានប៉ុន្មានក្តី ពុំបានជង់នៅ ៗ សឹង ប្រែព្រាត់ប្រាស ខ្ចាត់ខ្ចាយវិនាស អំពីខ្លួនទៅ ដោយវិនាសប្រាំ គឺកម្មខ្លួនឡៅ វិនាសមួយនៅ ទឹងភ្លើងឆេះហិន ៗ វិនាសមួយចោរ ដួរចិត្តពាលោ លបលួចពុំក្បាន្ត ខូចមួយប្រការ ទឹងមហាក្សត្រមាន មួយអន្តរធាន ទឹងព្រះគង្គា ៗ មួយមិញ្ញាត់ខ្ចាយ បង់បិទខ្ទេច ព្រាយ បង្និនអាត្មា ពោះរំពេកបាន ប៉ុន្មានក្តីណា វិនាសដោយប្រា- ការព្រោះអប្បម- ៗ ផលយក្ខអើយឯង អកុសលកាមេ តែងតែជួបជុំ ឲ្យទៅនរក ទល់ទុក្ខលុះឈន់ លុះមកកើតក្នុង លោកិយ៍នេះណា ៗ

ទុក្ខិន្ទ្រិយោ ទុក្ខរូបា ។ ហេតុកម្មកើតជា ខ្សោះខ្សោយប្រាជ្ញ
អាក្រក់មហិមា ឥត្ថីបុរិសា ស្មើរប្រុសស្មើរស្រី ។ អនិដ្ឋាថា ពោះ
បីប្រាថ្នា បង់បានអ្វី ។ សឹងប្រែមិនបាន ដូចក្នានមេត្រី គួរលោក-
កុំបី ធ្វើឲ្យមានហ្នង ។ បាណាទិន្នា ការមេសុមិច្ឆា តាំងបីនេះហោង
ព្រះស្រីសម្ពុទ្ធ ជាម្ចាស់លោកផង សំដែងដូចបង ហៅកាយទុច្ចរិត ។

យក្ខស្ដាប់ពោធិ ថ្វាត់ថ្វាយវន្ទ ទូលថាបពិត្រ អស់យើងខ្ញុំ
នេះសឹងចូលចិត្ត តែសូមអាណិត សំដែងទៀត ។ អ្នកណាដែលធ្វើ
នូវកម្មអំពើ អំពីវាចា អ្នកនោះតើត្រាំ ត្រូវកម្មវេទនា មេត្តាសូម
មេត្តា សំដែងឲ្យបាន ។

សម្ដេចពន្យពោ. ធីត្រាស់ថាភោ ម្នាលយក្ខគ្រប់ប្រាណ បើអ្នក
ឯណា មោហាអាចហាន បំពានបំពាន ស្របដីមុសា ។ ស្លាប់ទៅ
នរទុក្ខ ទៅព្លូកនរក លុះមកកើតជា មនុស្សហើនទុគិត កំសត់កំព្រា
មានមាត់អសារ អសោចិអប្រិយ៍ ។ សំឡេងស្អកស្អិត ពោះពោល
ពាក្យពិត ទឹងអ្នកណាក្ដី គេស្អប់គេខ្ពើម គេធ្មើមសិដ គេពុំមេត្រី
ពុំជឿវាចា ។ វាក្យញុះញង់ ស្ដីឲ្យគេបង់ បែកបុត្រភរិយា ស្លាប់-
ទៅនៅត្រាំ នរកម្មវេទនា លុះមកកើតជា មនុស្សនេះដួរជាតិ ។ ហេតុ
កម្មតាមមក រូបរាងពែកពក ក្នុងផ្ទះដូចគ្មាត វិស័យតិរច្ឆាន មិនមាន
សំអ្សាត សំឡេងគគ្រាត មាត់ស្អុយគគ្រុក ។ គគ្រិះគគ្រើម ខេត្តា
មនុស្សខ្ពើម បីដូចលាមក ហេតុកម្មបុរាណ មិញមានតែទុក្ខ ពិតពិ
សានុសុខ ដួបជុំញាតិទេ ។ វាក្យបិសុណា វាចាវាចា ញុះញ

ញាំញី ហេតុតែសំដី អំពីបុព្វ ខ្លួនបំបែកគេ ព្រាត់កូនប្រពន្ធ ។ ផរុសវាចា យក្សអើយអ្នកណា ពោលពាក្យទុជិន បំកាន់បំករ ច្រើន ប្រឡាក់សលន់ បង្អាប់បង្អន់ ធ្លាស់ធ្វើយ ឈ្លានពាន ។ ទៅរងវេទនា លុះមកកើតជា មនុស្សភាសាមាន្យ រូបអាក្រក់ខុស ទីងមនុស្សគ្រប់ ប្រាណ ពាក្យពោលមិនមាន ជាចូលចចិត្តគេ ។ តែស្តីកាលណា គេចឹងផ្តាសា គេជៀលដល់ម៉ែ ឧបទកម្មព្រាង អគ្គិឯងធ្វេសធ្វេ ធ្វេធ្វើឲ្យគេ អាប់អន់ចិន្តា ។ ហៃយក្សអើយថៅ នេះឯងហើយហៅ ផរុសវាចា រីអំពើកម្ម សម្ផប្បលាបា ជាទុកថា ពាក្យពោលទូជិន ។ ដូចនាលោកិយ៍ គេពប់អានអ្វី ថាពប់អានបុណ្យ សក្តាយឹនយស របស់ធានធន់ ជាតិជាបំណាន់ បំណាច់នៅបាន ។ ឯងស្តីបង្អន់ បង្អាប់ហើយបន្ថយពាក្យសន្តាន ស្លាប់ទៅនរក រងទុក្ខពុំស្រាន្ត បាប បទបង្ខាន បង្ខូចលាភគេ បើមកកើតជា មនុស្សឥតសក្តា រូបកា ទូរ ទូទន់ល្ងើល្ងង់ ឥតពន្លកស្នេហ៍ ជាអ្នកកំសែ កំសត់ទ្រព្យ ។ ឥតប្រាជ្ញឥតប្រាយ ពោះទីងធំយោយ ទៅទីងអ្នកណា គេចឹងក្រៃគ្រប់ ប្រទប់ផ្តាសា ហេតុពៀរពេក ដែលបង្អាប់គេ ។ ទាំងបួនប្រការ នេះហៅថា ទុច្ចរិតតែងតែ តាមទាន់ពុំសុខ ឲ្យទុក្ខឥតល្ហែ ព្រោះ ខ្លួនធ្វេសធ្វេ ធ្វើកម្មហៅ ។ យក្សស្តាប់ចូលចិត្ត ទូលថាបពិត្រ បុរសថ្លៃថ្លា ប្រាជ្ញប្រជិយក្ស ចូរអ្នកមេត្តា សំដែងវេក មនោទុច្ចរិត ។ ចូរអ្នកប្រាជ្ញទេស្នា ព្រះធម៌វិសេស ឲ្យយើងចូលចិត្ត វេរះវេក មនោ-ទុច្ចរិត តើពៀរដោយជិត ដូចម្តេចអាចារ្យ ។

ពោធិសត្វឆ្លើយ ថាហៃយក្ខអើយ បើអ្នកឯណា ធ្វើនូវមនៈ ទុច្ចរិតា(១) មួយចិត្តលោភា មួយចិត្តព្យាបាទ ៗ គេធ្វើអ្វីខ្លួន គិតពុំគន្លង តែងតាមប្រមាទ នៃនឹងអ្នកនោះ លង់លុះជន្មជាតិ ពៀរជាប់អង្គអាត្ម៍ ដល់ទិញ្ញានទាយ ៗ

( ចប់ខ្សែពីរតែបុណ្ណោះ ) ។

ដំណើរដំណាល ដំណាតកាល ពន្ធកញ្ញាណាញយ្យ សំដែងធម្មសម្មាថ្វាថ្ងៃ នៅក្នុងព្រឹក្សព្រៃ ទុន្មានយក្សា ៗ ហៅខ្សែបីបាន ពង្រ-ពោធិញាណ សំដែងធម៌ថា យក្ខអើយទុច្ចរិត ដោយចិត្តនេះណា នៅវិនាសប្រា-កដពុំដែលខាន ៗ វិចិត្តមិច្ឆា- ទិដ្ឋិដូចជា ព្រះស្តែងគ្រប់ថ្ងៃណា ព្រះស្តែងសព្វថ្ងៃ មមៃស្មោះស្មាន ថាជាពុំមាន ពុំនៀរវេរ ៗ ឃើញខុសជាត្រូវ ទឹងនាំខ្លួនទៅ រង់ទុក្ខវេទនា គួរប្រែគួរប្រាស គួរលះគួរលា វាងដប់ប្រការ សឹងពុំប្រពៃ ៗ នេះលោកហៅថា ពុំមែនធម្ម វិធម៌ថ្លាថ្លៃ វិះសសជ្រាលជ្រៅ ទូទៅគតត្រៃមនុស្សសត្វសព្វថ្ងៃ សឹងសាន្តសុខា ៗ គឺទុច្ចរិត វាងបីបទពិតជាដប់ប្រការ ឥតអ្វីប្រៀបត្រឹម ទឹងដូចឧបមា ព្រះស្តែងពល់គ្នាគួរវៀរទុច្ចរិត ៗ កាន់សុចរិតា ( វាងដប់ប្រការ ) ប្រើប្រាស់ប្រុងចិត្តផញ្ញាប់ផញ្ញឹង រំពឹងគន់គិត ជាទិពិទត ពិនាក់រូបបាន ៗ វរៈយានោយានៈសេដ្ឋា រៃងនានាំប្រាណ ទៀងទៅដាក់ដល់ ត្រើយថ្នល់ទិញ្ញានលះលោកលែងខាន កំណើតទុជា ៗ

(មានត)

---

(១) គឺមនោទុច្ចរិត ។ (២) ច្បាប់ដើមបាត់ នេះជាឃ្លាថែមថ្មី ។

# រឿងសាមកុក

## កំណាទី ២៨

ឧកញ៉ាវិបុលរាជសេនា ង្វ-ហ៊ិង ប្រែរៀបរៀង

(តមក)

| |
|---|
| រឿងសាមកុកទុកជាយុទ្ធសាស្ត្រ<br>អ្នករាងវៃឆ្លាតបើបានអាន<br>នឹងបេះឧបាយកលបំណាន<br>ទាំងមានសណ្ដានស្នេហាជាតិ ។ |

ខណៈតាំងតែព្រះចៅហៀនតេ ស្ដេចទៅប្រថាប់នៅក្រុងហ៊ូតោបាន១៨ ព្រះវស្សា លុះដល់ខែមាឃខាងខ្នើត ចូឆូចាត់ប្រើហាហ៊ូទុនទឹងហ៊ុនថងឲ្យ លើកទាហានទៅនៅក្បាលស្រុកយីឡាំ ប្រយោជន៍នឹងកពំងទាំងទ័ពលៀវ ប៉ៀវ កុំឲ្យចូលទៅមកបាន, ឲ្យស៊ិនហុកទឹងចៅយិននៅក្បាលស្រុកហ៊ូតោ ឯខ្លួនចូឆូក៏ប្រមូលពលទាហានបានច្រើន លើកចេញទៅ បំណងនឹង វាយយកស្រុកអ៊ួនសៀវ ៗ លុះទៅដល់មាត់ទន្លេហ្វាងហោក៏ឲ្យចូលទៅ តាំងបន្ទាយនៅចាំស្ដាប់ដំណឹងអ៊ួនសៀវ ។

ឯអ៊ួនសៀវលុះចូលឆ្នាំថ្មីក៏ស្រាកស្រាលជម្ងឺ ទើបចាត់ចែងសេនាទាហានទឹងលើកទៅវាយយកទីក្រុងហ៊ូតោ ៗ សឹមផោយក៏និយាយហាមឃាត់ ថាកាលគ្រាមុនលោកក៏ចង់ការទឹងចូឆូនៅដំបន់គួតមួង នៅដំបន់ស៊ិន

គេនឹងម្ដង ខូចខាតទាហានច្រើនណាស់ ឯទាហានដែលសល់នៅតាំងប៉ុន្មាន ក៏ពុំទាន់បាត់ហត់នឿយនៅឡើយ សូមឲ្យលោកការង់បង្អង់ឲ្យទាហានមាន កំឡាំងសិនរួចសឹមគិតការតទៅទៀត ។

# កណ្ឌទី ២៩

តាំងពីអ៊ួនស៊ុងសូមយកអាសាចេញទៅវាយទ័ព ហើយបរាជ័យនឹងចូឆូ អ្នកសៀវស្លាប់ អ៊ួនស៊ុងតាំងខ្លួនជាធំ ចូឆូលើកទ័ពទៅវាយស្រុកកេងជីវ សឹមដោយធ្វើកលយកទង់ជ័យ ជោគឡើង ។

ខណៈនោះ មានអ្នកបំរើម្នាក់ជិះសេះមកជំរាបអ៊ួនសៀវថា ចូឆូលើកកងទ័ពមកបោះបន្ទាយនៅក្បែរមាត់ទន្លេហ្វាងហោ តាមដំណឹងថានឹងលើកមកវាយឲ្យដល់ស្រុកគីជីវ ។ អ៊ួនសៀវឮហើយក៏និយាយនឹងស៊ឹមផោយថា យើងនឹងលើកកងទ័ពទៅវាយស្រុកហ៊ូគោ អ្នកមកហាមឃាត់មិនឲ្យលើកទៅ ឥឡូវចូឆូក៏លើកកងទ័ពមកហើយ អ្នកនឹងស្ងៀមនៅឲ្យកងទ័ពមកដល់ជើងកំពែងស្រុកឬ? គ្រានេះ យើងនឹងលើកកងទ័ពទៅរំលាងចូឆូចេញឲ្យបាន ។ អ៊ួនស៊ិនជាបុត្រនិយាយនឹងបិតាថា វេលានេះ បិតាមានជម្ងឺឈឺមិនសប្បាយ ជម្ងឺទើបតែនឹងគ្រាន់បើ មិនទាន់ជាស្រឡះ ដែលនឹងលើកកងទ័ពទៅនោះ ពេកក៏នឹងកើតរើកខ្លាំងឡើងថែមទៀត ខ្ញុំបាទនឹងសូមយកអាសាលើកទាហានទៅធ្វើការសង្គ្រាមនឹងចូឆូ ។ អ៊ួនសៀវក៏យល់ព្រមផង ហើយចាត់ចែងធ្វើសំបុត្រ ឲ្យទៅបង្គាប់បញ្ជូនកងទ័ពពីស្រុកសឿនជីវ, ស្រុកអីវជីវ, និងស្រុកប៉េងជីវ ឲ្យមកបញ្ចូលគ្នានឹងអ៊ួនស៊ុង

នោះតាំងពីគ្រាបានចេញចម្បាំងសម្លាប់ស៊ុយហ៊ុនស្លាប់ ក៏មានចិត្តកំរើកខ្លាំងណាស់ ។

កាលអ៊ុនសៀវឲ្យទៅបញ្ជូនកងទ័ពទាំងពីរមណ្ឌលនេះ អ៊ុនស៊ីងក៏មិនបានរង់ចាំ ខំលើកទាហានប្រហែល ៥ ម៉ឺនថ្លាយ ស្រុតរូតទៅតាំងបន្ទាយផ្ទាប់គ្នានឹងបន្ទាយចូង ។ ឃើញដូច្នោះក៏ប្រើទៀវលៀវឲ្យលើកទាហានចេញទៅចម្បាំងនឹងអ៊ុនស៊ីង ។ ក៏បរសេះកំចួចចូលប្រយុទ្ធគ្នានឹងទៀវលៀវបាន ៣ ក្ងង អ៊ុនស៊ីងគ្រាំទឹងកំឡាំងទៀវលៀវមិនបានក៏ញាក់សេះរត់ ។ ទៀវលៀវបរសេះដេញតាក់កាប់សម្លាប់ទាហានអ៊ុនស៊ីងពីក្រោយស្លាប់ជាច្រើន អ៊ុនស៊ីងក៏នាំទាហានដែលសល់ទាំងប៉ុន្មាន រត់ត្រឡប់ចូលទៅក្នុងស្រុកគីជីវិញ ។

ចំណែកអ៊ុនសៀវកាលដឹងថា អ៊ុនស៊ីងបែកទ័ពរត់មក ក៏ស្រុតរន្ធត់ចិត្ត ពេគនោះក៏បណ្តាលកំរើកឡើង គគ្រុកក្អកស្ទុះតែឈាមហូរចេញមកប្រហែលជា ១ ចាំង នាងឡៅជីជាភរិយាឃើញដូច្នោះក៏ភ័យស្លុតស្មារតី ទើបនាំពួកស្រីបំរើរាំងពួងគ្រាហ៍ត្រកងយកអ៊ុនសៀវចូលទៅដាក់ឯល្វែងក្នុង ហើយឲ្យហៅសឹមផោយ ហាងគីចូលមកប្រឹក្សាដែលនឹងតាំងឲ្យអ៊ុនស៊ីងធ្វើជាចៅហ្វាយស្រុកគីជីជំនួសខ្លួន នោះទៅ ។

ខណៈនោះអ៊ុនសៀវភ្ញាក់ស្មារតីឡើង បានព្រះហើយតែនិយាយមិនរួច គ្រាន់តែយកម្រាមដៃចង្អុលត្រង់ដើមទ្រូងខ្លួនឯង ។ នាងឡៅជីឃើញអ៊ុនសៀវយកម្រាមដៃចង្អុលដើមទ្រូងដូច្នោះ ក៏ចូលចិត្តថាឲ្យអ៊ុនស៊ីងចៅហ្វាយស្រុកទើបកុងស្វរអ៊ុនសៀវទៀតប្រាជ្ញាថានឹងឲ្យមនុស្សទាំងអស់នៅ

ទីនោះព្ធជាបន្ទាល់ថា ស្រុកគីជីវនេះនឹងឲ្យអ៊ួនស៊ីនឬ? អ៊ួនសៀវនិយាយមិនរួចក៏ញាក់មុខល្មមតែខ្យល់ដង្ហើមដកមកផុត ក៏ក្រែកដោយសំឡេងខ្លាំង ហើយក៏ញាក់ជើងបរដាច់ខ្យល់ស្លាប់នោះទៅ ។

សឹមផោយទឹងហងគី ឃើញអ៊ួនសៀវស្លាប់ហើយ ក៏នាំគ្នាតាក់តែងការសពតាមទំនៀម ។ ឯងឡាដីក៏ឲ្យយកខ្ទួននាងទាំង៤នាក់ជាភរិយាបន្ទាប់ៗដែលអ៊ួនសៀវស្រឡាញ់នោះទៅសម្លាប់ទាំងអស់ ហើយនៅគិតប្រចណ្ឌខ្លាចជាស្លាប់ទៅ ហើយទឹងទៅជួបគ្នានឹងអ៊ួនសៀវ ។ ទឹងចង់មេត្រីស្រឡាញ់ស្រីទាំងនោះទៀត ក៏ឲ្យយកដាវមកកាត់សក់កាត់ជើង ហើយជញ្ជ្រាំ សាច់មុខឲ្យទៅជារបួសស្នាកស្នាម ប្រាថ្នាទឹងឲ្យអ៊ួនសៀវស្អប់ខ្ពើមរអើម ហើយឲ្យយកសពស្រីទាំង ៤ នាក់នោះទៅចោល ។ អ៊ួនស៊ីនឃើញមាតាធ្វើដូច្នោះ ក៏គិតបារម្ភក្រែងញាតិបងប្អូនរបស់ស្រីទាំង ៤ នោះ មានចិត្តព្យាបាទអាឃាតគំគួនដល់មាតាទឹងខ្លួន ទើបប្រើទាហានទៅចាប់យកពួកញាតិសាលោហិត ស្រីទាំង៤នាក់នោះមកប្រហារជីវិតទាំងអស់ ។ ឯសឹមផោយទឹងហងគី ក៏រៀបចំតាក់តែងលើកអ៊ួនស៊ីនឲ្យឡើងទទួលស័ក្តិទីពដការជាចៅហ្វាយស្រុកគីជីវ ហើយធ្វើសំបុត្រចាត់ប្រើទាហានឲ្យកាន់យកទៅឲ្យដល់ អ៊ួនថាំ, អ៊ួនហ៊ីនឹងគោកទថា:"ឥឡូវអ៊ួនសៀវជាបិតាយើងទទួលអនិច្ចកម្មទៅហើយ " ។

ឯអ៊ួនថាំលើកកងទ័ពមកដល់ជិតស្រុកគីជីវ ទទួលប្រទះអ្នកកាន់សំបុត្រដឹងហេតុសព្វគ្រប់ថាបិតាស្លាប់ហើយ ក៏ប្រឹក្សានឹងគួ.តៅ ស៊ុនបេងថា ឥឡូវបិតាយើងអនិច្ចកម្មទៅហើយ :យើងនឹងគិតប្រការម្តេច?គួតៅឆ្លើយថា

ខ្លួនលោកជាបុត្រច្បងហើយមិនបាននៅក្នុងស្រុក ខ្ញុំបាទឃើញថាសឹម
ផោយនឹងហងគីនឹងឲ្យអ៊ួនស៊ុងធ្វើចៅហ្វាយស្រុកជំនួសបិតាលោក សូម
ឲ្យលោកប្រញាប់លើកទ័ពចូលទៅក្នុងស្រុក ហើយឲ្យនាម៉ឺនមុខមន្ត្រីប្រឹ-
ក្សាការតាមទំលាប់ប្រវេណីទើបគួរ ។ ស៊ុនបេងតបថា ដែលនឹងឲ្យអ៊ួន
ថាំចូលទៅដល់ក្នុងស្រុកនោះមិនបានទេ ព្រោះសឹមផោយនឹងហងគីជា
ដើមគំនិត ខ្លាចក្រែងធ្វើកលទុកប្រការម្តេច អន្តរាយនឹងមានដល់យើង ។
គួតៅឆ្លើយថា ដែលអ្នកសង្ស័យដូច្នោះត្រូវហើយ គួរឲ្យឈប់ទ័ពនៅទី
នេះចុះ តែខ្លួនខ្ញុំម្នាក់ឯងនឹងសូមអាសាចូលទៅក្នុងស្រុក ស្តាប់ការណ៍
មើលល្អអាក្រក់ឲ្យច្បាស់ ហើយនឹងបានគិតការតទៅ ។ អ៊ួនថាំនឹងស៊ុន
បេងក៏យល់ឃើញព្រមផង គួតៅក៏លាអ៊ួនថាំចូលទៅជួបនឹងអ៊ួនស៊ុង ។ ក៏
សួរគួតៅថា៖ អ៊ួនថាំបងយើងមកដែរឬទេ ? គួតៅជំរាបថា អ៊ួនថាំឃើញ
សំបុត្រដែលឲ្យប្រញាប់លើកកងទ័ពមក នោះក៏ស្រូតលើកមកឈប់ទ័ពនៅ
ក្រៅស្រុក តែអ៊ួនថាំកើតបច្ចុប្បន្នពេទនឹងមកមិនបាន ឥឡូវប្រើឲ្យខ្ញុំបាទចូ-
លមកស្តាប់ដំណឹង ជានឹងលើកទ័ពទៅច្បាំងនឹងចូចូវេលាណា អ៊ួនស៊ុង
ឆ្លើយថា កាលបិតាទៅមិនទាន់អនិច្ចកម្មនោះ បានផ្តាំទុកឲ្យយើងទទួលរាជ
ការធ្វើចៅហ្វាយស្រុកគីជីវ ឲ្យអ៊ួនថាំនោះគង់នៅជាចៅហ្វាយស្រុកសៀង
ជីវ ឥឡូវចូចូលើកកងទ័ពមកតាំងនៅមាត់ទន្លេហ្វាងហោ ដូច្នេះចូរអ្នកទៅ
ប្រាប់អ៊ួនថាំឲ្យទៅធ្វើសង្គ្រាមតទល់នឹងចូចូមុនចុះសឹមយើងស៊ើបយើងលើក
កងទ័ពទៅជួយ ។ គួតៅតបថា អ៊ួនថាំផ្តាំនឹងខ្ញុំបាទឲ្យមកជំរាប លោក
ថា ក្នុងកងទ័ពដែលលើកមកវេលានេះ នឹងរកអ្នកឯណាឲ្យមានដម្រេះ

ប្រាជ្ញាធ្វើជាទីប្រឹក្សាការសឹកសង្គ្រាមគ្មានសោះ អ៊ួនថាំឲ្យថាសូមសឹមជាមួយ
ទីនហានគី ទៅជាមួយផងទីនបានជួយគិតការគ្នា ។ អ៊ួនស៊ីនឆ្លើយថា
ដែលយើងទីនលើកទ័ពដាក់ហ្វូងទៅវេលានេះ ក៏ដោយអាស្រ័យតែគំនិត
របស់បឹមដោយទីនហានគីប៉ុណ្ណោះ បើអ៊ួនថាំឲ្យមកសុំយកទៅហើយ
យើងទីនបានរណាធ្វើទីប្រឹក្សា ។ គួគៅដឹកបថា បើលោកមិនឲ្យ
ទាំងពីរនាក់ ក៏សុំតែសឹមដោយឬហានគីតែម្នាក់ណាមួយទៅផងក៏បាន ។
អ៊ួនស៊ីនមិនដឹងកល់ទុបាយ មិនហ៊ានទទឹងតាស់ ដោយបារម្ភចិត្តអ៊ួនថាំជា
បង ទើបសរសេរឈ្មោះសឹម ដោយទីនហានគីទាំងពីរនាក់ឲ្យចាប់ឆ្នោត
បើចាប់ត្រូវលើឈ្មោះណាមុន ក៏ឲ្យអ្នកនោះទៅ ។ អ៊ួនស៊ីនសរសេរហើយ
ក៏ចាប់ត្រូវលើឈ្មោះហានគី ទើបបង្គាប់ឲ្យហានគីទៅជាមួយទីនគួគៅហើយ
អ៊ួនស៊ីនធ្វើសំបុត្រផ្ញើទៅដល់អ៊ួនថាំថា យើងប្រើហានគីមកជាទីប្រឹក្សា
ឲ្យអ៊ួនថាំលើកជាកងមុខចូលទៅធ្វើសង្គ្រាមទីនបួរ យើងទីនលើកកង
ហ្លួងទៅជួយ ។ គួគៅទីនហានគីទទួលសំបុត្រហើយក៏លាអ៊ួនស៊ីនចេញ
ទៅដល់កងទ័ពអ៊ួនថាំ ។ ហានគីឃើញអ៊ួនថាំមិនមែនឈើដូចពាក្យ
គួគៅនិយាយ ក៏គិតក្នុងចិត្តមិនសប្បាយ គួគៅក៏ជូនសំបុត្រទៅឲ្យអ៊ួន
ថាំមើល ។

(មានត)

# រឿងហ្គូឌិក

រលតែនិពន្ធ

## លោក រ៉ាយ-ប៊ុក រៀបរៀង

(តមក)

---

## វគ្គទី ៦ រដ្ឋមន្ត្រី

ចំណែកលោកហ្គូឌិតឋិតនៅក្នុងតំណែងនាយករដ្ឋមន្ត្រីនេះមិនបាន យូរប៉ុន្មាន ក៏មានពួកបច្ចាមិត្រធ្វើឧបាយឲ្យធ្លាក់លោកពីតំណែងនេះ ហើយ ត្រូវហូតងារចេញឲ្យទទួលទណ្ឌកម្ម បំបរបង់ចេញពីនគរទៅ ។

លោកហ្គូឌិតក៏រត់ចេញពីកដនាវបាបទៀន ធ្វើដំណើរទៅកាន់ ប្រទេសអេស៊ីប្ត ។

## រឿងនារីដែលគេវាយជាដំណាំ

ពេលយប់លោកហ្គូឌិតក៏រត់ចេញពីទីក្រុងបាបទៀន ; លោក ក្រឡេកមើលតាមលើមេឃមានផ្កាយក្រពើជាដើម, ហើយលោកត្រាច់ ទៅតាមផ្កាយនោះទៅ ។

លោកបានពិចារណានូវតារាទាំងនោះ ដែលគេទុកជាដុំស្មើធំនៅលើ មេឃ បើតាមភ្នែកក្រឡេកទៅជាតែតូចមួយក្ដិតៗ ។ ចំណែកឯផែន ដីដែលជាតែតូចណាស់ស្មើរមើលពុំឃើញ, បើតាមចក្ខុរបស់យើង ទៅជា តែធំសម្បើមអស្ចារ្យណាស់ទៅវិញ ។

លោកបានគិតអំពីមនុស្សក្នុងស្ថានភាពសម័យបច្ចុប្បន្ន ពួកបាណក

សត្វស្ថិតនៅលើដុំភក់មួយ ហើយខាំដណ្ដើមស៊ីគ្នាទៅវិញមក ហើយរូប
ពិតនោះក៏បញ្ចេញអារម្មណ៍ក្នុងមនោទ្វារាវជ្ជនៈរបស់លោក ធ្វើឲ្យវិនាស
នូវសេចក្ដីព្រួយលំបាកទាំងនោះ ដោយបង្ហាញសភាពទទេឥតខ្លឹមសារនៃ
រូបលោកទាំងទីក្រុងបាប៊ីឡូន ។

ចិត្តរបស់លោកក៏ផ្លោះឡើងទៅកាន់លោកធាតុ ហើយលោកក៏បានពិ
ចារណាចំពោះការរៀបចំបទបញ្ញត្តិច្បាប់ ក្នុងចក្រវាឡ ។ ប៉ុន្តែ, ដល់ចិត្ត
លោកវិលត្រឡប់មកកាន់ខ្លួនលោកវិញ លោកក៏បានគិតអំពីជាតកសន្ទា
របស់លោកៗក៏បានឃើញចំពោះធម្មជាតិទាំងមូល តែលោកហ្សាឌិគបិត
នៅក្នុងស្ថានភាពដ៏លំបាកប៉ុណ្ណោះ ។

ក្នុងពេលដែលលោកកំពុងពិចារណានូវទស្សនវិជ្ជាដ៏ប្រសើរនឹងទទួល
នូវទុក្ខលំបាកជាអនេកប្បការ លោកក៏បានធ្វើដំណើរទៅព្រំប្រទល់
ប្រទេសអេស៊ីប ។ ក្នុងពេលនោះ ទាសាដែលមានចិត្តស្មោះស្ម័គ្រនឹងលោក
បានទៅដល់ភូមិមួយជិតព្រំប្រទល់ កំពុងតែស្វែងរកទីស្នាក់អាស្រ័យដែរ ។

ដល់លោកហ្សាឌិគអញ្ជើញទៅដល់ភូមិនោះ លោកក៏ឆ្លៀតឱកាស
អញ្ជើញទៅលេងកំសាន្តឯទន្លេដែលបិតនៅចុងភូមិ ។ ក្នុងពេលនោះ
លោកបានក្រឡេកពីថ្នល់ធំទៅ ឃើញនារីម្នាក់យំទួញស្រែកអំពាវនាវឲ្យ
មេឃនឹងនាងគង្ហីងព្រះធរណីជួយនាង ហើយមានបុរសម្នាក់កាចសាហាវ
ដើរតាមពីក្រោយ ។ បុរសនោះក៏ដេញនាងទាន់ នាងកំពុងឱបក្បាល
ជង្គង់អង្វរបុរស ដោយពោលពាក្យគ្រប់យ៉ាង ។ បុរសនោះមិនតែ
បន្ទោសនាង ដោយពាក្យគ្រគោះបោះបោកផ្សេងៗនោះទេថែមទាំង

វាយដំច្រំបាក់នាងទៀត ។ លោកក៏បានពិនិត្យមើលអាការៈដ៏ឃោរឃៅនៃបុរសជាជនជាតិអេស៊ីប និងអាកប្បកិរិយារបស់នាង ដោយពោលពាក្យអង្វរទៅកាន់បុរស ក៏យល់ថាបុរសជាអ្នកប្រណែន ហើយនារីនោះជាអ្នកក្បត់ស្វាមី ។ តែដល់លោកពិនិត្យចំពោះស្ត្រីនោះដែលមានរូបឆោមលោមពណ៌ស្រស់ប្រិមប្រិយ, លោកក៏មានចិត្តអាណិតអាសូរដល់នាង ហើយមានចិត្តស្អប់បុរសជាជនជាតិអេស៊ីបនោះទៅវិញ ។

នាងក៏ស្រែកឲ្យលោកហ្សាឌិគជួយនាង ដោយពោលពាក្យថា: "សុំអ្នកជួយស្រោចស្រង់ខ្ញុំ ចូរអ្នកទាញខ្ញុំ ឲ្យផុតពីកណ្តាប់ដៃពីទុជនបុរសកាចកំពេលបួនជ្រុង សុំលោកជួយជីវិតខ្ញុំផង" ។

ដោយឮបម្រែកដូច្នេះ លោកហ្សាឌិគក៏រត់ទៅឈរនៅស្ងៀមរវាងនាងនិងបុរសនោះ ។ លោកមានចេះភាសាអេស៊ីបខ្លះដែរលោកក៏ពោលជាភាសានោះថា: "បើអ្នកមានចិត្តសប្បុរសខ្លះ ខ្ញុំសូមចិត្តអ្នក ឲ្យគោរពចំពោះ លំអរនិងទុព្វលភាពនៃស្ត្រីនេះ ។ តើអ្នកឯងនឹងធ្វើឲ្យខូចខូរលំអរដ៏ថ្លៃថ្លានៃធម្មជាតិដែលបិតនៅជិតដើមដែលមានតែទឹកក្អកជាគ្រឿងការពារ ។

បុរសនោះខឹងប្រឡោតស្រែកទៅកាន់លោកហ្សាឌិគថា: "ឯងស្រឡាញ់ស្ត្រីនេះដែរហើយអញត្រូវតែសងសឹកចំពោះឯងនេះវិញ" ។

បុរសនោះពោលដូច្នេះ ក៏បោះបង់ចោលនាង ដែលគាត់ចាប់ទាញសក់ហើយក៏ស្ទុះទៅកាន់លំពែង ដើម្បីនឹងលោតមកចាក់លោកហ្សាឌិគ ។ មានស្មារតីវៃ ក៏បានគេចផុតហើយស្ទុះទៅចាប់លំពែងគ្រង់ពាក់

កណ្តាលជនអ្នកទាំងពីរនាក់ ក៏ប្រព៉ាភាញលំពែងនោះទៅវិញទៅមក លំពែងនោះក៏បាក់ខ្ទេចខ្ទីអស់ ។ បុរសនោះហូតដាវរបស់ខ្លួន លោកហ្វាឌិតក៏ហូតដាវដែរ ហើយក៏ស្ទុះទៅកាប់គ្នាទៅវិញទៅមក ។ ជនសញ្ជាតិអេស៊ីប្ទបានកាប់លោកហ្វាឌិតមួយរយដង តែលោកចេះតែការពារបាន ។ ស្ត្រីនោះអង្គុយលើស្មៅ ក៏រៀបចំមួកខ្លួនឲ្យបានស្រួលបួល ក្រឡេកមកអ្នកទាំងពីរកំពុងគុនដាវ ។

ជនសញ្ជាតិអេស៊ីប្ទមានកាយដ៏មាំមួនជាងលោកហ្វាឌិត តែលោកហ្វាឌិតរៀនវៃប៉ិនប្រសប់ជាងគេ ក៏បានធ្វើឲ្យសត្រូវធ្លាក់អាវុធពីដៃចូលទៅចាប់កៀកគ្នា ធ្វើល្បិចកល់ឲ្យសត្រូវនោះដួល ហើយក៏ក្រវៃដាវយកមកដាក់ចំលើដើមទ្រូង តែលោកទុកជីវិតសត្រូវនោះ ឲ្យរស់នៅ ។

ក្នុងពេលដែលលោកហ្វាឌិត មានចិត្តសន្តោសត្រាប្រណី ជនសញ្ជាតិអេស៊ីប្ទៈដោយចិត្តខឹងហួសប្រមាណ ក៏យកដាវស្ទុះមកចាក់លោកហ្វាឌិតតែលោកគេចរួច ក៏យកដាវចាក់ចំដើមទ្រូងសត្រូវដួលស្លាប់ក្នុងពេលនោះទៅ ។

លោកហ្វាឌិតខិតចូលទៅជិតនារីហើយនោះ ពោលដោយវាចាស្រទន់ថា: "បុរសនោះបានបង្ខំឲ្យខ្ញុំសម្លាប់គាត់" ។ ខ្ញុំក៏បានសងសឹកជូននាងហើយ នាងបានរួចពីកណ្តាប់ដៃបុរសដែលមានចិត្តពាលឃងឃ្នងបំផុត ដែលខ្ញុំមិនដែលឃើញសោះ ។ តើឲ្យខ្ញុំធ្វើអ្វីទៀតចំពោះនាង.... ។

—នាងនោះក៏តបទៅលោកហ្វាឌិតវិញថា: "អញចង់ឲ្យឯងស្លាប់ ឯងត្រូវតែស្លាប់ ព្រោះឯងបានពិឃាដសង្សាររបស់អញ ៗ អញចង់តែហែក

បេះដូងឯងស៊ីទាំងរស់ ..." ។

លោកហ្វ្រេឌិកក៏តបទៅវិញថា: "នាងឯងមានបុរសសង្សារប្លែកពីបុរសទាំងឡាយ ៗ សង្សារនេះវាយដំប្រំជាក់នាងឯងឥតមានត្រាប្រណីហើយ....." ។

នាងនោះក៏តបទៅលោកហ្វ្រេឌិកទៅទៀតថា: "អញចង់ឲ្យគាត់វាយអញទៀត អញត្រូវតែគេវាយដូច្នេះឯង ព្រោះអញធ្វើអំពើមិនគួរគប្បី នាំឲ្យគាត់ប្រណែនចំពោះខ្លួនអញ ៗ លុះហើយគាត់វាយអញ ៗ ចង់ឲ្យឯងស្ដាប់ផ្លូសគាត់ ឲ្យគាត់សេមកវាយអញទៀត" ។

លោកហ្វ្រេឌិកទឹកនៀងឆ្ងល់ហើយមានចិត្តខឹងពន់ប្រមាណ ក៏ឆ្លើយតបទៅនាងវិញថា: "ឱនាង, នាងឯង. ពិតមែនតែមានរូបឆើតឆាយ នាងឯងគួរតែអញវាយទើបសម ព្រោះនាងឯងប្លែកពីស្ត្រីធម្មតា តែអញមិនធ្វើទេ វាស្អុយដៃអញ...." ។

លំដាប់តមក លោកហ្វ្រេឌិកក៏ជិះឧទ្ធតម្រង់ទៅភូមិនោះទៅ ៗ ក្រោយដែលលោកចេញពីទីនោះបន្តិច ស្រាប់តែឮសូរជើងសេះបួនជាយមកពីទីក្រុងបាប៊ីឡោន ៗ មានអ្នកជិះសេះម្នាក់ក្រឡេកឃើញនាងនោះក៏ពោលពាក្យថា: "នាងនេះឯង" ហើយមានអ្នកជិះសេះទាំងប៉ុន្មានក៏ចាប់នាងព្រានាក់លើខ្នងសេះបោលទៅ នាងនៅតែស្រែកឲ្យលោកហ្វ្រេឌិកជួយ ដោយវាចាផ្អែមល្ហែមថា: "ឱអ្នកមហាសប្បុរសអើយសូមលោកអ្នកអាណិតអាសូរដល់រូបនាងខ្ញុំផង នាងខ្ញុំសុខចិត្តបម្រើលោករហូតដល់ផុតជីវិតឥន្ទ្រិយ...." ។

លោកហ្វ្រេឌិក ក៏ពោលតបទៅនាងវិញថា: នាងឯងឲ្យអ្នកណា

យកចុះ ឯខ្ញុំលែងចាញ់បោកនាងឯងទៀតហើយ ។

លំដាប់តមក, លោកហ្វាឌិត; ក្រោយដែលបានធ្វើដំណើរទៅកាន់ប្រទេសផ្សេងៗក៏វិលត្រឡប់មកកាន់ប្រទេសអេសិប្ត ដដែលវិញ ។ នៅទីនេះលោកបានយកបុរសមួយនាម "សេតុក" ជាមិត្រ ។

លោកសេតុក ត្រូវមានកិច្ចធ្វើពាណិជ្ជកម្ម ហើយត្រូវធ្វើដំណើរទៅកាន់កោះសេរង់ឌីប, តែលោកទើបនឹងរៀបរាប់មង្គលការជាបឋមមិនអាចនឹងឃ្លាតចេញពីភរិយារបស់លោក ដែលជាទីគាប់ចិត្តបាន ។ លោកសុំឲ្យលោកហ្វាឌិត អញ្ជើញទៅកាន់កាប់មុខជំនួញនោះជួសលោកសិន ។

លោកហ្វាឌិតក៏បានព្រមព្រៀង ធ្វើដំណើរទៅកាន់កោះសេរង់ឌីបជំនួសលោកសេតុក ដែលទើបនឹងមានភរិយាថ្មី ។ លុះលោកហ្វាឌិតអញ្ជើញទៅដល់ទីនោះ លោកទៅជាអាជ្ញាកណ្តាល សម្រេចការរ៉ាទរ៉ាងពួកឈ្មួញពាណិជ ជាកល្យាណមិត្រពួកបណ្ឌិត ហើយជាទីប្រឹក្សាពួកណា ដែលត្រូវការយោបល់អំពីលោក ។ កិត្តិសព្ទនៃលោកហ្វាឌិតក៏ផ្សាយទៅដល់ព្រះបរមរាជវាំងព្រះមហាក្សត្រនៃកោះសេរង់ឌីប ទ្រង់មានព្រះរាជបំណងចង់ឃើញលោកហ្វាឌិតនោះណាស់ ។ លុះលោកហ្វាឌិតចូលទៅក្រាបបង្គំគាល់ព្រះអង្គ ។ ទ្រង់ក៏មានព្រះរាជឧង្ការសួរសព្វគ្រប់ប្រការ ទ្រង់យល់ជាក់ច្បាស់ថាលោកហ្វាឌិតជាអ្នកមានប្រាជ្ញាពិតមែន; មានព្រះរាជហឫទ័យទុកចិត្តចំពោះគតិបណ្ឌិតដែលលោកហ្វាឌិតបានក្រាបបង្គំទូល ហើយទ្រង់យកលោកនេះធ្វើជាមិត្ររបស់ព្រះអង្គនោះទៅ ។

(មានត)

## អំពីបងប្អូនពីរនាក់

និង

## មាន់ឆ្នាក់

(តចប់)

# លោកទៀង-តែឈុន ប្រែរៀបរៀង

លុះព្រះមហាក្សត្រ ដែលមិនទ្រង់ជ្រាបថា មានស្រីទេពអប្សរពីរនាក់នេះ ពួននៅក្នុងក្អមនេះ ស្រាប់តែកើនឡើង ហើយទតឃើញព្រះស្ងោយ ដែលទំនងជាមានឱជារស យ៉ាងឆ្ងាញ់ក្រៃលែងនេះ ក៏លាន់ព្រះឱស្ឋថា " អញអត់អាហារ ៧ ថ្ងៃហើយ ឥឡូវនេះ អញឃើញអាហារយ៉ាងអស្ចារ្យនេះ ! អ្នកណាធ្វើអាហារនេះ ទុកឲ្យអញ ឬអាទិ-ទេពនិម្មិតមក ឬ បុរសណាធ្វើអាហារនេះ លាយនឹងថ្នាំពុល ដោយមានគោលបំណង នឹងសម្លាប់អញ បើទុកជាយ៉ាងណាក៏ដោយ អញត្រូវតែស្លាប់ ដោយអញខ្សោយមកពីអត់អាហារ ឬ ដោយថ្នាំពុល អញត្រូវតែស៊ីអាហារនេះសាកមើល ហើយទោះបីយ៉ាងណា ក៏អញបានរួចអំពីសេចក្តីឃ្លានមួយសិនដែរ" ! ទ្រង់ប្រថុយសោយព្រះស្ងោយ អស្ចារ្យនេះ ដែលមានឱជារស គួរឲ្យជាប់ចិត្ត ៗ លុះសោយរួចហើយ ទ្រង់មានព្រះទ័យធូរស្បើយ ប្រកបដោយសុខុមាលភាព យ៉ាងបរិបូណ៌ រួចពីនោះមកទៀត ទ្រង់យកក្អមដីរមែកលាក់ទុក ហើយទ្រង់យកអ្នកនាក់ទីនមានយានធ្វើដំណើរទៅមុខទៀត ទ្រង់យាងមិនត្រោះទៅកន្លែងណាទេ នៅតែក្នុងព្រៃអស់ចំនួន ៧ ថ្ងៃ ៧ យប់ សោយតែផ្លែឈើ ហើយទ្រង់ពុំដែល

បានព្រះស្ងោយណា ក្រៅពីនេះមកសោយសោះ ។ នៅទីបំផុតទ្រង់អស់ព្រះកាយពល ហើយទ្រង់ឃ្លានព្រះស្ងោយ យ៉ាងក្រៃលែង ។ ទ្រង់ត្រិះរិះដូចតទៅនេះថា "ឱអញ ម្ដេចក៏វេទនាដល់ថ្នាក់នេះ! ពីព្រោះតែអញ មានបំណងចង់ប្រសើរធ្វើជាស្ដេចទៅទៀត ទើបអញប្ដូរនគរយកមាន់នេះ, ឥឡូវ អញធ្វើឲ្យវេទនា តែខ្លួនអញទៅវិញ"! រួចពីការត្រិះរិះនេះមក, ទ្រង់ប្រុះស្នឹងចងមាន់ ហើយរៀបចំដាក់អន្ទាក់ជាស្រេច ទើបទ្រង់យាងទៅពួនលបចាំមើលលទ្ធផល ដូចលើកមុនទៀត។

មាន់ទទះស្លាបរងាវ ៣ ដង ហើយចេះតែប៉ុកដី ។ បន្តិចមកស្ដេចមាសមកដល់ ឃើញហើយក៏ស្ទុះអស់ទំហឹងតម្រង់ទៅរកមាន់ ។ ស្រាប់តែកុយក៏ដាច់ពីថ្ងាស ធ្លាក់នៅជិតមាន់ ហើយក៏ត្រឡប់វិលចូលទៅព្រៃវិញ ។

នៅក្នុងកុយមាស មានស្ត្រីទេពអប្សរម្នាក់ លាក់បំពួនខ្លួន ។ បំណែកឯមាន់កកាយដី ត្របពីលើកុយមាសនោះហើយ ក៏ក្រាបប៉ប៉ុកដីទៅទៀត។

ព្រះមហាក្សត្រកាលបើទតឃើញស្ដេចមាស ស្ទុះអស់ទំហឹង ហាក់ដូចជាទៅចាំមាន់សម្លាប់ដូច្នោះ ក៏ទ្រង់ស្រែកថា "យីអើ! សត្វមាសនេះ មកពីណា ស្ទុះសំរុកទៅហែកមាន់អញស៊ី" បន្ទាប់មក ទ្រង់រត់យ៉ាងលឿនតម្រង់ទៅកន្លែងដែលទ្រង់ចងមាន់ ហើយទ្រង់សព្វព្រះរាជហឫទ័យដោយទតឃើញមាន់ កំពុងតែក្រាបប៉ប៉ុកដី ។ ទ្រង់ដកស្នឹងស្រាយមាន់ ពីចំណងយកមកបីនឹងព្រះហស្ត ។ នៅពេលនោះ ទ្រង់ទតឃើញកុយមាសធ្លាក់នៅទីនោះ ហើយទ្រង់រើសយកមក, ប៉ុន្តែទ្រង់មិនបាន

ជ្រាបថា មានស្រីទេពអប្សរម្នាក់ នៅក្នុងកុយមាសនោះទេ ។

ព្រះមហាក្សត្រ ទ្រង់យាងត្រឡប់មកដើមល្វា ហើយដោយព្រះអង្គទ្រង់អស់ព្រះកាយពលខ្លាំងពេក, ទ្រង់ក៏ដួលកស្កប់ស្កល់នៅទីនោះ ។

ស្រីទេពអប្សរ ដែលនៅក្នុងកុយមាស មើលឃើញថា ព្រះមហាក្សត្រ ទ្រង់ដួលកស្កប់ស្កល់ហើយអត់ព្រះស្ងោយ ក៏ចេញមករៀបចំព្រះស្ងោយទិព្វទុកដាក់ជិតព្រះអង្គ រួចចូលទៅក្នុងកុយមាសវិញ ។

លុះព្រះរាជាទ្រង់តើនឡើង ទតឃើញព្រះស្ងោយអស្ចារ្យនេះស្ថិតនៅជិត ទ្រង់គិតថា "អើ! អញបានអាហារដ៏មានឱជារសនេះស៊ីម្តងទៀតហើយ! ប៉ុន្តែ អ្នកណាអាចដឹងបានថា អាហារនេះគ្មានលាយថ្នាំពុល? ណ្ហើយចុះ បើអ្នកណាប្រាថ្នាចង់បំពុលអញ ៗ ត្រូវតែស្លាប់ទៅចុះ" លុះទ្រង់ពិចារណាដូច្នោះហើយ, ទ្រង់បានសោយព្រះស្ងោយនោះជាស្រេច ទើបទ្រង់មានព្រះហឫទ័យធូរស្បើយប្រកបដោយសុខុមាលភាពយ៉ាងបរិបូណ៌ ។

បន្ទាប់មក, ព្រះអង្គទ្រង់យាងធ្វើដំណើរតទៅទៀត, កាត់ពលចូលព្រៃចេញពីព្រៃកាត់ពល ៗ មានមួយថ្ងៃនោះ, ព្រះរាជាទ្រង់សព្វព្រះរាជហឫទ័យ ឈប់នៅត្រង់កន្លែងមួយ, ទ្រង់បោះស្នឹង ចងមាន់ ទឹងរៀបចំដាក់អន្ទាក់ដូចលើកមុន ៗ ទៀត ។ រួចស្រេច, ទ្រង់យាងទៅពួនលបចាំមើលលទ្ធផលនៅក្រោមដើមល្វា ។

ព្រះរាជាទ្រង់គ្មានទតឃើញលទ្ធផលអ្វីទាំងអស់ ដោយទ្រង់អស់ព្រះកាយពលខ្លាំងពេក, ទ្រង់ក៏ដួលកនៅទីនោះ ។

រីឯមាន់នេះ មានលក្ខណៈ ដែលជាហេតុ មិនឲ្យទាក់បានមាន់ញី ដូចមាន់ដទៃ ។

បន្ទាប់មក, មាន់ទទះស្លាបរងាវ ៣ ដង ។ ស្រាប់តែមានប្រាសាទមាស, ប្រាសាទប្រាក់, ផ្ទះគ្រប់បែប, ហាងលក់ទំនិញគ្រប់យ៉ាង ផ្លូវយ៉ាងល្អៗផុះឡើង ក្រចាំងក្រចែង មានពណ៌ក្រហមប្រាលឆ្អៅ ហាក់ដូចជាមានអគ្គិភ័យ នៅលើមាន់ដែលនៅក្នុងមុង ហើយមានកំពែងព័ទ្ធជុំវិញ ។

នៅពេលនោះ, ព្រះមហាក្សត្រតើនឡើង ស្រាប់តែទតឃើញអគ្គិភ័យរស់រវើកនេះ មានពន្លឺក្រហមព្រោងព្រាត ពាសពេញមហាមេឃ ។

ព្រះរាជាទ្រង់លាន់ព្រះឱស្ឋថា "យីអើ ! អ្នកណាដុតព្រៃ ? មាន់អញមុខតែនេះស្លាប់ហើយមួននេះ, អញវិញថ្ងៃស្អែកគេមួយតាំងមូល" រួចមក, ព្រះអង្គទ្រង់យាងរត់សំដៅទៅរកមាន់គ្រប់កន្ទុង ហើយទ្រង់មានព្រះចិន្តាស្តាយមាន់នោះយ៉ាងក្រៃលែង ។

នៅពេលដដែលនេះ, ទ្រង់ទតឃើញប្រាសាទមាស, ប្រាសាទប្រាក់ដែលផុះស្មើ ភ្លឺក្រហមប្រាលឆ្អៅ ប្រទាក់គ្នាទៅវិញទៅមក ដោយអំណាចពេជ្រនិងត្បូងយ៉ាងល្អ ៗ បំផុត ។ លុះទ្រង់រកឃើញមាន់នៅរស់ ហើយទ្រង់យាងតាមរុក្ខវិថី ដែលមានផ្ទះល្អ ៗ និងហាងលក់ទំនិញគ្រប់យ៉ាង ហាក់ដូចជាព្រះអង្គ យាងទៅដល់នគរឋានសួគ៌ ។

គ្រានោះ ព្រះរាជាទ្រង់ជ្រាបច្បាស់ថា របស់ទាំងនេះ ជាវត្ថុអស្ចារ្យ

ណាស់ ហើយទ្រង់ត្រិះរិះ ក្នុងព្រះចិន្តាថា "យីអើ! បុរីទិព្វនេះ មិនមែនស្នាដៃរបស់មនុស្សធម្មតាទេ! គឺពិតជាមានអញ មានលក្ខណៈត្រូវឲ្យនិម្មិតបានប្រាសាទមាស, ប្រាសាទប្រាក់នេះ ដែលមានពន្លឺត្រចះត្រចង់ ប្រកបដោយភាពសុភស្ដម " ។

បន្ទាប់មក, ទ្រង់យាងត្រឡប់ ទៅយកក្អកដំរីទាំងពីរ នឹងក្អមមាសហើយទ្រង់វិលមកគង់ក្នុងប្រាសាទទិព្វនេះ ជាមួយនឹងមាន់ ។

ឯស្រីទេពអប្សរ ដែលនៅក្នុងក្អកដំរី នឹងក្អមមាស បានចេញមកបង្ហាញខ្លួន ឲ្យព្រះមហាក្សត្រឃើញ, ស្ត្រីទេពអប្សរទាំងបីនេះ មានរូបឆោមល្អ ៗ ប្រកបដោយពណ៌ត្រចះត្រចង់យ៉ាងអស្ចារ្យ ឧបមាដូចជាស្ត្រីឋានសួគ៌ ។ ព្រះមហាក្សត្រ កាលទតឃើញហើយ ក៏មានព្រះទ័យប្រតិព័ទ្ធស្នេហាចំពោះទេវកញ្ញាទាំងបីនេះ ព្រមទាំងសុំដែងការកក្ដីផង ។

ព្រះរាជាទ្រង់តាំងស្ត្រីទេពអប្សរ ដែលនៅក្នុងក្អកស្ដាំ, ជាមហេសីស្ដាំ, តាំងស្ត្រីទេពអប្សរ ដែលនៅក្នុងក្អកឆ្វេង, ជាមហេសីឆ្វេង ។ ចំណែកស្ត្រីទេពអប្សរដែលនៅក្នុងក្អមមាស, ទ្រង់តាំងជាមហេសីកណ្ដាល ។ រួចពីនោះមក, ព្រះអង្គទ្រង់សន្មតនាមនគរជា "បុរី·បុស្បា" ដែលជាក្រុងមានកេរ្ដិ៍ឈ្មោះអស្ចារ្យ ក្នុងសាកលលោក ។

អ្នកជំនួញគ្រប់ប្រទេស បាននាំទំនិញនឹងគ្រឿងបរិភោគ គ្រប់បែបគ្រប់យ៉ាង ចូលមកក្នុងនគរបុរី·បុស្បានេះ ដែលស្គាល់តែសេចក្ដី

សម្បូណ៌សប្បាយទីងសេចក្ដីសុខស្ងាត់ត្រៀមត្រួត ។

ព្រះមហាក្សត្រទ្រង់ចិញ្ចឹមទីងលើកតម្កើងមាន់ឡូទីងខុសជាងអ្នកមានបណ្ដាស័ក្ដិតូច តាមសម័យនោះ នៅក្នុងព្រះរាជអាណាចក្រ ។

ព្រះអង្គទ្រង់សោយរាជសម្បត្តិ នៅនគរនោះបាន ១០០ ឆ្នាំ ទើបព្រះអង្គ ទ្រង់ទីវង្គត ។ ឯមហេសីទាំងបីព្រះអង្គ ក៏ស្លាប់តែបាត់នៅពេលនោះដែរ, ពីព្រោះវិមាននោះជាវត្ថុកើតឡើងដោយឫទ្ធិ ។

រឿងព្រេងនេះ សន្មតថា ចប់តែត្រឹមប៉ុណ្ណេះ ។

| |
|---|
| រឿងព្រេងប្រយោជន៍ យើងដឹងវង្សពូជ<br>ធំទៀមទម្លាប់ ប្រវត្តិសាស្ត្រជាតិ<br>ប្រពៃណីតាប់ សង្គមស្រុកស្រាប់<br>ក្រោមច្បាប់សាសនា ។<br>រ. ប. |

**កំណាត់ទី៨ ប្រវត្តិការណ៍**

## ដំណើរទស្សនាការសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត_តាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ក្រុងភ្នំពេញ

### រៀបរៀងដោយ ជា-ទន់

សាស្ត្រាចារ្យទទួលភារៈខាងការបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

(តមក)

---

អ្នកគ្រូដែលបង្ហាត់ មានឫកពាជាអ្នក-ផ្ទន់ផ្ទ ៈបះប្រុងប្រយ័ត្នណាស់ មានគុណៈ កោសល្យសម្បត្តិបរិបូណ៌, គេបង្ហាត់ក្មេងឲ្យលេង បង្ហាត់ដើរ.ឈរ.អង្គុយ ឲ្យច្រៀង ឲ្យរាំ ឲ្យរត់ ឲ្យនិយាយ ... គេបង្ហាត់ឲ្យកូនក្មេងតូចៗ អាយុ ៤.៥.៦ ឆ្នាំ ហាត់ច្រៀងបទនគរពេទន៍ជាតិរបស់គេ ៗ គេបង្ហាត់ បង្រៀន ពន្យល់ ធ្វើឲ្យក្មេងចូលចិត្ត ឲ្យប្រឡាញ់ទន់ជាតិរបស់គេ ឲ្យស្រឡាញ់ សាលារៀន ឲ្យស្រឡាញ់ការរៀនសូត្រ ៗ ដោយគាប់ចិត្តបង្ហាត់បង្រៀន បារបទ តាំងពីតូចក្របខ្នារយ៉ាងនេះ ហើយ កូនប្រុសស្រីអាមេរិកាំងអាយុ ៧.៨ ឆ្នាំ នាំគ្នាដើរត្រសង ៗ ដើរបណ្ដើរច្រៀងគ្នាបណ្ដើរទៅ សាលារៀន ដោយឥតមានអ្នកណាបន្ទំក្បែរសោះឡើយ, គឺទៅសាលារៀន ដោយសប្បាយ, មានគ្រឿងសប្បាយនៅឯសាលា ៗ នៅតំបន់ដែល ឆ្ងាយ ៗ ពីសាលារៀន មានឡានធំ ៗ ហៅថា School bus ទៅដឹក ជញ្ជូនកូនអ្នកស្រុកទៅ-មកសាលារៀន ៗ ដូច្នេះ កូនក្មេងអ្នកស្រុកដែល

នៅឆ្ងាយពីសាលា មិនមានលំបាកនឹងទៅសាលារៀនឡើយ ។

នៅថ្នាក់ខ្ពស់ ៗ កូនក្មេងធំ ៗ អាយុ ៨.៩ ឆ្នាំឡើងទៅ, ការរៀនសូត្រ ក៏ចេះតែចំរើនឡើង គ្រូអ្នកបង្រៀនក៏មានការប្រឹតប្រៀបច្រើនជាងថ្នាក់ក្រោម ៗ ។

គ្រូបង្រៀនប្រុសស្រី, សាស្ត្រាចារ្យ និងសិស្ស ឬ និស្សិត មានការជិតជិត នឹងគ្នាណាស់, មិនមានប្រកាន់មានះ ចំពោះគ្នានឹងគ្នាទេ មានការគួរសម ចំពោះគ្នាទៅវិញទៅមក, មិនមានប្រើពាក្យគំហកកំហែង គំរោះគំរាមទ្រគោះបោះបោករកគ្នាទេ ។ ច្បាប់ទាំងឡាយណា ដែលគ្រូត្រូវប្រតិបត្តិចំពោះសិស្ស គេប្រតិបត្តិតាមច្បាប់នោះ ពុំហ៊ានឲ្យល្អៀងឡើយ ។

ចំណែកការសិក្សានៅវិទ្យាល័យ ឬ មហាវិទ្យាល័យ មានរបៀបប្លែកគ្នាដូចខ្ញុំនឹងពណ៌នាតទៅនេះ ៖

ខ្ញុំបាននិយាយមកពីមុនខ្លះហើយថា និស្សិតនៅមហាវិទ្យាល័យសុទ្ធសឹងធំ ៗ អាយុ ១៧-១៨ ឆ្នាំទៅហើយ ហើយការរៀនសូត្រក្នុងមហាវិទ្យាល័យទោះបីមហាវិទ្យាល័យពដការរដ្ឋ ឬ មហាវិទ្យាល័យឯកជនក៏ដោយ ក៏ត្រូវចេញថ្លៃឈ្នួលសាលា និងថ្លៃផ្ទះសំណាក់អាស្រ័យ ៗ ដូច្នេះ, ដោយហេតុនេះហើយ និស្សិតប្រុសស្រី គប្បីរកប្រាក់ ៗ ប្រាក់បានមក ដោយមធ្យោបាយបែបណា គេត្រូវរកដោយមធ្យោបាយបែប នោះគេធ្វើគូលីស៊ីឈ្នួល ធ្វើការនៅហាងលក់ដូរផ្សេង ១ ហាងលក់ដូរថែខ្ទបង្អារ ហាងលក់ថ្នាំ ហាងលក់សៀវភៅ លក់កាសែត ឬ នៅភោជនីយដ្ឋាន ធ្វើអ្វីក៏ដោយ ឲ្យតែបានប្រាក់នឹងរៀនសូត្រ ផ្សេងៗនិងប្រាក់

ដែលឪពុកម្ដាយ ជួយទំនុកបំរុងផង អាចញុំាងការសិក្សាឲ្យប្រព្រឹត្តទៅបាន ៗ បានឮថា អ្នកស៊ីឈ្នួលធ្វើការផ្សេង ៗ តែងបានរង្វាន់ឬថ្លៃឈ្នួលយ៉ាងតិច មួយដុល្លារក្នុង១ម៉ោង ហើយបើធ្វើការខុសពេលម៉ោង ថ្លៃឈ្នួលត្រូវកើនឡើង មួយជាពីរ ឬជាពីរកន្លះ ក្នុងមួយម៉ោង ៗ ហេតុនេះ និស្សិតប្រុសស្រីនៅមហាវិទ្យាល័យ តែងចែកពេលធ្វើការ ក្រៅពីពេលរៀន គេរៀនផង ធ្វើការផង ៗ ធ្វើការរៀងរាល់ថ្ងៃ បានលុយកាន់តែច្រើន, ច្រើនជាងចំនួនប្រាក់ ដែលត្រូវបង់ឲ្យថ្លៃសាលា ឬ ផ្ទះសំណាក់ ៗ គេទិញរបស់ដែលត្រូវការជាការចំបាច់ ទិញអ្វី? ទិញឡាន ! ឡានជាជំនិះចាំបាច់បំផុតនៅស.រ.អា, និស្សិតច្រើនគ្នា មានឡានផ្ទាល់ខ្លួន សំរាប់សម្រួលការរៀនសូត្រ មិនមែនជាជំនិះសំរាប់ជះបង្អួតគេ ឲ្យគេដឹងថាខ្លួនមានឡានជិះទេ ឯឡានទៀតសោត ក៏ងាយទិញប្រើប្រាស់ណាស់, គេមានលក់ឡានចាស់ ដែលគេប្រើ ២-៣-ឆ្នាំហើយ ទីងឡានថ្មី តម្លៃមានតាំងពី ពីរ-បី-៤រយដុល្លារ ឡើងទៅ ឯឡានថ្មី តម្លៃមានតាំង ពី១៧០០ដុល្លារ ទៅដល់៦ពាន់ដុល្លារ ៗ

នៅមហាវិទ្យាល័យខ្លះ ,គេតម្រូវនិស្សិតប្រុសស្រី ធ្វើការយ៉ាងតិចដប់ម៉ោងក្នុង ១ សប្ដាហ៍ ដើម្បីហាត់ហ្វឹក ឲ្យថ្នឹកនូវបំណះ ដែលបានរៀនរួចហើយ, មានកិច្ចការគ្រប់ជំពូក ដែលគេចែកឲ្យនិស្សិត ស្រីប្រុសបាន ធ្វើគ្រប់គ្នា ៗ មហាវិទ្យាល័យដែលគេតម្រូវឲ្យនិស្សិត ធ្វើការយ៉ាងដូច្នោះគេមិនយកថ្លៃឈ្នួលសាលាទេ ព្រោះគេឲ្យនិស្សិតធ្វើការឲ្យគេរាល់ថ្ងៃហើយដូចជាធ្វើការនៅសណ្ឋាគារ,លក់ដូរ,ត្បាញ,ធ្វើគ្រឿងឈើ តុ ទូ ៗលៗ

យ៉ាងដូចជា មហាវិទ្យាល័យបេរៀ នៃខេនថេកឃី Berea KentucKy ជាដើម ប៉ុន្តែ គេយកថ្លៃឈ្នួលផ្ទះសំណាក់អាស្រ័យ ។ ចំណែកខាងផ្ទះសំណាក់អាស្រ័យនិស្សិត បែកជា២យ៉ាងក៏មានជា ៣យ៉ាងក៏មាន គឺមហាវិទ្យាល័យខ្លះ មានផ្ទះសំណាក់ សំរាប់និស្សិតប្រុស សំរាប់និស្សិតស្រី សំរាប់និស្សិតដែលមានប្តីប្រពន្ធ ។ ផ្ទះសិស្សសំណាក់អាស្រ័យនៅ ហៅថា Dormitory ( F. Dortoir ) ។

ទីសំណាក់អាស្រ័យនៃនិស្សិតទាំងឡាយ យើងសង្កេតឃើញក្នុង ១ បន្ទប់ៗ មានគ្រែពីរ ទីដាក់សរសេរពីរ សម្រាប់និស្សិតពីរនាក់ ក្រៅពីនេះ មានកន្លែងទទួលភ្ញៀវ ឬ កន្លែងអង្គុយលេង ដែលមានទូរស័ព្ទមួយ ទីងទស្សនាវដ្តី កាសែត ទីងសៀវភៅជាច្រើន, មានបន្ទប់ទឹកដោយឡែកពីគ្នា, នៅមហាវិទ្យាល័យខ្លះ មានបបនដ្ឋាន (ជើងក្រាន) សំរាប់ចំអិនម្ហូបអាហារ តាមសេចក្តីត្រូវការនៃនិស្សិត ។ ផាសុកភាពនៃនិស្សិតទាំងឡាយ ដែលនៅរៀនក្នុងមហាវិទ្យាល័យមួយ ១ ឃើញជាបរិបូរគួរជាទីជ្រះថ្លា ក្នុងការរៀនសូត្រក្រៃពេក ។ កូនអាមេរិកាំងទាំងឡាយតែងបន្តការសិក្សារបស់ខ្លួន នៅមហាវិទ្យាល័យនានា ដូចខ្ញុំបានពណ៌នាដោយសង្ខេបមកនេះ ។ នៅមហាវិទ្យាល័យ មានរយៈឆ្នាំសិក្សា ៤ ឆ្នាំយ៉ាងតិចគឺរៀន៤ឆ្នាំដំបូង បានសញ្ញាបត្រមួយហៅថា ឌីប្លូម៉ា, រៀន២ ឆ្នាំទៀតបានឋានៈជាម៉ាស់ទើរ Maste Degree រៀន៤ឬ៣ឆ្នាំតទៅទៀត បានឋានៈជាដុកទ័រ ដែលជាឋានៈខ្ពស់បំផុតក្នុងមហាវិទ្យាល័យ ។ នេះជាការសិក្សាទីងរបៀបសិក្សាដោយសង្ខេបនៅសហរដ្ឋ ។

អំពីបណ្ណាល័យ ទីកន្លែងដែលសំរាប់ដំកល់ក្បួនច្បាប់ក្រិតក្រម គម្ពីរដីកាឯកសារផ្សេងៗ ដើម្បីសាធារណជនសិក្សាតាមការ ហៅថា បណ្ណាល័យ (Library) ។ នៅសហរដ្ឋ មានបណ្ណាល័យជាច្រើនអនេកអនន្តណាស់គ្រប់សាលារៀន ទោះជាសាលាបឋមសិក្សាតូចតាចយ៉ាងណាក្តី ធំក្តី សាលាមធ្យមសិក្សាក្តី មហាវិទ្យាល័យក្តី មានបណ្ណាល័យធំៗ សម្រាប់កុមារកុមារីសិស្សឬនិស្សិត ។ នៅមហាទីក្រុងនានាសុទ្ធតែមានបណ្ណាល័យ ។ ទីក្រុងតាំងឡាយ ស្រុក ឃុំតូចតូចតាច គឺមានបណ្ណាល័យដែរ ។ បណ្ណាល័យ ជាទីបណ្តុះពូជធារនៃចំណេះវិជ្ជាចំណែកមួយក្នុងបណ្តាគ្រឹះស្ថានសិក្សាតាំងឡាយ ។ បណ្ណាល័យច្រើនណាស់ ដែលព្រះតេជព្រះគុណព្រះពោធិវង្សនិងខ្ញុំបានឃើញក្នុងដំណើរទស្សនានេះ ។ ក្នុងបណ្ណាល័យមួយដូចមួយឃើញមានសៀវភៅរាប់លាន ដែលគេដំកល់ទុកយ៉ាងមានរបៀបត្រឹមត្រូវ ក្នុងអាគារធំៗច្រើនជាន់, មានបន្ទប់អានធំល្វឹងល្វើយប្រដាប់ដោយតុកៅអី ភ្លើងដោយពន្លឺអគ្គិសនីព្រោងព្រាតគួរជ្រះថ្លា ។ ក្នុងបន្ទប់អាន គេឥតមានសូរស័ព្ទអ្វីនាំឱ្យរំខានអ្នកអានសោះឡើយ ។ បណ្ណារក្សច្រើនតែជាភេទស្រីជាអ្នកផ្គត់ផ្គង់រកសៀវភៅដល់អ្នកអានរាប់រយនាក់ក្នុង ១ ថ្ងៃ ។ ។

ឯសារមន្ទីរ គឺមានច្រើនពន់ប្រមាណណាស់ ហើយមានអ្នកដំណើរទស្សនារៀងរាល់ថ្ងៃ ។ ខ្ញុំពុំអាចនឹងអធិប្បាយឱ្យសព្វគ្រប់អំពីសារមន្ទីរបានឡើយ ព្រោះនៅក្នុងសារមន្ទីរមួយ មានបុរាណវត្ថុ សារវត្ថុច្រើនពេកណាស់ តែខ្ញុំអាចបំព្រួញដោយខ្ញុំថា បណ្តាគ្រឹះស្ថានសិក្សា

ទាំងឡាយ សារមន្ទីរជាទីមានសារប្រយោជន៍សំខាន់ចំណែកមួយ ។ សារមន្ទីរជាកន្លែងបង្រៀនប្រវត្តិសាស្ត្រ ដល់អ្នកប្រវត្តិសាស្ត្រទាំងឡាយ ។ នៅក្នុងសារមន្ទីរនីមួយ ៗ, គេដាក់លំរូបចម្លាក់, ក្បាច់ក្បូរ, បុរាណវត្ថុនានា ដែលបង្ហាញឲ្យឃើញនូវវប្បធម៌សម័យបុរាណនៃប្រទេសនីមួយ ៗ អារ្យធម៌, វប្បធម៌, វប្បធម៌ សម័យបុរាណនិងសម័យបច្ចុប្បន្ន នៃប្រទេសទាំងឡាយ គេអាចឃើញច្បាស់នៅសារមន្ទីរ ។ ដើម្បីឲ្យបញ្ញាជនបានរៀនសូត្រពីគ្រប់ផ្នែកសិក្សា ដូចជាខាងគ្រឿងចក្រ, គ្រឿងហត្ថកម្ម, លទ្ធិសាសនាជាដើម គេបានបង្កើតឲ្យមានសារមន្ទីរជាច្រើន ។ សិល្បៈសម័យបុរាណ និងវិចិត្រសិល្បៈសម័យថ្មី, គេរៀបតាក់តែងមានរបៀបរៀបរយល្អ សម្រាប់សាធារណជនមើល ។

អំពីប្រជាជន.— សហរដ្ឋអាមេរិក ជាប្រទេសធំទូលំទូលាយណាស់ ព្រោះប្រទេសនេះ បានរួមរដ្ឋទាំង ៤៨ រួមបូលគ្នាតែមួយ ហៅថា សហរដ្ឋអាមេរិក តាមភាសាអង់គ្លេសថា United States of America (F. Etats Unis d'Amérique) ។ ភូមិភាគដែលឋិតនៅក្នុងទ្វីបអាមេរិកខាងជើង ហៅថា North America ឬ ទ្វីបអាមេរិកដែលស្ថិតនៅខាងត្បូង ហៅថា South America ឬ អាមេរិកកណ្ដាល ហៅថា Central America នេះមិនចាប់ចូលក្នុងសហរដ្ឋ ដែលមានរដ្ឋ ៤៨ រួមបូលគ្នានោះឡើយ ។

(មានត)

# ព្រះរាជដំណើរសម្តេចព្រះឧបយុវរាជ
# ទៅកាន់កោះសិរីលង្កាក្នុងពិធីបុណ្យពុទ្ធជយន្តី ។

លោក ក៉ាយ-ប៊ុគា រៀបរៀង

កាលពីថ្ងៃអង្គារ ទី១២ កុម្ភៈ ១៩៥៧ ម៉ោង ៧ និង១៩នាទី, សម្តេចព្រះឧបយុវរាជនរោត្តមសីហនុ ទ្រង់យាងចេញព្រះរាជដំណើរ ដោយអាកាសយានពិសេស ក្រុមអាកាសយានខេមរភូមិន្ទ ឆ្ពោះទៅកាន់កោះសិរីលង្កា ។ ព្រះរាជដំណើរនេះ គឺធ្វើដោយសេចក្តីអញ្ជើញជាផ្លូវការនៃរដ្ឋាភិបាលកុលម្បូ សូមទ្រង់យាងទៅជាព្រះរាជកិត្តិយស ក្នុងពិធីបុណ្យពុទ្ធជយន្តីនៅប្រទេសសិរីលង្កា ។

បានស្តេចយាង និងអញ្ជើញទៅជាមួយនិងសម្តេចគឺ ព្រះអង្គម្ចាស់ក្សត្រី នរោត្តម-សូរ្យារឿងស៊ុ, ព្រះរាជបុត្រី សហជីវិនសាន-យុន រដ្ឋមន្ត្រីមួយនិងលោកស្រី សហជីវិនសឺន-សាន, សមញ្ញាណ, ហ៊ូ-ហុន និងនាយទាហានពីរនាក់ ។

លុះដល់ម៉ោង ១១ និង ៣០ នាទី សម្តេចទ្រង់បានយាងទៅដល់ទីក្រុងរង្គូន (ប្រទេសភូមា) ហើយទ្រង់បានឈប់សម្រាកព្រះកាយពលនៅទីនោះ ។

ក្នុងពេលដែលទ្រង់យាងចុះពីព្រះទីនាំងអាកាសយានពិសេស, មានមន្ត្រីធំៗនៃក្រសួងការពារប្រទេស មានឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំប្រទេសប៉ូល៉ូញនិងប្រទេសយូកូស្លាវីនិងប្រតិភូនៃអគ្គរាជទូតសិរីលង្កាជាដើម បានអញ្ជើញទៅកាន់ស្ថានទីអាកាសយាន ដើម្បីសំដែង

ការគោរព ចំពោះព្រះអង្គជាព្រះរាជកិត្តិយស ។

ក្នុងពេលនោះ រដ្ឋាភិបាលប្រទេសភូមា ក៏បានរៀបចំពិធីបុណ្យលៀងព្រះស្ងោយ នៅអាកាសយានដ្ឋាននោះ ។ លុះទ្រង់សោយព្រះស្ងោយរួច ព្រមទាំងព្រះរាជបរិវារ ទ្រង់ក៏បានស្តេចយាងឡើងព្រះទីនាំងអាកាសយានពិសេសហោះទៅកាន់ទីក្រុងកាល់កុត្តា ( ប្រទេសឥណ្ឌា ) ។

ក្នុងពេលដែលទ្រង់យាងចុះពីព្រះទីនាំងអាកាសយាន, មានអ្នកតំណាងរដ្ឋាភិបាលបង់កាល់ ប្រធានមហាពោធិសមាគមកាល់កុត្តា និងការ៉ាវៃនស្ថានឯកអគ្គរាជទូតប្រទេសកម្ពុជា ប្រចាំប្រទេសឥណ្ឌា បានអញ្ជើញទៅសំដែងសេចក្ដីគោរពចំពោះព្រះអង្គ ។

លំដាប់តមក មានពិធីទទួលខាងពុទ្ធសាសនា ដែលមហាពោធិសមាគមទីក្រុងកាល់កុត្តា បានចាត់ចែងជូនចំពោះសម្ដេច និងលោករដ្ឋមន្ត្រីមួយ សាន-យុន ។

ក្រោយដែលមានពិធីបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា សម្ដេចក៏បានយាងទៅគង់នៅលើវេទិកាកិត្តិយស ព្រមទាំងលោក សាន-យុន និងព្រះរាជបរិវារ ។ ពេលនោះ មានពួកភិក្ខុជាច្រើន បានជូនសព្ទថា សរសើរព្រះកិត្តិនាមសម្ដេចព្រះឧបយុវរាជ ដែលពិភពលោកទទួលស្គាល់ចំពោះសកម្មភាពព្រះអង្គខាងព្រះពុទ្ធសាសនានិងសន្តិភាពលោក ។

លំដាប់តមក សម្ដេចទ្រង់ថ្លែងនូវព្រះរាជសន្ទរកថាមួយ ទទួលអំណរគុណឧបការៈ ចំពោះពួកពុទ្ធមាមកជន ទាំងគ្រហស្ថទាំងបព្វជិតដែលអញ្ជើញមកប្រជុំក្នុងទីនោះ, ព្រមទាំងបញ្ជាក់នូវការប្រាស្រ័យដ៏

ផលសង្ខេបនៃនយោបាយ សិប្បៈនិងសាសនា រវាងប្រទេសកម្ពុជានឹងប្រទេសឥណ្ឌា ហើយទ្រង់បានប្រទានពរសព្ទសាធុការ, សូមឲ្យប្រទេសឥណ្ឌា បានប្រកបដោយសន្តិភាពនិងសម្បូណ៌ភាព សមតាមបំណងតទៅ ។

ក្នុងឱកាសនៃពិធីបុណ្យនោះ សម្តេចបានធ្វើព្រះរាជអំណោយចំពោះប្រធានមហាពោធិសមាគម នូវព្រះពុទ្ធរូបប្រាក់មួយអង្គ និងបច្ច័យ ១០០០ រូពី ។ ចំណែកឯមហាពោធិសមាគម ក៏បានថ្វាយចំពោះព្រះអង្គនូវព្រះពុទ្ធរូបធ្វើពីថ្មបន្ទំមួយអង្គ ។

សម្តេចព្រះឧបយុវរាជ, ព្រះអង្គម្ចាស់ក្សត្រី សុវ៉ារឿងស៊ី រដ្ឋមន្ត្រីទីមួយសាន-យុន និងលោកស្រីជាភ្ញៀវកិត្តិយសនៃនាយករដ្ឋបង់គល នៅទីក្រុងកល់កត្តា ។

## ថ្ងៃពុធទី ១៣ កុម្ភៈ

ម៉ោង ៧ សម្តេចទ្រង់យាងចេញពីទីក្រុងកល់កត្តា ដោយព្រះរាជទីនាំងអាកាសយានពិសេស បន្តព្រះរាជដំណើរទៅដល់ទីក្រុងម៉ាដ្រាស់ (ប្រទេសឥណ្ឌា) ពេលថ្ងៃត្រង់ព្រមទាំងព្រះរាជបរិវារ ។ រដ្ឋាភិបាលនៃទីក្រុងម៉ាដ្រាស់ ក៏បានធ្វើពិធីលៀងព្រះក្រយាស្ងោយ ចំពោះសម្តេចព្រះឧបយុវរាជ និងនាហ្មឺនដែលធ្វើដំណើរជាមួយនឹងព្រះអង្គ ។

ម៉ោង ១៤, សម្តេចទ្រង់បន្តព្រះរាជដំណើរ ឆ្ពោះទៅកាន់ទីក្រុងកុលម្ប ដែលទ្រង់យាងទៅដល់ពេលម៉ោង ១៧ ។

រដ្ឋមន្ត្រីបីរូប បានអញ្ជើញទៅសំដែងគារវភាពចំពោះសម្តេចនៅ

ចំណតអាកាសយាន ជាព្រះរាជកិត្តិយស ។

កន្លែងពេលដែលសម្ដេចយាងចុះពីព្រះទីនាំងអាកាសយាន មានកាំភ្លើងធំបាញ់ម្ភៃមួយពភាត់ ថ្វាយជាព្រះរាជកិត្តិយស ។ លំដាប់តមកលោកស្រីប័ន្ទរនៈ អ៊ីកេ (Bandaranaike) នាយករដ្ឋមន្ត្រីទីមួយនៃប្រទេសសិរីលង្កា (ដោយស្វាមីមានពេគាពាធ) និងប្រធានព្រឹទ្ធសភាបានអញ្ជើញទៅទទួលសម្ដេច កន្លែងពេលដែលសម្ដេចយាងចុះ ពីព្រះទីនាំងអាកាសយាន ។ បុត្រលោកនាយករដ្ឋមន្ត្រីទាំងពីរនាក់ បានយកកួនបុប្ផាមកថ្វាយសម្ដេចនិងព្រះអគ្គមហេសីក្សត្រីសុរ៉ាម៉ារិទ្ធ ។

លំដាប់តមក, ក្រុមនាយទាហានឈរគោរពសម្ដេច ហើយសម្ដេចទ្រង់យាងត្រួតពល, រួចព្រះសង្ឃបានចំរើនពុទ្ធជ័យមង្គលថ្វាយ ។ កន្លែងពេលនោះ ពួកមន្ត្រីធំតូចទាំងអស់និកទាហាន បានអញ្ជើញមកទទួលសម្ដេច ព្រមទាំងប្រជាជនប្រុសស្រីគឹកកងរំពង ពេញចំណតអាកាសយាន; ពួកការទូតនានាប្រទេស ក៏បានអញ្ជើញមកគោរពសម្ដេច ហើយបរិយាកាសកន្លែងពេលនោះ មានសភាពរីករាយផ្សព្វផ្សាយពេញទីក្រុង ប្រកបដោយទិដ្ឋភាពប្រុសស្រាយសប្បាយ ជាអនេកប្បការ ។

រួចសម្ដេចទ្រង់បានចុះព្រះហត្ថលេខាលើ " សៀវភៅបុណ្ណ " ហើយទ្រង់ថ្លែងព្រះរាជសុន្ទរកថាដូចតទៅនេះ៖ ១

ព្រះរាជរដ្ឋាភិបាលខ្មែរបានទទួលយល់ព្រមដោយសេចក្ដីសោមនស្សជាយ៉ាងក្រៃពេក ចំពោះការអញ្ជើញដោយស្មោះស្ម័គ្រ នៃរដ្ឋាភិបាលប្រទេ

សស៊ីរលង្កា ហើយបានចាត់ព្រះពុទ្ធគណៈប្រតិភូមួយ ដើម្បីទៅរួមប្រជុំក្នុងពិធីបុណ្យពុទ្ធជយន្តីនេះ ។

ក្នុងព្រះបរមនាម នៃព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, ព្រះនាមនៃពុទ្ធគោលពេញពាល ទីងប្រជាជាតិខ្មែរ, ខ្ញុំមានកិត្តិយសក្នុងឋានៈជាប្រធានគណប្រតិភូ ដែលមានឧត្តមបុគ្គលិកប្រទេស ជាសមាជិក ថ្លែងនូវសេចក្តីសោមនស្សជាយ៉ាងក្រៃលែង ។ ដោយខ្ញុំបានមកកាន់ប្រទេសរបស់អ្នក ដែលជាប្រទេសមានការប្រស្រ័យខាងរឿងរ៉ាវព្រះពុទ្ធសាសនាជាអនេកប្បការ ហើយជាប្រភពនៃព្រះពុទ្ធសាសនា មានសភាពដូចគ្នាទីងប្រទេសកម្ពុជា ខ្ញុំមានបំណងជាបឋមចង់នាំសេចក្តីគោរពដោយចិត្តភក្តីទីងភាគកោព នៃពួកពុទ្ធសាសនិកជនខាងបព្វជិតជាង ៨០០០០ រូប ទីងគ្រហស្ថ ៤ មុឺននាក់ មកជូនចំពោះពួកខុបាសកខុបាសិកាប្រទេសសីរលង្កា ។

លំដាប់តមក, ខ្ញុំមានបំណងបញ្ជាក់ត្រង់លក្ខណៈជិតស្និទ្ធជាយ៉ាងជ្រាលជ្រៅនៃការគមនាគមន៍ ដែលមានផែនការណ៍ទាំងអស់ខាងសាសនា, សិល្បៈការ្យធម៌, ទំនៀមទម្លាប់ ធ្វើឲ្យប្រទេសទាំងពីររួបរួមគ្នា តាំងពីព្រេងសតវត្សរ៍មកហើយ ។

មិនតែប៉ុណ្ណោះ ដោយមានជំនឿក្នុងព្រះពុទ្ធសាសនាដូចគ្នា ប្រទេសសីរលង្កា ទីងប្រទេសកម្ពុជា ក៏បានទទួលអនុមតិនូវនយោបាយអព្យាក្រិតភាពទីងសហការប្រកបដោយសន្តិភាព ចំពោះប្រជាជាតិទាំងអស់ ដែលគោរពឯករាជ្យទីងអធិបតីភាព របស់ប្រទេសយើង ។

នយោបាយនេះ បានស្ដាបនានូវចំណងជាថ្មីមួយរវាងប្រទេសទាំងពីរទៅវិញទៅមក, ដែលមានចិត្តជាប់ស្អិតទៅនឹងច្បាប់សីលធម៌ សេចក្ដីព្រមព្រៀងរវាងជាតិ និងសន្តិភាពពិភពលោក ។

គណៈប្រតិភូរបស់យើង មានចិត្តសោមនស្សជាមុន ដោយបានមកកាន់ទីនេះ ជាហេតុឲ្យលើកកិត្តិយសចំពោះពិធីបុណ្យពុទ្ធជយន្តិនៅទីនេះ ហើយមានបំណងជាយ៉ាងខ្លាំងក្លា ចង់ឲ្យគណៈប្រតិភូប្រទេសសិរីលង្កា, អញ្ជើញទៅកាន់ពិធីបុណ្យដូចគ្នា ដែលប្រទេសកម្ពុជានឹងធ្វើក្នុងខែវិសាខាខាងមុខនេះ ដើម្បីនឹងតម្កើងនូវពិធីបុណ្យនេះ ឲ្យកាន់តែឧឡារិកឡើងថែមទៀត ។

ខ្ញុំជឿជាក់ថា ការដែលយើងឋិតនៅប្រទេសអ្នក នឹងនាំឲ្យយើងមានចំណងថ្មី ដែលជាហេតុធ្វើឲ្យសមភាពរវាងប្រទេសយើងទាំងពីរឲ្យកាន់តែមានពលភាពឡើង និងបញ្ចេញរស្មី ចូលមកឋិតនៅក្នុងប្រាជ្ញារបស់យើង ឲ្យកាន់តែភ្លឺស្វាងរុងរឿងឡើង ហើយនឹងស្ដាបនានូវសេចក្ដីយល់ជាក់ច្បាស់ដ៏ប្រសើរ រវាងប្រជារាស្ត្រ ជាបងប្អូនរួមសាច់ឈាមទាំងពីរ ជាកិយោភាពតទៅអនាគត ។

(មានត)

# សន្និសីទនៃបណ្ឌិតវិស្សាទ៍អេក្លាក

## ធ្វើនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ

លោក ប៉ៃយ.ប៉ុក រៀបរៀង

(តមក)

## ៣.- វិជ្ជាដែលជាមូលដ្ឋាននៃការសិក្សាព្រះពុទ្ធសាសនា

តាមសេចក្តីពិតក្នុងការសិក្សាថា បើគោលបំណងបានគិតត្រឹមត្រូវ ហើយ បានថ្លឹងទុកហើយ បានយល់ច្បាស់ហើយថាជាគោលបំណង ដែលត្រូវបំពេញឲ្យសម្រេច ហេតុនោះរឿងរ៉ាវឬវិជ្ជាដែលត្រូវសិក្សា ត្រូវលៃលកឲ្យសមតាមគោលបំណងនោះ ព្រោះថាការពិចារណាតទៅ មុខនូវគោលបំណងដើម នៃការសិក្សាព្រះពុទ្ធសាសនា បានចង្អុលយ៉ាង ច្បាស់លាស់ដល់វិជ្ជា ដែលគួរសិក្សានិងបង្រៀន គឺ ធម៌ ការចេះដឹង អំពីសង្គមមនុស្សនិងវត្ថុដែលនៅជុំវិញ ។

ការរៀនធម៌បែបចាស់គឺ ការអាននិងទន្ទេញបទបាលីគាថាណាមួយ ឬទាំងអស់នៃព្រះសូត្រ ព្រះវិន័យនិងព្រះអភិធម្មក្នុងគម្ពីរមួយ ឬច្រើន ដោយភាសា ភូមា ខ្មែរ លាវសេរីលង្កា ឬ ថៃ ដែលប្រែពីធម៌នោះមក ក្នុងក្បួនតម្រា និងមេរៀន ឬ មួយវិញទៀត ដែលគេហៅថា ពាក្យ អត្ថាធិប្បាយ ។ ការរៀនដោយវិធីអាននិងទន្ទេញនោះ និងប្រើសម្រាប់ សិក្សាធម៌ ដែលមានក្នុងភាសាសំស្ក្រឹត ទីបេ ចិន ជប៉ុន និងភាសា ឯទៀតផង ។ ការសិក្សាធម៌បែបទំនើប គឺរួមការសិក្សាបែបចាស់

និងការអធិប្បាយអត្ថន័យតាមភាសាបច្ចុប្បន្នឲ្យបានសេចក្តីច្បាស់លាស់ និងរក្សាតម្លៃរបស់ភាសាឲ្យបានគង់ដូចដើម ។

តាមការពិត ការសិក្សាអត្ថបទនិងគម្ពីរទំនើបនៃជនជាតិអាស៊ីនិងបច្ចិមទិកាយបានជួយរក្សាធម៌និងអត្ថាធិប្បាយនៃធម៌នោះ ។ ព្រោះជាការបំពេញគោលបំណងក្នុងការសិក្សាព្រះពុទ្ធសាសនាឲ្យបានពេញបរិបូណ៌ ។

ការសិក្សាព្រះពុទ្ធសាសនាតាមការពិតនោះ រមែងទាន់កាលទាន់សម័យជានិច្ចទាំងខាងផ្លូវទ្រឹស្តីនិងផ្លូវប្រតិបត្តិ ត្រូវអាស្រ័យលើការស្រាវជ្រាវដ៏មានប្រយោជន៍ និងវិធីធ្វើឲ្យបានស្រួល ដោយមិនបាច់គិតដល់យុគណា ឬសម័យណាទេ ។

ការបេះដឹងអំពីរឿងសង្គមមនុស្សនិងវត្ត ដែលនៅជុំវិញជាភាគមួយដ៏សំខាន់បំផុតក្នុងការរៀនព្រះពុទ្ធសាសនា ។ ព្រោះថាគម្ពីរនិងការពិសោធន៍ខាងផ្លូវព្រះពុទ្ធសាសនា ផ្តើមឡើងដោយការញែកសង្ខារមនុស្សឲ្យឃើញថាជា ទុក្ខំ អនិច្ចំ និង អនត្តា ។ ព្រះពុទ្ធសាសនាបង្រៀនឲ្យស្គាល់ ឲ្យបេះរឿងជីវិត ។ ក្នុងរឿងនេះការសិក្សាឯទៀតក្រៅពីព្រះពុទ្ធសាសនា ក៏នៅក្រៅរឿងដែលទាក់ទងនិងគម្ពីរព្រះពុទ្ធសាសនា ហេតុនោះទើបគ្មានការជំទាស់គ្នាទៅវិញទៅមករវាងការរៀនព្រះពុទ្ធសាសនា និងចំណេះវិជ្ជាដទៃទៀត ក្នុងការសិក្សាព្រះពុទ្ធសាសនា ។ បើពិចារណាតាមប្រវត្តិសាស្ត្រ ក្នុងធម៌មានទីតាំងជាច្រើន ដែលទាក់ទងដល់លក្ខខណ្ឌបញ្ហា និងសេចក្តីត្រូវការរបស់សង្គម បានព្រះពុទ្ធសាសនាជាគ្រឿងនាំផ្លូវឲ្យសមកាលនិងសម័យនៃការបង្រៀនឬសិក្សាអត្ថបទ ។

ព្រះសម្ពុទ្ធជាម្ចាស់ បានត្រាស់ដឹងជាពិតប្រាកដនូវវត្ថុដែលនៅជុំវិញរាងកាយនិងសង្គម ហើយទ្រង់ប្រទានពាក្យប្រៀនប្រដៅរបស់ព្រះអង្គឲ្យពាក់ទងនឹងរឿងទាំងនោះផង ៗ តាមសេចក្តីពិត លក្ខណៈនៃទុក្ខំ អនិច្ចំ និងអនត្តា តែងកើតមានដល់សង្គមទូទៅ ដូចជាកើតមានដល់បុគ្គលពល់រូបឥតបន្ទោះដូច្នោះដែរ ៗ

ការពិចារណាឲ្យយល់ច្បាស់ និងអធិប្បាយឲ្យបានពេញទីនូវសមុទយសច្ចនិងកម្ម ត្រូវអាស្រ័យការបេះដឹងវត្ថុនៅជុំវិញខ្លួនដែលបុគ្គលម្នាក់ ៗ អាចសង្កេតទៅឃើញច្បាស់លាស់មួយវិញទៀត ការប្រតិបត្តិតាមផ្លូវអដ្ឋង្គិកមគ្គនិងការបំពេញបារមី១០ ដែលបានចំរើនហើយ អាចនាំឲ្យបានដល់ជីវិតដ៏ប្រសើរសម្រាប់បុគ្គលនិងសង្គម ៗ

ការបេះដឹងដែលគួរពឹងផ្អែកបាន គឺការចុំនប្រសប់ដែលសន្សំទុករបស់បុគ្គលម្នាក់ៗនិងការស្ទាត់ជំនាញម្នាក់នៃសង្គម ៗ ហេតុនោះការបេះដឹងនេះមែនបានលទ្ធផលមកពីការប្រតិបត្តិតាំងពីដើមមក និងជាបំណេះវិជ្ជាទាន់សម័យជានិច្ច ៗ ក្នុងអតីតកាលក៏ដូចជាក្នុងពេលបច្ចុប្បន្នដែរ ការសិក្សាព្រះពុទ្ធសាសនា ត្រូវរៀនឲ្យស្ទាត់ជំនាញក្នុងការសិក្សាភាសាសាស្ត្រ ប្រវត្តិសាស្ត្រការប្រែប្រួលនៃសង្គម ការស្គាល់តម្លៃនិងសកម្មភាពនៃសេដ្ឋកិច្ច គោលបំណងនិងវិធីសិក្ខាត្តមគតិមនុស្សជាតិចំពោះច្បាប់និងសេចក្តីយុត្តិធម៌ ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈឲ្យបានពេញទី គោលបំណងស៊ីវិល សង្គមកិច្ចឧត្តមគតិខាងទស្សនវិជ្ជា ការប្រព្រឹត្តិប្រតិបត្តិការស្រាវជ្រាវខាងផ្លូវវប្បធម៌ ចរិយាសាស្ត្រ ជីវភាពក្នុងសម័យ

វិទ្យាសាស្ត្របណ្ណាល័យនិងពិពិធភ័ណ្ឌ សម្រាប់រក្សាទុកនូវកេរ្តិ៍មតកដ៏ថ្លៃថ្លានៃគំនិតនិងស្នាដៃរបស់មនុស្ស ។

និយាយដោយខ្លី វិជ្ជាដែលជាមូលដ្ឋាននៃការសិក្សាព្រះពុទ្ធសាសនា ត្រូវឲ្យមានវិជ្ជាដែលគួរសិក្សា គ្រប់ជំពូកដើម្បីឲ្យបានសម្រេចតាមគោលបំណងនៃសង្គម ។

## ៤.- របៀបជាមូលដ្ឋាននៃការសិក្សាខាងព្រះពុទ្ធសាសនា

ការរៀនសូត្រនិងវិធីបង្រៀនខាងការសិក្សា ព្រះពុទ្ធសាសនានោះ តែងត្រូវការជាចម្បង នូវរបៀបខ្លះដែលជាមូលដ្ឋានចំពោះគោលបំណងនិងកម្មវត្ថុ ។ នៅទីនេះក៏ដូចគ្នា និងទីដទៃដែរ ៈ ការរៀនសូត្រនិងការបង្រៀន ការសិក្សានិងការអប់រំ ត្រូវអាស្រ័យគ្នាទៅវិញទៅមក ទើបបានសម្រេច ។ ការសិក្សាខាងព្រះពុទ្ធសាសនា ធ្វើឲ្យនិស្សិតនិងគ្រូបង្រៀនចូលរួមគ្នានូវវត្ថុបំណងនិងការពិសោធន៍តែមួយ ។

វិធីរៀនខាងព្រះពុទ្ធសាសនាតាមទំនៀមទំលាប់ មានការស្តាប់គ្រូបង្រៀន ការកែខុសកែត្រូវ និងការដញ្ញាំងគិតៈដោយខ្លួនឯង រៀនថ្វីងដោយមាត់ឬដោយការសរសេរ ការសាកសួរ និងការសាកល្បង ការទន្ទេញចាំមាត់ និងការប្រតិបត្តិអំពីមុខវិជ្ជាដែលបានរៀនមកហើយ ។ របៀបបែបនេះនៅតែមានប្រើប្រាស់ក្នុងសម័យសិក្សាបច្ចុប្បន្ន ទោះបីវិធីសូត្រនិងវិធីអធិប្បាយខុសគ្នាយ៉ាងណាក៏ដោយ ។

ការប្រតិបត្តិជាមូលដ្ឋានក្នុងការសិក្សាព្រះពុទ្ធសាសនា តាមប្រពៃណី គ្មានអ្វីជាជាងវិធីរៀន ដែលសំដែងក្នុងអរិយសច្ច ៤ ទេ ដំបូង

បង្អស់ ការសង្កេតនិងការប្រមូលរឿងរ៉ាវដែលទាក់ទងនឹងជីវិតដ៏មិនទៀងទាត់, ទីពីរ វិធីរកខុសត្រូវនិងការស្វែងរកហេតុផល ។ សមុទយសច្ច ទីបី ក្បួននៃទ្រឹស្ដីដែលអាចអនុវត្តទៅតាមស្ថានការណ៍ ឬ ការរំលត់សមុដ្ឋាននៃទុក្ខ "និរោធសច្ច" និងទីបួន ការធ្វើឲ្យប្រាកដឡើងនូវទ្រឹស្ដី ឬការត្រួតពិនិត្យសមុដ្ឋាននៃនិរោធសច្ច ដោយប្រតិបត្តិតាម "មគ្គសច្ច" ។ វិធីរៀនតាមប្រពៃណីក្នុងព្រះពុទ្ធសាសនា តោងប្រកបដោយការស្រាវជ្រាវក្នុងវិទ្យាសាស្ត្រ ខាងសង្គមកិច្ចនិងខាងរូបកាយ ។

វិធីបង្រៀនខាងព្រះពុទ្ធសាសនាតាមទំនៀមទំលាប់មាននិយាយប្រាប់ដល់ពួកអ្នកសិក្សា ការធ្វើអត្ថាធិប្បាយដោយសរសេរជាលាយលក្ខណ៍អក្សរ ការធ្វើសាកច្ឆា និងការណែនាំឲ្យស្រាវជ្រាវ ហើយនិងការបង្ហាញឧទាហរណ៍នៃវត្ថុដែលបង្រៀន ។ គរុកោសល្យបែបនេះទោះបីក្នុងវិជ្ជាស្ថានការអប់រំដែលមិនទាក់ទងខាងព្រះពុទ្ធសាសនាក៏ដោយ ត្រូវយកមកប្រើក្នុងសម័យបច្ចុប្បន្ន ។

ហេតុនេះ វិធីជាមូលដ្ឋាននៃការសិក្សាខាងព្រះពុទ្ធសាសនា ទើបជាការសិក្សាតាមប្រពៃណីនិងសម័យថ្មី ដោយមានបញ្ជាក់ក្នុងការប្រតិបត្តិដែលបានតាំងឡើង និងធ្វើឲ្យបានរុងរឿងឡើងដោយការប្រើប្រាសនិងដោយផ្លូវបច្ចេកទេសទំនើបៗ វិធានការដែលបានលទ្ធផលល្អនិងការស្រួលក្នុងការរៀននិងបង្រៀនខាងព្រះពុទ្ធសាសនា តែងបានប្រយោជន៍និងគួរប្រាថ្នាជានិច្ច ទីបំផុតសភាពបីក្នុងការសិក្សារមែងប្រែប្រួលទៅតាមវត្ថុដែលនៅជុំវិញ សង្គមតែម្យ៉ាងក្នុងសម័យនៃប្រវត្តិសាស្ត្រ ។ (មានត)

(តមក)

## ព្រះមហា ប៉ាង-ខាត់ រៀបរៀង

—*នាសិកា* ស្ត្រី. ចុងនៃច្រមុះ។ —*និរូបណ* នបុ. កិរិយាសម្រេចមុន ។ —*ប* គុ. ដែលផឹកមុន ។ — *បាណិ* បុំ. ចុងនៃដៃ, ដៃស្តាំ ។ — *បាទ* បុំ. ចុងនៃជើង; ម្រាមជើង។ —*បូជា* ស្ត្រី. បូជាដ៏ប្រសើរ ។ —*បេយ* នបុំ. កិរិយាផឹកមុន ។ —*ប្រទាយិន* គុ.អ្នកប្រគល់ឲ្យមុន ។-*ប្រគីណ៌* គុ. ដែលមានកំពូលបែកបាក់។—*ភាគ* បុំ.ភាគដ៏ខ្ពង់ខ្ពស់,កំពូល ៗ —*ភុជ* គុ. ដែលស៊ីមុន បុំ. ព្រះអាទិត្យ ។ —*ភូ* គុ. ជាមេ,ជាប្រធាន។—*ភូមិ* ស្ត្រី.ជាន់ខាងលើ; សេចក្តីប្រាថ្នាជាន់ខ្ពស់ ។-*ភោជិន* គុ.អ្នកបរិភោគវត្ថុដ៏ប្រសើរ។ *ភោជ្យ* គុ.ដូច*អគ្រភោជិន*។*មហិឞី* ស្ត្រី. អគ្គមហេសី ។ —*មាំស្យ* នបុំ.ថ្លើម,ដួងចិត្ត។—*យាត* កា.គុ. អ្នកដើរខាងមុខ ។—*យាន*, នបុំ. ដំហានទៅមុខដើម្បីតស៊ូសត្រូវ, អគ្រយាន។—*យាយិន* គុ.អ្នកដើរមុខ; អ្នកនាំ ។ —*យោធិន* គុ. ដែលមានយោធា,មេទាហាន ,ទ័ពស្រួច,ជើងឯក ។ *វីរ* ,. វិរបុរសដ៏ប្រសើរ ។ —*ឝិខ* គុ.ដែលមានអណ្តាតភ្លើងស្រួច ។ —*សំខ្យា* ស្ត្រី.សំខ្យាដើម,ជាន់ទីមួយ ដើមខ្សែ។ —*សំធ្យា* ស្ត្រី. កាលខាងដើមនៃសន្ធិវេលា,អរុណ ។ —*សន្ធានី* ស្ត្រី បញ្ជីព្រះយមរាជ ។—*សរ* គុ.ដែលប្រព្រឹត្តទៅក្នុងខាងមុខ; —*សរតា* ស្ត្រី. ភាពនៃ..... ប្រព្រឹត្តទៅក្នុងខាងមុខ ។ —*សូចី* ស្ត្រី. ចុងនៃម្ជុល ។ — *ហ* គុ. ដែលជាមេ។ — *ហស្ត* បុំ. ម្រាមនៃដៃ,ប្រមោយ។ - *ហាយណ* បុំ. ខាងដើមនៃឆ្នាំ, នាមខែនៃហិណ្ឌូ (មាគសិរ ប្រហែលខែទី ១២ ខែធ្នូ) ។ — *ហារ* បុំ. ការព្រះរាជទានដីដល់ព្រាហ្មណ៍,ដីឬភូមិដែលទ្រង់ប្រទាន ។

*អគ្រាក្សិ* (អគ្រ + អក្សិ) នបុំ. កិរិយាក្រឡេកមើល,ចុងនៃភ្នែក ។ *អគ្រាង្គ* (អគ្រ+អង្គ) បុំ. ដូចអគ្រភាគ ។ *អគ្រាំឝុ* (អគ្រ+អំឝុ) បុំ.ចុងនៃរស្មី។—

(មានត)